សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Science Economiqes

Royal University of Law and Economics


## សារណាបញ្ចប់ការសិក្សា

# ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ

ស្រាវជ្រាវពីថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០១៩ ដល់ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩


ស្រាវជ្រាវដោយៈ

និស្សិតឈ្មោះៈ កញ្ញា **ស សៀវយី**

កញ្ញា **សន ដាណេ**

សាស្ត្រាចារ្យណែនាំ

លោក **ទេព សុខ**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥

ឆ្នាំសរសេរសារណា ២០១៩

សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច

Université Royale de Droit et des Science Economiqes

Royal University of Law and Economics


## សារណាបញ្ចប់ការសិក្សា

# ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ

ស្រាវជ្រាវពីថ្ងៃទី ១៧ ខែឧសភា ឆ្នាំ២០១៩ ដល់ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩


ស្រាវជ្រាវដោយ៖

និស្សិតឈ្មោះ កញ្ញា **ស សៀងឃី**

កញ្ញា **សន ដាណេ**

សាស្រ្តាចារ្យណែនាំ

លោក **ទេព សុខ**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្រ្ត**

ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥

ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងពីរនាក់ឈ្មោះ **ស សៀងយី** និង **សន ដាណេ** ជានិស្សិតបរិញ្ញាបត្រផ្នែកនីតិសាស្ត្រជំនាន់ទី ១៩ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**យើងខ្ញុំទាំងពីរអ្នកសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ**

អ្នកម្តាយ **សាយ វណ្ណា** លោកយាយ **ខៀវ ណៃ** លោកតា **ដាវ ស** លោកឪពុក **ឯម ពៅ** និងអ្នកម្តាយ **អ៊ុច សុផា** ដែលលោកបានផ្តល់កំណើត និងចិញ្ចឹមបីបាច់ ថែរក្សាថ្នាក់ថ្នមរូបយើងខ្ញុំតាំងពីពេលចាប់កំណើត មកដល់សព្វថ្ងៃនេះដោយក្តីស្រលាញ់ និងការសណ្តោសប្រណីដោយព្រហ្មវិហារធម៌ ជាពិសេសគឺជាគ្រូ ដែលបានផ្តល់នូវការអប់រំ ទូន្មានដំបូងបំផុតក្នុងជីវិតរបស់យើងខ្ញុំទាំងពីរ លើសពីនេះទៅទៀតលោកទាំងពីរតែងតែជួយជ្រោមជ្រែងគ្រប់សព្វបែបយ៉ាង ទាំងស្មារតី និងសម្ភារៈ សម្រាប់ផ្គត់ផ្គង់ដល់ការរៀនសូត្ររបស់យើងខ្ញុំតាំងពីថ្នាក់បឋមសិក្សា រហូតដល់បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចនាវេលានេះ ដោយពុំដែរត្អូញត្អែរពីភាពនឿយហត់បន្តិចណាសោះឡើយ ដែលទាំងនេះ គឺកម្លាំងជំរុញដ៏អស្ចារ្យឲ្យខ្ញុំតស៊ូដើម្បីដើរមកដល់ភាពជោគជ័យរបស់យើងខ្ញុំទាំងពីរនាពេលបច្ចុប្បន្ននេះ។

សូមថ្លែងការដឹងគុណដល់ស្ថាបនិកអង្គការមូលនិធិ លោកប៉ា **ស្កុត និសិន** (**Scott Nesson**) និងបុគ្គលិកអង្គការមូនិធិគ្រប់ជាន់ថ្នាក់ទាំងអស់ ដែលបានផ្គត់ផ្គង់ការសិក្សារ តែងតែអប់រំផ្តល់ដំបូន្មានល្អៗ លើកទឹកចិត្ត ផ្តល់កន្លែងស្នាក់នៅ និងតែងតែផ្តល់កំលាំងចិត្តដល់នាងខ្ញុំរហូតមកតាំងពីថ្នាក់វិទ្យាល័យ រហូតដល់ចប់ថ្នាក់សលកវិទ្យាល័យ។ ក្រៅពីនេះអ្នកទាំងអស់គ្នាតែងតែដើរតួនាទីជាលោកឪពុក អ្នកម្តាយ បងប្រុស បងស្រី និងជាបុគ្គលគម្រូភាពមួយសម្រាប់ខ្ញុំ ក្នុងការដឹកនាំខ្ញុំដើម្បីក្លាយជាពលរដ្ឋល្អដើរក្នុង ផ្លូវដែលត្រឹមត្រូវមកដល់នាពេលបច្ចុប្បន្ន។

សូមថ្លែងអំណរគុណដល់ក្រុមគ្រួសារទីពីររបស់ខ្ញុំ មានលោកឪពុក **Allan Nathanson** អ្នកម្តាយ **Jeanine Braithwaite** ព្រមទាំងបងប្រុសបងស្រីទាំងបី ដែលអ្នកទាំងអស់គ្នា តែងតែផ្គត់ផ្គង់ការសិក្សាររបស់នាងខ្ញុំ ផ្តល់កំលាំងចិត្ត បង្ហាត់បង្រៀននាងខ្ញុំកន្លងមក និងតែងតែជម្រុញអោយនាងខ្ញុំខិតខំសិក្សារដើម្បីអោយនាងខ្ញុំបានមកដល់ថ្ងៃនេះ។ ទោះបីជាអ្នកទាំងអស់មិនមែនជាខ្សែលោហិតអ្វីនឹងនាងខ្ញុំ មិនមែនជាឈាមជ័រជាខ្មែរក៏ដោយ ប៉ុន្តែទឹកចិត្ត និងសេចក្តីស្រលាញ់របស់លោកមកលើនាងខ្ញុំពិតជាធំធេងណាស់សម្រាប់នាងខ្ញុំ ដែលលោកជាចំណែកដ៏ធំធេងក្នុងភាពជោគជ័យរបស់ខ្ញុំ។

យើងខ្ញុំសូមគោរពថ្លែងអំណរគុណផងដែរចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស និងលោក លោកស្រីសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**

**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ទាំងអស់ដែលបានយកចិត្តទុកដាក់ចំណាយពេលវេលា និងកម្លាំងញើសឈាមដ៏មានតម្លៃរបស់អស់លោក ដើម្បីបណ្តុះបណ្តាល និងបំពេញបន្ថែមនូវពុទ្ធិដល់រូបយើងខ្ញុំក៏ដូចជាមិត្តនិស្សិតទាំងអស់ដែលសិក្សានៅក្នុងសាកលវិទ្យាល័យនេះ គ្រប់មុខវិជ្ជាតាំងពីថ្នាក់សិក្សាឆ្នាំមូលដ្ឋាន រហូតដល់បញ្ចប់ការសិក្សា។

យើងខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលបំផុតចំពោះ **លោកសាស្ត្រាចារ្យ ទេព សុខ** ដែលលោកសាស្ត្រាចារ្យ បានទទួលយកនូវការដឹកនាំក្នុងការសរសេរសារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំ ដោយលោកបានចំណាយនូវពេលវេលាដ៏មានតម្លៃទាំងកម្លាំងកាយ និងកម្លាំងចិត្តក្នុងការបណ្តុះបណ្តាល និងពន្យល់ណែនាំផ្តល់ជាចង្កៀងដើម្បីបំភ្លឺគំនិតដល់យើងខ្ញុំ ក្នុងរយៈពេលកន្លងមកនេះ រហូតយើងខ្ញុំបានចងក្រងនូវសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រមួយនេះឡើងដោយភាពជោគជ័យ។

ជាទីបញ្ចប់យើងខ្ញុំទាំងពីររូប សូមគោរពជូនពរដល់អស់ **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស លោកសាស្ត្រាចារ្យ និងសិស្សនិស្សិតទាំងអស់** សូមឲ្យបានជួបប្រទះតែនូវពុទ្ធពរទាំងបួនប្រការគឺៈ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

សារណាមួយក្បាលនេះ គឺជាសមិទ្ធផលមួយដែលកើតឡើងពីការខិតខំប្រឹងប្រែង ការតស៊ូព្យាយាមក្នុងការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អស់រយៈពេលបួនឆ្នាំកន្លងមកនេះ ដើម្បីបន្សល់ទុកជាស្នាដៃមួយ សម្រាប់ជាគុណប្រយោជន៍ ទៅដល់សិស្សនិស្សិតជំនាន់ក្រោយៗ ក្នុងការសិក្សាស្រាវជ្រាវបន្ត។

ការសិក្សាអស់រយៈពេលបួនឆ្នាំកន្លងមកនេះ គ្រប់មុខវិជ្ជាដែលយើងខ្ញុំបានសិក្សា គឺសុទ្ធតែមានសារៈសំខាន់ៗសម្រាប់អនុវត្តក្នុងសង្គមយើងនាពេលបច្ចុប្បន្ននេះ ហើយសម្រាប់យើងខ្ញុំផ្ទាល់ដោយឃើញថាប្រទេសកម្ពុជាសព្វថ្ងៃយើងជាប្រទេសដែលកំពុងតែអភិវឌ្ឍន៍ ទើបបណ្តាលឲ្យយើងខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំងទៅលើមុខវិជ្ជារដ្ឋប្បវេណី ដែលជាមុខវិជ្ជាគ្រឹះមួយ សម្រាប់ការអភិវឌ្ឍទៅលើវិស័យយុត្តិធម៌នៅព្រះរាជាណាចក្រកម្ពុជាប្រសើរឡើង និងមានយុត្តិធម៌នៅក្នុងសង្គម។ ជាក់ស្តែងនាពេលបច្ចុប្បន្នវិស័យយុត្តិធម៌នេះ គឺជាអំណាចមួយក្នុងចំណោមអំណាចធំៗទាំងបីនៅកម្ពុជា ដែលជាចំណុចចម្បងមួយដែលត្រូវពង្រឹង និងកំពុងតែពេញនិយម ដែលជាហេតុផលធ្វើឲ្យយើងខ្ញុំបានជ្រើសរើសយកការស្រាវជ្រាវសារណាមួយនេះឡើង ក្រោមប្រធានបទស្តីអំពី "**ការអនុវត្តដោយបង្ខំលើអចលនវត្ថុ**"។

តាមរយៈស្នាដៃស្រាវជ្រាវមួយនេះ យើងខ្ញុំសង្ឃឹមយ៉ាងថាវានឹងអាចជួយបន្ថែមនូវចំណេះដឹងថ្មីៗ និងផ្តល់ជាអត្ថប្រយោជន៍ជាច្រើនទៅដល់អ្នកអានគ្រប់រូប ពិសេសនិស្សិតជំនាន់ក្រោយឲ្យបានយល់កាន់តែស៊ីជម្រៅ ជាពិសេសជួយសម្រួលឲ្យមានភាពងាយស្រួលក្នុងការស្វែងយល់អំពីនីតិវិធីនៃការអនុវត្តដោយបង្ខំ ក៏ដូចជាការអនុវត្តដោយបង្ខំនៃអចលនវត្ថុនៅក្នុងប្រព័ន្ធតុលាការកម្ពុជាឲ្យបានត្រឹមត្រូវ ទៅតាមដំណាក់កាលនីមួយៗ និងស្របតាមច្បាប់ដែលជាធរមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ទោះបីជាយ៉ាងណាក៏ដោយ យើងខ្ញុំក៏សូមធ្វើការខន្តី អភ័យទោសនូវរាល់ចំណុចខ្វះខាតដូចជាការបប្រើប្រាស់ពាក្យពេចន៍ អត្ថន័យ ឬកំហុសឆ្គងអចេតនាណាមួយដែលមាននៅក្នុងសារណាមួយនេះទុកជាមុន ព្រោះយើងខ្ញុំជឿជាក់ថា ពិតជាគ្មានអ្វីដែលល្អឥតខ្ចោះបាននោះឡើយ ដូចនេះយើងខ្ញុំត្រូវតែទទួលស្គាល់នូវកំហុសទាំងឡាយរបស់យើងខ្ញុំ និងទទួលយកនូវការកែតម្រូវរបស់អ្នកអានតាមរយៈការផ្តល់ជាមតិយោបល់ រិះគន់ដើម្បីភាពស្ថាបនារបស់មិត្ត និស្សិត អ្នកអានទាំងអស់ដើម្បីឲ្យស្នាដៃមួយនេះកាន់តែមានភាពល្អប្រសើរឡើង។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១**

**សញ្ញាណគតិយុត្តនៃការអនុវត្តដោយបង្ខំ**

**ផ្នែកទី១៖ សញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំ** ........ ៤

១. លក្ខខណ្ឌនៃការអនុវត្តដោយបង្ខំ ........ ៥

២. បណ្តឹងពាក់ព័ន្ធនឹងការអនុវត្ត ........ ៦

៣. ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ ........ ៧

៤. សោហ៊ុយសម្រាប់ការអនុវត្ត និងការមើលសំណុំរឿងនៃការអនុវត្ត ........ ៨

**ផ្នែកទី២៖ ប្រភេទនៃការអនុវត្តដោយបង្ខំលើអចលនវត្ថុ** ........ ៩

១. ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ........ ៩

២. ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ........ ១១

៣. ការអនុវត្តដោយបង្ខំចំពោះនាវា ........ ១៣

៤. ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ........ ១៣

**ជំពូកទី២**

**លំហូរនៃនីតិវិធីអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ**

**ផ្នែកទី១៖ ការដាក់ពាក្យសុំ និងទីកន្លែងដាក់ពាក្យសុំអនុវត្ត** ........ ១៤

១. លិខិតអនុវត្ត ........ ១៤

២. លិខិតដែលបានបញ្ជាក់ពីការបានបញ្ជូនលិខិតអនុវត្ត ........ ១៥

៣. រូបមន្តអនុវត្ត ........ ១៦

៤. ពាក្យសុំលក់ដោយបង្ខំចំពោះអចលនវត្ថុ ........ ១៦

**ផ្នែកទី២៖ ស្ថាប័នអនុវត្ត** ........ ១៧

១. ការបំបែកស្ថាប័នវិនិច្ឆ័យ និងស្ថាប័នអនុវត្ត ........ ១៧

១.១. ស្ថាប័នវិនិច្ឆ័យ ........ ១៧

១.២. ស្ថាប័នអនុវត្ត ........ ១៨

២. តុលាការអនុវត្ត ........................................................................................ ២១
២.១. ទីកន្លែងដែលត្រូវដាក់ពាក្យ ........................................................................... ២១
២.២. ឯកសារចំបាច់ក្នុងការដាក់ពាក្យ ...................................................................... ២២
២.៣. លិខិតអនុវត្ត ................................................................................................ ២២
២.៤. លិខិតបញ្ជាក់ពីការបញ្ជូនលិខិតអនុវត្ត ............................................................ ២៣
៣. រូបមន្តអនុវត្ត ................................................................................................. ២៣
៣.១. នីតិវិធីនៃការផ្តល់រូបមន្តអនុវត្ត ....................................................................... ២៥
៣.២. ពាក្យសុំផ្តល់រូបមន្តអនុវត្ត ............................................................................... ២៦
៤. ពាក្យសុំលក់ដោយបង្ខំចំពោះអចលនវត្ថុ ............................................................... ២៧
៥. ដីការសម្រេចចាប់ផ្តើមការលក់ដោយបង្ខំចំពោះអចលនវត្ថុ ....................................... ២៨
**ផ្នែកទី៣៖ លិខិតគតិយុត្តក្នុងការអនុវត្ត** ............................................................... ២៩
១. លិខិតអនុវត្តដែលអាចអនុវត្តបានដោយគ្មានបញ្ហា ................................................ ៣០
២. លិខិតអនុវត្តដែលមានបញ្ហា ............................................................................. ៣០

## ជំពូកទី៣

## ទំនាក់ទំនងគតិយុត្តរវាងការអនុវត្តដោយបង្ខំ និងការរក្សាការពារ

**ផ្នែកទី១៖ គោលការណ៍នៃការរឹបអូស** ................................................................... ៣១
១. ការរឹបអូសជាបណ្តោះអាសន្ន និង ការអនុវត្តដោយបង្ខំ ............................................ ៣១
២. ការប្តូរពីការរឹបអូសជាបណ្តោះអាសន្ន ទៅការអនុវត្តពិតប្រាកដ .................................. ៣៤
**ផ្នែកទី២ ៖ ការលក់** .......................................................................................... ៣៤
១. ការស្រាវជ្រាវ ................................................................................................... ៣៤
២. ការលក់ ........................................................................................................... ៣៨
៣. អានុភាព ........................................................................................................ ៣៩
**ផ្នែកទី៣៖ ចែកចំណែក** ....................................................................................... ៤០
១. ការរៀបចំការចែកចំណែក ................................................................................. ៤០
២. ការចែកចំណែក ................................................................................................ ៤១
**សេចក្តីសន្និដ្ឋាន** .............................................................................................. ៤៥
**អនុសាសន៍** ...................................................................................................... ៤៦

**ឯកសារពិគ្រោះ**........................................................................................................................................ ៤៩
**ឧបសម្ព័ន្ធ**........................................................................................................................................ ៥០

# សេចក្តីផ្តើម

# សេចក្តីផ្តើម

ប្រជាជនខ្មែរទាំងអស់គ្នាបានដឹងហើយថា ក្រោយពីប្រទេសយើងបានជួបនូវសង្គ្រាមស៊ីវិល ទាំងសង្គ្រាមជាមួយបរទេសក្តី ជាពិសេសគឺការដាក់នឹមអាណានិគមនិយមបារាំងមកលើប្រទេសកម្ពុជា។ ដោយសារតែការដាក់នឹមអាណានិគមនេះមានរយៈពេលដ៏យូរ ដែលនាំឲ្យប្រទេសយើងមានការយកលំនាំតាមប្រទេសបារាំង ទាំងទំនៀមទំលាប់ ទាំងភាសា ដែលជាពិសេសនោះគឺច្បាប់រដ្ឋប្បវេណីតែម្តង។ ពោលគឺ អត្តន័យនៃមាត្រាមួយចំនួននៅក្នុងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មានលក្ខណៈប្រហាក់ប្រហែលជាមួយនឹងមាត្រាមួយចំនួននៃក្រមរដ្ឋប្បវេណីរបស់ប្រទេសបារាំងបច្ចុប្បន្ន។

ក្រោយពីប្រទេសទទួលបានសន្តិភាពហើយ ប្រជាពលរដ្ឋក៏ចាប់ផ្តើមមានទំនាក់ទំនងគ្នាក្នុងការងារសេដ្ឋកិច្ច ការងារសង្គមកិច្ច ការងារប្រចាំថ្ងៃ និងទំនាក់ទំនងផ្សេងៗទៀត។ ដើម្បីគ្រប់គ្រងរាល់ទំនាក់ទំនងទាំងនេះ គឺចាំបាច់បង្កើតឲ្យមានច្បាប់។ ដូចនេះដើម្បីអាចអនុវត្តច្បាប់រដ្ឋប្បវេណីគឺមានស្ថាប័នតុលាការជាអ្នកមានសមត្ថកិច្ចក្នុងការដោះស្រាយ។ នីតិរដ្ឋប្បវេណីដែលជាច្បាប់ទម្រង់ គឺមានគោលបំណងដើម្បីឲ្យតុលាការដោះស្រាយវិវាទរដ្ឋប្បវេណី ដោយផ្អែកលើធាតុច្បាប់ដើម្បីការពារសិទ្ធិរបស់បុគ្គលឯកជន។ នៅក្នុងដំណើរការក្នុងការដោះស្រាយវិវាទរដ្ឋប្បវេណីដោយផ្អែកលើច្បាប់ដើម្បីការពារសិទ្ធិរបស់បុគ្គលឯកជន។ នៅក្នុងដំណើរការដោះស្រាយរឿងក្តីរដ្ឋប្បវេណីការអនុវត្តដោយបង្ខំ ពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ម្ចាស់បំណុល ដែលបានអនុញ្ញាតឲ្យម្ចាស់បំណុលសម្រេចសិទ្ធិស្តាពររបស់ខ្លួនត្រឡប់មកវិញ។ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោលបំណងឲ្យសងជាប្រាក់ ត្រូវបានចែកជាបួនប្រភេទគឺ៖ ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ការអនុវត្តដោយបង្ខំចំពោះនាវា និងការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល។ ដោយសារក្នុងក្រមនីតិវិធីរដ្ឋប្បវេណីបានកំណត់អំពីការអនុវត្តដោយបង្ខំជាច្រើនប្រភេទដូច្នេះ ទើបយើងខ្ញុំសូមលើកយកការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ មកធ្វើការស្រាវជ្រាវ ហើយបានរៀបចំចងក្រងជាសារណាដែលមានចំណងជើងថា: **ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ**។

គោលបំណងដែលយើងខ្ញុំជ្រើសរើសប្រធានបទ ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងជាសារណា ដោយសារតែយើងខ្ញុំយល់ឃើញថាប្រធានបទខាងលើនេះមិនទាន់មានការយល់ដឹងទូលំទូលាយនៅឡើយទេ ពោលគឺនិតីវិធីអនុវត្តដោយបង្ខំចំពោះអចលនវត្ថុនេះមានលក្ខណៈថ្មីនៅឡើយសម្រាប់ប្រជាពលរដ្ឋកម្ពុជា ជាពិសេសគឺសិស្សនិស្សិតដែលកំពុងសិក្សាផ្នែកនីតិសាស្ត្រ។ ក្រៅពីនេះទៅទៀតបើយោងតាមការសិក្សាអស់ជិតរយៈពេលជិតបួន

ឆ្នាំកន្លងមក យើងខ្ញុំបានអង្កេតឃើញថា ក្នុងកម្មវិធីសិក្សាផ្នែកនីតិរដ្ឋប្បវេណីនេះ គឺមិនទាន់មានការសិក្សាឲ្យស៊ីជម្រៅទៅលើផ្នែកណាមួយនៃការអនុវត្តដោយបង្ខំនោះទេ។ ហេតុដូច្នេះហើយទើបយើងខ្ញុំសម្រេចជ្រើសរើសយកប្រធានបទនេះមកធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងជាសារណាសម្រាប់ប្អូនៗនិស្សិតជំនាន់ក្រោយ។ ចំពោះនីតិវិធីនៃការអនុវត្តដោយបង្ខំ ដែលនឹងត្រូវលើកឡើងមកធ្វើការបកស្រាយនៅក្នុងប្រធានបទនេះ គឺយើងខ្ញុំផ្អែកលើក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០៦ កក្កដា ២០០៦ រួមទាំងបញ្ញត្តិផ្សេងៗដែលមានការពាក់ព័ន្ធថែមទៀត។

មុននឹងឈានដល់ការពន្យល់ដល់ការបកស្រាយក្បោះក្បាយទាក់ទងទៅនឹងប្រធានបទ**ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ** យើងខ្ញុំសូមធ្វើការពន្យល់នូវពាក្យគន្លឹះសំខាន់ៗជាមុនសិនដើម្បីជាភាពងាយស្រួលក្នុងការស្វែងយល់នូវខ្លឹមសារទាំងស្រុងរបស់ប្រធានបទដូចជា៖ អចលនវត្ថុ គឺសំដៅទៅលើដី អាគារដែលត្រូវបានចុះបញ្ជីចំណែកនៃកម្មសិទ្ធិអវិភាគលើដី ឬអាគារនោះ ដូចជា៖ សិទ្ធិជួលអចិន្ត្រៃយ៍ និងផលុបោគដែលត្រូវបានចុះបញ្ជី និងចំណែកនៃសិទ្ធិទាំងនេះដែលជាសិទ្ធិរួម[១]។ ចំណែកឯការអនុវត្តដោយបង្ខំ គឺជានីតិវិធីរបស់តុលាការក្នុងការសម្រេចនូវសិទ្ធិទាមទារ ឬសិទ្ធិប្រាតិ ភោគដែលបានកំណត់នៅក្នុងនីតិឯកជនដោយប្រើអំណាចរដ្ឋ។ រីឯស្ថាប័នរដ្ឋ គឺជាស្ថាប័នដែលទទួលបន្ទុកអនុវត្តដោយបង្ខំ និងជាស្ថាប័នឯករាជ្យនៃអំណាចតុលាការ ដែលស្ថាប័ននេះត្រូវបានបែងចែកចេញជាពីរ គឺតុលាការអនុវត្ត និងអាជ្ញាសាលា។ នៅក្នុងការអនុវត្តដោយបង្ខំមានភាគីពីរគឺមិនអាចខ្វះបាន គឺភាគីម្ខាងជាបុគ្គលដែលបានដាក់ពាក្យសុំឲ្យអនុវត្តដោយបង្ខំដែលហៅថា: ម្ចាស់បំណុលនៃការអនុវត្ត និងភាគីម្ខាងទៀតហៅថា កូនបំណុលនៃការអនុវត្ត។

ហេតុដូចនេះមិត្តអ្នកអាន ជាពិសេសសិស្សនិស្សិតពិតជាចង់ដឹងថា៖ តើកាអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ មានន័យដូចម្តេច និងមានលក្ខខណ្ឌយ៉ាងណា ហើយប្រព្រឹត្តទៅដោយរបៀបណា?

ដើម្បីជាយានក្នុងការដោះស្រាយចម្ងល់ទាំងនេះ យើងខ្ញុំបានបែងចែកសារណាជាជំពូកៗដូចតទៅនេះ៖

- ជំពូកទី១ ៖ សញ្ញាណគតិយុត្តនៃការអនុវត្តដោយបង្ខំ
    - ផ្នែកទី១ ៖ សញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំ
    - ផ្នែកទី២ ៖ ប្រភេទនៃការអនុវត្តដោយបង្ខំលើអចលនវត្ថុ
- ជំពូកទី២ ៖ លំហូរនៃនីតិវិធីអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ
    - ផ្នែកទី១ ៖ ការដាក់ពាក្យសុំ និងទីកន្លែងដាក់ពាក្យសុំអនុវត្ត

[១] យោងតាមមាត្រា ១២០ នៃក្រមរដ្ឋប្បវេណី ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧

- ផ្នែកទី២ ៖ ស្ថាប័នអនុវត្ត
- ផ្នែកទី៣ ៖ លិខិតគតិយុត្តក្នុងការអនុវត្ត

➢ ជំពូកទី៣ ៖ ទំនាក់ទំនងគតិយុត្តរវាងការអនុវត្តដោយបង្ខំ និងការរក្សាការពារ

- ផ្នែកទី១ ៖ គោលការនៃការរឹបអូស
- ផ្នែកទី២ ៖ ការលក់
- ផ្នែកទី៣ ៖ ចែកចំណែក

# ជំពូកទី ១

## សញ្ញាណគតិយុត្តនៃការអនុវត្ត
## ដោយបង្ខំ

# ជំពូកទី១

# សញ្ញាណគតិយុត្តនៃការអនុវត្តដោយបង្ខំ

## ផ្នែកទី១៖ សញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំ

ការអនុវត្តដោយបង្ខំ គឺជានីតិវិធីដែលធ្វើឡើងតាមផ្លូវតុលាការ ក្នុងការសម្រេចនូវសិទ្ធិទាមទារ ឬសិទ្ធិប្រាតិភោគដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី ឬច្បាប់ដែលពាក់ព័ន្ធផ្សេងៗ។ គោលបំណងនៃនីតិវិធីនេះគឺ ដើម្បីធ្វើការសម្រេចនូវសិទ្ធិទាមទាររបស់ភាគីដោយគិតទៅដល់ ការការពារប្រយោជន៍របស់ម្ចាស់បំណុលនៃការអនុវត្តហើយត្រូវធ្វើយ៉ាងណាឲ្យនីតិវិធីនៃការអនុវត្តនេះធ្វើឡើង ដោយងាយស្រួល និងឆាប់រហ័ស។

ការអនុវត្តដោយបង្ខំត្រូវធ្វើឡើងដោយស្ថាប័នតុលាការដែលជាស្ថាប័នអនុវត្ត ហើយស្ថាប័ននេះត្រូវបានបែងចែកជាពីរគឺ តុលាការអនុវត្ត និងអាជ្ញាសាលា។ ស្ថាប័នទាំងពីរខាងលើនេះមានចរិកលក្ខណៈផ្សេងពីគ្នាដោយអាស្រ័យលើកម្មវត្ថុនៃការអនុវត្តដោយបង្ខំ និងប្រភេទនៃការអនុវត្តដោយបង្ខំ។ តុលាការអនុវត្ត គឺជាតុលាការដែលមានភារកិច្ចធ្វើការអនុវត្តដោយបង្ខំ ទៅតាមនីតិវិធីនៃការអនុវត្តដោយបង្ខំ ហើយតុលាការបានកំណត់ថាជាតុលាការអនុវត្ត គឺសាលាដំបូងរាជធានីខេត្ត[2]។ ចំពោះអាជ្ញាសាលា គឺជាយុត្តាធិការឯករាជ្យមួយដែលទទួលបន្ទុកធ្វើការបញ្ជូនឯកសារនានាដែលចេញដោយតុលាការ និងធ្វើការអនុវត្តដោយបង្ខំមួយចំនួនតាមច្បាប់កំណត់។

ការអនុវត្តដោយបង្ខំមានភាគីពីរដែលសំខាន់ដែលមិនអាចខ្វះបានគឺ ភាគីម្ខាងដែលហៅថាៈ ម្ចាស់បំណុលនៃការអនុវត្ត គឺជាបុគ្គលដែលបានដាក់ពាក្យសុំឲ្យអនុវត្តដោយបង្ខំ និងភាគីម្ខាងទៀត គឺកូនបំណុលនៃការអនុវត្តដែលរាប់បញ្ចូលទាំងតតិយជនដែលបានផ្តល់វត្ថុ ឬសិទ្ធិដើម្បីធានាបំណុល ក្នុងករណីនៃការអនុវត្តសិទ្ធិប្រាតិភោគ។ ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ គឺរាល់ទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត ឬរាល់ទ្រព្យសម្បត្តិដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់កូនបំណុលនៃការអនុវត្ត។ ជាគោលការណ៍ទ្រព្យសម្បត្តិទាំងឡាយដែលជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្តត្រូវក្លាយទៅជាទ្រព្យសម្បត្តិទទួលខុសត្រូវ។ ក៏ប៉ុន្តែច្បាប់បានបញ្ញត្តិដកចេញនូវវត្ថុ និងសិទ្ធិមួយចំនួនពីទ្រព្យសម្បត្តិទទួលខុសត្រូវដូចជា៖ ប្រដាប់ប្រដាស្លៀកពាក់ គ្រឿងបរិភោគ ប្រាក់បៀវត្សជាដើម ត្រូវបានច្បាប់ហាមឃាត់មិនឲ្យរឹបអូស។ ក្នុងករណីដែលកូនបំណុលនៃការអនុវត្តបានធ្វើអនុប្បទានស្របច្បាប់នូវទ្រព្យសម្បិត្តរបស់ខ្លួន ហើយអនុប្បទាននិកបានបំពេញលក្ខខណ្ឌរួចរាល់មុនពេលអនុវត្តដោយបង្ខំ ទ្រព្យសម្បត្តិនោះមិនមែនជាទ្រព្យសម្បត្តិដែលទទួលខុសត្រូវរបស់កូនម្ចាស់បំណុលនៃការអនុវត្តទេ លើកលែងតែការធ្វើអនុប្បទានរបស់កូន

---

[2] យោងតាមមាត្រា ៣៣៦ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ ២០០៦

បំណុលនៃការអនុវត្តនោះ ជាកត្តានាំឲ្យខូចខាតដល់ម្ចាស់បំណុលនៃការអនុវត្តនោះ ម្ចាស់បំណុលនៃការអនុវត្តអាចលុប ចោលការធ្វើអនុប្បទាននោះបានដើម្បីធ្វើបដិទាននៃទ្រព្យសម្បត្តិទទួលខុសត្រូវ និងដាក់ទ្រព្យសម្បត្តិ នោះជាកម្មវត្ថុនៃការអនុវត្តតាមរយៈសិទ្ធិលុបចោលអំពើដែលនាំឲ្យខូចខាតប្រយោជន៍របស់ម្ចាស់អនុវត្តនៃការអនុវត្ត។ មានករណីទ្រព្យសម្បត្តិដែលត្រូវទទួលខុសត្រូវត្រូវបានកម្រិតនៅក្នុងទំហំមួយជាក់លាក់ ហើយមានការអនុវត្តដោយបង្ខំមិនអាចធ្វើបានចំពោះទ្រព្យសម្បត្តិផ្សេងទៀតរបស់កូនបំណុលនៃការអនុវត្តនោះទេ។ បើយោងតាមមាត្រា ៣៣៤ បានចែងថាៈ បុគ្គលដែលមានសិទ្ធិទាមទារ ឬសិទ្ធិប្រាតិភោគដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី ឬច្បាប់ផ្សេងទៀត អាចទាមទារឲ្យសម្រេចសិទ្ធិនោះដោយការអនុវត្តដោយបង្ខំ តាមបញ្ញត្តិនៃគន្ថីនេះលើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់ផ្សេង[៣]។

### ១. លក្ខខណ្ឌនៃការអនុវត្តដោយបង្ខំ

លក្ខខណ្ឌសំខាន់ក្នុងការអនុវត្តដោយបង្ខំ គឺចាំបាច់ត្រូវដាក់ពាក្យសុំឲ្យអនុវត្តដោយបង្ខំដែលពាក្យសុំឲ្យអនុវត្តដោយបង្ខំត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។ នៅក្នុងពាក្យសុំនោះត្រូវមានបញ្ជាក់អំពីឈ្មោះ ឬនាមករណ៍ អាសយដ្ឋាន របស់ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត ហើយនិងឈ្មោះ អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ សញ្ញាណនៃលិខិតអនុវត្តសេចក្តីសុំឲ្យអនុវត្តតាមការបង្ខំដោយផ្ទាល់ ឬការអនុវត្តជំនួស ឬវិធានបង្ខំដោយប្រយោលជាដើម ព្រមទាំងសញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ និងខ្លឹមសារនៃសេចក្តីសម្រេច ដែលម្ចាស់បំណុលក្នុងករណីដែលសុំឲ្យអនុវត្តដោយបង្ខំ ឬការអនុវត្តជំនួស ឬវិធានដោយប្រយោលក្តី[៤]។

ដើម្បីធ្វើការអនុវត្តដោយបង្ខំចាំបាច់ត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោមៈ

- ការដាក់ពាក្យសុំ
- លិខិតអនុវត្ត
- រូបមន្តអនុវត្ត
- ប្រាក់ប្រដាប់ក្តី

លក្ខខណ្ឌនៃការអនុវត្តដោយបង្ខំ គឺចាប់ផ្តើមឡើងដោយការដាក់ពាក្យសុំឲ្យអនុវត្តរបស់ម្ចាស់បំណុលនៃការអនុវត្ត[៥]។ ពាក្យសុំឲ្យអនុវត្តដោយបង្ខំត្រូវធ្វើឡើងដោយការដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរទៅតាមស្ថាប័នអនុវត្តដែលមានសមត្ថកិច្ចគឺតុលាការអនុវត្ត ឬអាជ្ញាសាលា។ នៅ

[៣] មាត្រា៣៣៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

[៤] មាត្រា៣៩៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

[៥] មាត្រា៣៩៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

ក្នុងពាក្យសុំជាលាយលក្ខណ៍អក្សរត្រូវមានបញ្ជាក់អំពីប្រភេទនៃការអនុវត្តដោយបង្ខំដែលសុំឲ្យធ្វើ។ ពោលគឺ ការអនុវត្តដោយផ្ទាល់ត្រូវបញ្ជាក់ផងដែរលើលិខិតនោះនូវកម្មវត្ថុនៃការអនុវត្តដោយបង្ខំ (អចលនវត្ថុ) ហើយចំពោះករណីដែលសុំឲ្យអនុវត្តដោយបង្ខំតាមការអនុវត្តជំនួស ឬវិធានបង្ខំដោយប្រយោលនោះ ត្រូវបញ្ជាក់នូវខ្លឹមសារនៃសេចក្តីសម្រេចដែលទាមទារឲ្យមានការអនុវត្តនោះ ហើយត្រូវភ្ជាប់មកជាមួយនូវលិខិតចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត។

ជាងនេះទៅទៀតក្នុងករណីមួយចំនួនតម្រូវឲ្យសរសេររៀបរាប់ក្នុងពាក្យសុំជាលាយលក្ខណ៍ អក្សរអំពីចំណុចទាំងនោះ ដើម្បីកំណត់ឲ្យជាក់លាក់នូវកម្មវត្ថុនៃការអនុវត្តដោយបង្ខំ និងការតម្រូវឲ្យដាក់ឯកសារមួយចំនួនដែលពាក់ព័ន្ធទៅនឹងកម្មវត្ថុនោះផងដែរ។

## ២. បណ្តឹងពាក់ព័ន្ធនឹងការអនុវត្ត

នៅក្នុងបណ្តឹងពាក់ព័ន្ធនឹងការអនុវត្ត គឺផ្តោតសំខាន់ទៅលើបណ្តឹងបីធំៗគឺ បណ្តឹងតវ៉ាចំពោះការទាមទារ បណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្ត និងបណ្តឹងតវ៉ាចំពោះតតិយជន។ កូនបំណុលនៃការអនុវត្តដែលមានការតវ៉ាចំពោះអត្ថិភាព ឬអត្ថន័យនៃសិទ្ធិទាមទារ ដែលត្រូវបានកំណត់នៅក្នុងលិខិតអនុវត្ត ដែលអាចដាក់ពាក្យបណ្តឹងតវ៉ាចំពោះការទាមទារ ដើម្បីកុំឲ្យតុលាការអនុញ្ញាតការអនុវត្តដោយបង្ខំ ដោយផ្អែកលើលិខិតអនុវត្តនោះបាន[៦]។ ចំពោះករណីដែលរូបមន្តអនុវត្តត្រូវបានផ្តល់ តាមបញ្ញត្តិនៃមាត្រា ៣៥៦ (រូបមន្តអនុវត្តពិសេស) នៃក្រមនីតិវិធីរដ្ឋប្បវេណី កូនបំណុលនៃការអនុវត្ត ដែលមានការតវ៉ាចំពោះការបំពេញលក្ខខណ្ឌ ចំពោះការមកដល់នៃការបរិច្ឆេទមិនពិតប្រាកដ ឬ ចំពោះលទ្ធភាពដែលអាចធ្វើការអនុវត្តដោយបង្ខំ ដោយយកបុគ្គលក្រៅពីភាគីដែលបានកំណត់ក្នុងលិខិតអនុវត្ត មកធ្វើជាម្ចាស់បំណុលនៃការអនុវត្ត ឬកូនបំណុលនៃការអនុវត្តអាចដាក់ពាក្យបណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត ដើម្បីកុំឲ្យអនុញ្ញាតការអនុវត្តដោយបង្ខំបាន ដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់នឹងរូបមន្តអនុវត្តនោះ[៧]។ ដោយឡែកបណ្តឹងតវ៉ារបស់តតិយជន គឺតតិយជនដែលមានកម្មសិទ្ធិ ឬសិទ្ធិផ្សេងទៀតដែលរាំងស្ទះការធ្វើអនុប្បទាន ឬប្រគល់ចំពោះវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ គឺអាចដាក់ពាក្យបណ្តឹងតវ៉ាដើម្បីទាមទារកុំឲ្យអនុញ្ញាតការអនុវត្តដោយបង្ខំ ចំពោះម្ចាស់បំណុលនៃការអនុវត្តនោះបាន ដោយតុលាការអនុវត្តដែលក្លាយជាស្ថាប័នអនុវត្ត ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់តុលាការអនុវត្តនោះ រីឯការអនុវត្តដោយបង្ខំដែលអាជ្ញាសាលាក្លាយជាស្ថាប័នអនុវត្ត ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាដំបូង ដែលអាជ្ញាសាលានៅស្ថិតនៅ[៨]។

---

[៦] មាត្រា៣៦៣ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

[៧] មាត្រា៣៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

[៨] មាត្រា៣៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

### ៣. ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ

ប្រសិនបើពាក្យបណ្តឹង ឬពាក្យសុំទាំងនោះត្រូវបានទទួលស្គាល់នៅពេលដែលយកអនុសាសន៍ សាលក្រម ឬសាលដីកា ឬយកឯកសារចម្លងយថាភូតនៃដីកាសម្រេចទៅដាក់នៅស្ថាប័នអនុវត្តនោះ ការអនុវត្តដោយបង្ខំនឹងត្រូវបានផ្អាកហើយការចាត់ចែងការអនុវត្តដែលបានធ្វើរួចហើយក៏ត្រូវបានលុបចោល ដូចដែលបានចែងនៅក្នុង**មាត្រា ៣៧០ កថាខណ្ឌទី១ ចំណុច ខ** បានចែងថាៈ ឯកសារចម្លងយថា ភូតនៃសេចក្តីសម្រេចដែលបានកំណត់ថា មិនអនុញ្ញាតអោយអនុវត្តដោយបង្ខំ។

ដោយឡែកពុំមានសេចក្តីថាឲ្យតែដាក់ពាក្យបណ្តឹង ឬពាក្យសុំទាំងអស់នោះ ជាធម្មតានីតិវិធីនៃការអនុវត្តដោយបង្ខំនឹងត្រូវបានផ្អាកនោះទេ។ ដើម្បីផ្អាកនីតិវិធីមួយរយៈរហូតដល់ចេញលទ្ធផល ក្រៅពីដាក់ពាក្យបណ្តឹង ឬពាក្យសុំតវ៉ា ចាំបាច់ត្រូវធ្វើពាក្យសុំផ្អាកការអនុវត្តចំពោះតុលាការទទួលបណ្តឹងទៀត[៩]។ ក្នុងករណីដែលមានពាក្យបណ្តឹងតវ៉ាចំពោះការទាមទារ ពាក្យបណ្តឹងតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត ឬពាក្យបណ្តឹងតវ៉ាចំពោះតតិយជន បើមានសេចក្តីបញ្ជាក់ដំបូងអំពីមូលហេតុតវ៉ាដែលត្រូវបានអះអាងនោះ តុលាការដែលបានទទួលពាក្យបណ្តឹង អាចបង្គាប់ឲ្យផ្អាកការអនុវត្តដោយបង្ខំមួយតាមរយៈពាក្យសុំ ដោយឲ្យដាក់ប្រាតិភោគ ឬមិនឲ្យដាក់ប្រាតិភោគនោះរហូតដល់ធ្វើការសម្រេចសេចក្តីដែលបានកំណត់នៅក្នុង**កថាខណ្ឌទី១ នៃមាត្រា៣៦៨ ការសម្រេចសេចក្តីផ្អាកការអនុវត្តនៅក្នុងសាលក្រម ឬសាលដីកាចុងក្រោយជាអាទិ៍** នៃក្រមនីតិវិធីរដ្ឋប្បវេណី នៅក្នុងសាលក្រមចុងក្រោយ[១០]។

ទោះបីជាក្នុងករណីនេះក៏ដោយ ការដែលបង្គាប់ឲ្យផ្អាកការអនុវត្ត គឺជាការវិនិច្ឆ័យបដិសេធនូវអានុភាពនៃសាលក្រម ឬសាលដីកាស្ថាពរដែលនេះជាករណីលើកលែង ពុំមែនដាច់ខាតត្រូវតែបង្គាប់ឲ្យ ផ្អាកនោះឡើយ ក្នុងនាមជាតុលាការត្រូវធ្វើការវិនិច្ឆ័យដោយយកចិត្តទុកដាក់ជាទីបំផុត។ ប៉ុន្តែប្រសិនបើការតវ៉ានេះមានមូលហេតុត្រឹមត្រូវនោះ នៅក្នុងសេចក្តីសម្រេចបញ្ចប់នឹងត្រូវបានបង្ហាញថាៈ មិនអនុញ្ញាតការអនុវត្តដោយបង្ខំដែលផ្អែកលើលិខិតអនុវត្តដែលត្រូវបានភ្ជាប់ជាមួយរូបមន្តអនុវត្ត នោះទេ។

ទោះជាយ៉ាងណាក៏ដោយ ក៏អាចនឹងមានកូនបំណុលដែលមានគោលបំណងទុច្ចរិតក្នុងការអនុវត្តកាតព្វកិច្ចរបស់ខ្លួន ដែលធ្វើការដាក់ពាក្យបណ្តឹងដោយគ្មានមូលហេតុ ហើយថែមទាំងដាក់ពាក្យសុំធ្វើការផ្អាកការអនុវត្តដោយមានបំណងដើម្បីតែរួចផុតពីការអនុវត្តដោយបង្ខំតែប៉ុណ្ណោះ។ បណ្តឹងប្រភេទនេះគឺជាការប្រើប្រាស់សិទ្ធិខុស ដែលចាកឆ្ងាយពីគោលគំនិតប្រព័ន្ធច្បាប់ ហេតុដូចនេះពុំ

---

[៩] មាត្រា៣៦៩ និងមាត្រា ៣៧០ កថាខណ្ឌទី២ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

[១០] មាត្រា៣៦៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

មានអ្វីដែលត្រូវ ទទួលស្គាល់ក្នុងការផ្អាកការអនុវត្តដោយបង្ខំនោះទេ។

## ៤. សោហ៊ុយសម្រាប់ការអនុវត្ត និងការមើលសំណុំរឿងនៃការអនុវត្ត

**សោហ៊ុយសម្រាប់ការអនុវត្ត**[១១] សំដៅទៅលើពន្ធដាក់ពាក្យសុំដែលមានចែងក្នុងមាត្រា ៣៧២ នៃក្រមនីតិវិធីរដ្ឋប្បវេណី សោហ៊ុយដែលបានដាក់ពាក្យសុំដែលមានចែងក្នុងមាត្រា ៣៧៣ នៃក្រមដដែល និងសោហ៊ុយដែលមានចែងក្នុងមាត្រា ៣៧៤ ហៅថាសោហ៊ុយភាគី ក្នុងក្រមដដែល។ រីឯ **សោហ៊ុយសម្រាប់នីតិវិធី** គឺសំដៅដល់សោយហ៊ុយសម្រាប់ផលប្រយោជន៍រួមក្នុងចំណោមសោហ៊ុយដែលមានចែងក្នុងចំណុច **ក** នៃមាត្រា ៣៧១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**ពន្ធដាក់ពាក្យសុំ៖** ក្នុងករណីដែលបានដាក់ពាក្យសុំទៅតុលាការអនុវត្ត ម្ចាស់បំណុលនៃការអនុវត្តត្រូវបង់ពន្ធចំនួនដូចគ្នាដោយពុំគិតអំពីពាក្យសុំឲ្យអនុវត្ត ចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ ឬចំពោះសិទ្ធិលើបំណុលដែលមិនមានគោលបំណងសងជាប្រាក់ ហើយពុំគិតការបង្ខំដោយផ្ទាល់ ការអនុវត្តជំនួស ឬការបង្ខំដោយប្រយោលនោះទេ។ ក្រៅពីនេះទៅទៀត ចំពោះការដាក់ពាក្យសុំឲ្យទៅអាជ្ញាសាលា ម្ចាស់បំណុលនៃការអនុវត្តក៏មានកាតព្វកិច្ចត្រូវបង់ពន្ធតាមបញ្ញត្តិនៃច្បាប់ផ្សេងទៀត[១២]។

**សោយហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ** គឺម្ចាស់បំណុលនៃការអនុវត្តត្រូវបង់នូវចំនួនទឹកប្រាក់ដែលកំណត់ដោយតុលាការ ជាសោហ៊ុយចាំបាច់ក្នុងការបញ្ជូនឯកសារ ឬធ្វើសកម្មភាពផ្សេងទៀតដើម្បីនីតិវិធីក្នុងការអនុវត្តដោយបង្ខំ[១៣]។

ក្រៅពីសោហ៊ុយទាំងពីរខាងលើ សោហ៊ុយដែលទទួលស្គាល់ថាជាការចាំបាច់ក្នុងការអនុវត្តនោះ ត្រូវចាត់ទុកថាសោហ៊ុយភាគី។ នៅពេលដែលដាក់ពាក្យសុំទៅតុលាការ អ្នកដាក់ពាក្យសុំត្រូវបង់ជាមុននូវចំនួនទឹកប្រាក់ដែលតុលាការអនុវត្តកំណត់ថាជាសោហ៊ុយចាំបាច់ដើម្បីធ្វើនីតិវិធីនៃការអនុវត្តដោយបង្ខំ។ ហើយក្នុងករណីដែលសោហ៊ុយត្រូវបានបង់ខ្វះនោះ គឺតុលាការបង្គាប់ឲ្យបង់នូវសោហ៊ុយដែលខ្វះខាតនោះជាមុន។ ប្រសិនបើភាគីដាក់ពាក្យសុំមិនព្រមបង់ប្រាក់ទេ តុលាការអាចលើកចោលនូវពាក្យសុំអនុវត្តដោយបង្ខំ ឬលុបចោលនូវនីតិវិធីនៃការអនុវត្តដោយបង្ខំនោះបាន។ រីឯដីកាសម្រេចលើកចោលនីតិវិធីនៃការអនុវត្តវិញ គឺអាចប្ដឹងជំទាស់បាន[១៤]។ សោហ៊ុយសម្រាប់ការអនុវត្តជាបន្ទុករបស់កូនបំណុល[១៥]។

---

[១១] មាត្រា៣៧១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

[១២] មាត្រា៣៧២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

[១៣] មាត្រា៣៧៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

[១៤] មាត្រា៣៧៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

[១៥] មាត្រា៣៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

ក្នុងការមើលសំណុំរឿងនៃរឿងក្តីអនុវត្តដោយបង្ខំ គឺជនដែលបានធ្វើសេចក្តីបញ្ជាក់ដំបូងអំពីការពាក់ព័ន្ធនឹងផលប្រយោជន៍ចំពោះការអនុវត្តដោយបង្ខំដែលធ្វើឡើងដោយតុលាការអនុវត្ត អាចទាមទារ មើលសំណុំរឿង ថតចម្លងសំណុំរឿង ឲ្យប្រគល់ឯកសារថតចម្លងយថាភូត ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ ឬឯកសារដកស្រង់នៃសំណុំរឿង ឬអាចទាមទារឲ្យប្រគល់លិខិតបញ្ជាក់ជាដើម អំពីចំណុចដែលពាក់ព័ន្ធដោយតាមរយៈការបង់ពន្ធ។

## ផ្នែកទី២៖ ប្រភេទនៃការអនុវត្តដោយបង្ខំលើអចលនវត្ថុ

ការអនុវត្តដោយបង្ខំមានបួនប្រភេទសំខាន់ៗគឺ ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ការអនុវត្តដោយបង្ខំចំពោះនាវា និងការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល។

### ១. ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ

កម្មវត្ថុនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុមានគោលបំណងអោយសងជាប្រាក់ គឺអចលនវត្ថុ។ អចលនវត្ថុគឺសំដៅលើ ដី អាគារដែលត្រូវបានចុះបញ្ជី ចំណែកនៃកម្មសិទ្ធិអវិ ភាគលើដី ឬអាគារនោះ សិទ្ធិជួលអចិន្ត្រៃយ៍ និងផលុបភោគដែលត្រូវបានចុះបញ្ជី និងចំណែកនៃសិទ្ធិទាំងនោះ គឺជាសិទ្ធិរួម។ ជាទូទៅវត្ថុដែលនៅជាប់នឹងដី ឬវត្ថុ ដែលអាចក្លាយជាភាគមួយនៃដី ជាពិសេស អាគារ សំណង់ដែលសង់នៅលើដី ហើយមិនអាចប្តូរទីតាំងបាន ឬពូជដែលសាបនៅលើដីដំណាំដែលបានដាំរុក្ខជាតិដែលរបស់នៅលើដី គឺជាសមាសភាគដី លុះត្រាតែមិនអាចបំបែកបានចេញពីដីទេ ហើយមិនអាចក្លាយជាកម្មវត្ថុនៃសិទ្ធិឯករាជ្យបាន លើកលែងតែមានបញ្ញត្តិផ្សេង។ ចំពោះការចាត់ទុកអាគារ គឺជាអចលនវត្ថុឯករាជ្យនៃដី ឬមិនមែនជាអចលនវត្ថុឯករាជ្យ គឺអាស្រ័យទៅលើគោលនយោបាយនីតិកម្មរបស់ប្រទេសផ្សេងៗគ្នា។ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាចែងថា: អាគារគឺជាសមាសភាគនៃដី ពោលគឺអាគារមិនអាចក្លាយជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំចំពោះ អចលនវត្ថុដែលមានលក្ខណ:ជាអចលនវត្ថុឯករាជ្យបានឡើយ[១៦]។

ប៉ុន្តែមានករណីដែលអាចចុះបញ្ជីអាគារជាកម្មវត្ថុនៃកម្មសិទ្ធិដោយឯករាជ្យបានដែរដោយសារមានកាលៈទេសៈពិសេសដែលថា: ដីមិនមែនជាកម្មវត្ថុនៃកម្មសិទ្ធិតាមច្បាប់រដ្ឋប្បវេណីទេ នៅក្នុងតំបន់មួយចំនួននៃព្រះរាជាណាចក្រកម្ពុជា ដូចជារាជធានីភ្នំពេញ។ ក្នុងករណីបែបនេះហើយទើបអាគារដែលត្រូវបានចុះបញ្ជីក៏អាចក្លាយជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំបានដែរ។ រីឯអាគារ ដែលមិនបាន

ចុះបញ្ជីនោះ គឺជាសមាសភាគនៃកម្មសិទ្ធិលើដី ឬសមាសភាគនៃសិទ្ធិប្រត្យក្សប្រើប្រាស់ដីគឺជួល អចិន្ត្រៃយ៍ និងផលុបភោគ ដែលមិនអាចក្លាយជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំចំពោះអចលន

[១៦] មាត្រា១២២ នៃក្រមរដ្ឋប្បវេណី ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៧

វត្ថុដោយ ឯករាជ្យបាន។ ដោយសារថាអានុភាពនៃការអនុវត្តដោយបង្ខំចំពោះកម្មសិទ្ធិលើដី ឬចំពោះសិទ្ធិប្រត្យក្សប្រើប្រាស់ដីមាននៅលើ អាគារដែលជាសមាសភាគនៃសិទ្ធិនោះដែរ អាគារទាំងនោះនឹងត្រូវបានលក់ដោយបង្ខំជាមួយនឹងកម្មសិទ្ធិលើដី ឬសិទ្ធិប្រត្យក្សប្រើប្រាស់នៃដី[១៧]។

ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ គឺជានីតិវិធីដែលមានលក្ខណៈស្មុគស្មាញជាងគេ។ ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ សំដៅទៅលើការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោលបំណងឲ្យប្រគល់ការគ្រប់គ្រងលើទីកន្លែង ឬទីទំនេរណាមួយឲ្យទៅម្ចាស់បំណុលនៃការអនុវត្ត ឬតតិយជន។

ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ មានដូចជា៖ ដី ចំណែកនៃសហកម្មសិទ្ធិលើដី សិទ្ធិជួលអចិន្ត្រៃយ៍ និងផលុបភោគដែលត្រូវបានចុះបញ្ជី ព្រមទាំងចំណែកនៃសិទ្ធិទាំងនេះ។ អាគារជាសមាសភាគនៃកម្មសិទ្ធិលើដី ឬសមាសភាគនៃសិទ្ធិប្រត្យក្សដែលជាសិទ្ធិប្រើប្រាស់នៃដី ហេតុដូចនេះ ពុំអាចក្លាយជាកម្មវត្ថុ នៃការអនុវត្តដោយបង្ខំដោយឯកឯងបានទេ។ អានុភាពនៃការអនុវត្តដោយបង្ខំ ដែលយកកម្មសិទ្ធិលើដី ឬសិទ្ធិប្រត្យក្សដែលជាសិទ្ធិប្រើប្រាស់ដី ជាកម្មវត្ថុមានទៅលើអាគារដែលជាសមាសភាគនៃសិទ្ធិទាំងនេះ បើអាគារត្រូវបានលក់ដោយបង្ខំជាមួយនឹងសិទ្ធិប្រើប្រាស់ដីដែរ[១៨]។

ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុនេះត្រូវធ្វើឡើងដោយវិធីលក់ដោយបង្ខំ ពោលគឺតុលាការអនុវត្តរឹបអូសអចលនវត្ថុរបស់កូនបំណុលនៃការអនុវត្ត រួចលក់អចលនវត្ថុនោះដោយបង្ខំ ហើយយកប្រាក់ដែលបានពីការលក់ទៅសងម្ចាស់បំណុល។ ការលក់ដោយបង្ខំត្រូវចាប់ផ្តើមដោយដីកាសម្រេច ចាប់ផ្តើមការលក់ដោយបង្ខំដែលតុលាការអនុវត្តចេញតាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត និងប្រកាសអំពីការរឹបអូស[១៩]។ នៅពេលដែលដីកាសម្រេចត្រូវបានចេញ ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ឲ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីអំពីការរឹបអូសដែលពាក់ព័ន្ធនឹងដីកាសម្រេចចាប់ផ្តើមនោះ ដែលគេហៅថា: ការចុះបញ្ជីអំពីការរឹបអូស។

ក្រោយពីការរឹបអូស តុលាការអនុវត្តនឹងលក់អចលនវត្ថុដែលត្រូវបានរឹបអូស ហើយមុននឹងលក់ តុលាការត្រូវកំណត់តម្លៃលក់អប្បបរមាដោយផ្អែកលើការវាយតម្លៃ[20]។ ក្នុងករណីដែលយល់ឃើញថាតម្លៃលក់អតិប្បបរមានៃអចលនវត្ថុក្រោយពីបានសងសោហ៊ុយសម្រាប់នីតិវិធី គ្មានលទ្ធ

---

[១៧] មាត្រា៥២១ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

[១៨] មាត្រា៥១៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

[១៩] មាត្រា៥១៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

[២០] មាត្រា៥៣២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

ភាពសេសសល់ទេ តុលាការអនុវត្តត្រូវជូនដំណឹងអំពីការនោះទៅម្ចាស់បំណុលនៃការអនុវត្ត ហើយជាគោលការណ៍ នីតិវិធីលក់ដោយបង្ខំត្រូវបានលុបចោលដោយមិនរង់ចាំកាលបរិច្ឆេទនៃការលក់ទេ។ ផ្ទុយមកវិញក្នុងអំឡុងពេលមួយសប្តាហ៍ គិតចាប់ពីថ្ងៃដែលម្ចាស់បំណុលបានទទួលដំណឹង ម្ចាស់បំណុលនៃការអនុវត្តបានស្នើសុំទិញដោយខ្លួនឯង ក្នុងតម្លៃដែលលើសពីការប៉ាន់ប្រមាណ ហើយដាក់ប្រាក់ធានាដែលមានតម្លៃស្មើនឹងការស្នើសុំនោះ ដោយនីតិវិធីលក់ដោយបង្ខំនៅតែបន្តដដែល[២១]។

## ២. ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ

ចលនវត្ថុតាមក្រមរដ្ឋប្បវេណី សំដៅទៅលើវត្ថុក្រៅពីអចលនវត្ថុទាំងឡាយដែលរួមមានដូចជា៖ រូបិយវត្ថុ និងផលធម្មជាតិដែលមិនទាន់បំបែកពីដីនៅឡើយ ហើយអាចទទួលបានផលយ៉ាងច្បាស់នៅក្នុងអំឡុងពេល០១ (មួយ) ខែ[២២]។ ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុត្រូវធ្វើឡើង តាមការរឹបអូសយកវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្តដោយអាជ្ញាសាលា។ ប៉ុន្តែនៅក្នុងករណីដែលចលនវត្ថុនោះត្រូវបានកាន់កាប់ដោយតតិយជន អាជ្ញាសាលាអាចរឹបអូសបានលុះត្រាតែតតិយជននោះមិនបដិសេធក្នុងការប្រគល់។

ជាគោលការណ៍ ការរឹបអូសចលនវត្ថុអាចធ្វើបានតែចំពោះទ្រព្យរូបិយ ឬទ្រព្យអរូបិយទាំងឡាយដែលធ្លាក់ទៅលើកូនបំណុលតែប៉ុណ្ណោះ មានន័យថាទ្រព្យសម្បត្តិទាំងអស់របស់កូនបំណុលនៃការអនុវត្ត អាចក្លាយជាកម្មវត្ថុនៃការរឹបអូសបានតែក្នុងករណីដែលមានមូលហេតុពាក់ព័ន្ធ។ ទោះជាយ៉ាងនេះក្តី មានទ្រព្យសម្បត្តិមួយចំនួនដែលច្បាប់បានហាមឃាត់មិនឲ្យរឹបអូស មានដូចខាងក្រោម[២៣]៖

- សំលៀកបំពាក់ សំភារៈដំណេក តុ ទូ សំភារៈសម្រាប់ដាំស្ល និងសំភារៈសំរាប់ឃាំងនៅបន្ទប់របស់កូនបំណុលនៃកាអនុវត្ត និងញាតិដែលរស់នៅជាមួយកូនបំណុលនៃការអនុវត្ត ហើយមានជីវភាពរួមគ្នាជាដើម។
- គ្រឿងបរិភោគ និងទបានវត្ថុដែលត្រូវការចាំបាច់ដើម្បីចិញ្ចឹមជីវិតក្នុងអំឡុងពេល០២ (ពីរ) ខែរបស់កូនបំណុលនៃការអនុវត្ត និងញាតិដែលរស់នៅជាមួយកូនបំណុលនៃការអនុវត្តមានជីវភាពរួម។
- របបឧបត្ថមផ្នែកជីវភាព របបឧបត្ថមផ្នែកអប់រំ របបឧបត្ថមផ្នែកសុខភាព និងប្រាក់ ឬវត្ថុឧបត្ថមផ្សេងទៀតដែលផ្តល់ពីរដ្ឋ ឬអាជ្ញាធរដែនដីដើម្បីការពារដល់ជីវភាពរស់នៅរបស់កូនបំណុលនៃ

[២១] មាត្រា៨៣៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

[២២] មាត្រា៣៨៤ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

[២៣] មាត្រា៣៨០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

ការអនុវត្ត។

• ផ្នែកប្រាក់តិចជាង ឬស្មើនឹង ១ ០០០ ០០០ (មួយលាន) រៀល ក្រៅពីប្រាក់ដែលបានកំណត់នៅក្នុងចំណុចខាងលើនេះ។

• ឧបករណ៍ ដី សត្វពាហនៈដែលជាចាំបាច់សម្រាប់ការងារកសិកម្មរបស់ខ្លួន និងចំណីសត្វទាំងនេះព្រមទាំងគ្រាប់ពូជ ឬកសិផលដែលមានប្រភេទដូចគ្នា ដែលត្រូវការចំបាច់សម្រាប់បន្តការងារកសិកម្ម រហូតដល់រដូវបានផលបន្ទាប់របស់កសិករក្នុងការប្រកបកសិកម្ម។

• មង សំណាញ់ ឬនេសាទុបករណ៍ផ្សេងៗចំបាច់ ចំណី និងកូនត្រី ឬជលផលប្រភេទដូចគ្នាដែលត្រូវការចាំបាច់សម្រាប់រកជលផល ឬចិញ្ចឹមជលផលរបស់អ្នកប្រកបរបរនេសាទ។

• ឧបករណ៍ និងវត្ថុផ្សេងៗដែលចាំបាច់សម្រាប់អ្នកបច្ចេកទេស សិប្បករ កម្មករ និងអ្នកផ្សេងទៀត ដែលប្រកបវិជ្ជាជីវៈ ឬអាជីវកម្ម ដោយប្រើកំលាំងប្រាជ្ញា និងកម្លាំងកាយ។ ប៉ុន្តែបើជាវត្ថុដែលអ្នកនោះមានក្នុងគោលបំណងសម្រាប់លក់ ឬជួលវិញអាចរឹបអូសបាន។

• ព្រះពុទ្ធរូប ក្បួនវិន័យសាសនា និងវត្ថុផ្សេងៗដែលចំបាច់សម្រាប់ពិធីក្នុងសាសនា។

• ពង្សាវលី កំណត់ប្រចាំថ្ងៃ បញ្ជីប្រកបមុខរបរ និងឯកសារប្រភេទដូចគ្នាដែលចាំបាច់របស់កូនបំណុលនៃការអនុវត្ត។

• គ្រឿងឥស្សរិយស និងប័ណ្ណសរសើរផ្សេងទៀតរបស់កូនបំណុលនៃការអនុវត្ត ឬរបស់ញាតិរបស់ជននោះ។

• ឯកសារ និងឧបករណ៍ដែលចាំបាច់ក្នុងការសិក្សានៅសាលារៀន ឬនៅស្ថាប័នអប់រំផ្សេងទៀតរបស់កូនបំណុលនៃការអនុវត្ត និងញាតិដែលរស់នៅជាមួយកូនបំណុលនៃការអនុវត្តហើយមានជីវភាព រួមគ្នា។

• វត្ថុដែលទាក់ទងទៅនឹងតក្កកម្ម ឬស្នាដៃនិពន្ធដែលមិនទាន់បានផ្សាយជាសាធារណៈ។

• អវយវៈសិប្បនិមិត្ត សរីរាង្គសប្បនិមិត្តផ្សេងទៀត និងឧបករណ៍ជំនួយខ្លួនប្រាណផ្សេងទៀតដែលចាំបាច់របស់កូនបំណុលនៃការអនុវត្ត និងញាតិដែលរស់នៅជាមួយកូនបំណុលនៃការអនុវត្តហើយមានជីវភាពរួមគ្នាព្រមទាំងវត្ថុផ្សេងៗសម្រាប់ថែទាំអ្នកជម្ងឺ ដែលជាកូនបំណុលនៃការអនុវត្ត និងញាតិដែលរស់នៅជាមួយកូនបំណុលនៃការអនុវត្តហើយមានជីវភាពរួមគ្នា។

• ម៉ាស៊ីន ឬឧបករណ៍ពន្លត់ភ្លើង ឧបករណ៍ជម្លៀសខ្លួនពេលមានអាសន្ន ឬឧបករណ៍ផ្សេងទៀតសម្រាប់អាគារ ឬសំណង់ផ្សេងទៀតដែលច្បាប់ ឬបទដ្ឋានគតិយុត្តផ្សេងៗតម្រូវឲ្យមានបរិក្ខាដើម្បីបង្ការមហន្តរាយ និងការពារសន្តិសុខ។

### ៣. ការអនុវត្តដោយបង្ខំចំពោះនាវា

នាវាសំដៅទៅលើជលយានដែលមានចំណុះសរុបជាតោនស្មើនឹង និងលើសពី២០តោន និងជលយានដែលមានចំណុះសរុបជាតោនក្រោម២០តោន ហើយដែលបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា[២៤]។ ចំពោះជលយានដែលមានចំណុះសរុបជាតោនស្មើនឹង និងលើសពី២០តោននោះ ទោះបីជាមិនបានចុះបញ្ជីក៏ដោយ ក៏ចាត់ទុកជានាវាក្នុងន័យក្រមរដ្ឋប្បវេណីដែរ។

នាវាដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំចំពោះនាវានៅទីនោះ សំដៅទៅលើនាវាដែលមានរចនាសម្ព័ន្ធជាក់លាក់មួយ និងមានសមត្ថភាពអាចធ្វើដំណើរតាមផ្លូវទឹកដើម្បីដឹកអ្នកដំណើរ ឬវត្ថុផ្សេងបាន។

ក្នុងការអនុវត្តដោយបង្ខំចំពោះនាវា ត្រូវធ្វើឡើងដោយតុលាការអនុវត្តតាមរយៈវិធីលក់ដោយបង្ខំ ហើយតុលាការអនុវត្តដែលមានសមត្ថកិច្ចលើការអនុវត្តដោយបង្ខំចំពោះនាវា គឺសាលាដំបូងនៃទីកន្លែងដែលនាវាស្ថិតនៅជាអ្នកមានសមត្ថកិច្ច នៅពេលចេញដីកាសម្រេចចាប់ផ្ដើមលក់ដោយបង្ខំ។

### ៤. ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល

ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល គឺជាការអនុវត្តដោយបង្ខំដើម្បីសម្រេចបាននូវសិទ្ធិទាមទារដែលមានគោលបំណងឲ្យសងជាប្រាក់របស់ម្ចាស់បំណុល ឬប្រគល់ចលនវត្ថុ ហៅថាការអនុវត្តសិទ្ធិលើបំណុល តាមរយៈការរឹបអូសសិទ្ធិលើបំណុលដែលមានកម្មវត្ថុជាការសងប្រាក់ ប៉ុន្តែប្រសិនបើតតិយជនដែលកាន់កាប់ចលនវត្ថុរបស់កូនបំណុលនៃការអនុវត្តមិនព្រមប្រគល់ចលនវត្ថុនោះ ការអនុវត្តដោយបង្ខំត្រូវបានធ្វើដោយមិនអាចធ្វើតាមការអនុវត្តចំពោះចលនវត្ថុទេ គឺត្រូវធ្វើតាមការអនុវត្តចំពោះសិទ្ធិលើបំណុល[២៥]។

កូនបំណុលនៃសិទ្ធិលើបំណុលដែលត្រូវរឹបអូសហៅថា: កូនបំណុលទី៣។ តុលាការអនុវត្តមានសមត្ថកិច្ចធ្វើការអនុវត្តចំពោះសិទ្ធិលើបំណុល ត្រូវកំណត់តាមលំនៅឋានរបស់កូនបំណុលនៃការអនុវត្ត[២៦]។ ក្នុងករណីដែលកូនបំណុលនៃការអនុវត្តគ្មានលំនៅឋាននៅក្នុងប្រទេសកម្ពុជាទេ គឺត្រូវយកលំនៅឋានទី៣ដើម្បីកំណត់ជាមូលដ្ឋាន។

---

[២៤] មាត្រា៨៥៨ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦

[២៥] មាត្រា៨០២ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦

[២៦] មាត្រា៨ នៃក្រមរដ្ឋប្បវេណី ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

# ជំពូកទី ២

## លំហូរនៃនីតិវិធីអនុវត្តដោយបង្ខំ
## ចំពោះអចលនវត្ថុ

# ជំពូកទី២
# លំហូរនៃនីតិវិធីអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ

## ផ្នែកទី១៖ ការដាក់ពាក្យសុំ និងទីកន្លែងដាក់ពាក្យសុំអនុវត្ត

ការដាក់ពាក្យសុំអនុវត្តចំពោះអចលនវត្ថុ ត្រូវដាក់ឯកសារដែលហៅថា: ពាក្យសុំលក់ដោយបង្ខំចំពោះអចលនវត្ថុ។

ការដាក់ពាក្យសុំអនុវត្តដោយបង្ខំ ត្រូវធ្វើឡើងដោយការដាក់ពាក្យសុំឲ្យអនុវត្តដោយម្ចាស់បំណុលដែលត្រូវធ្វើឡើងដោយលាយលក្ខណ៍អក្សរទៅស្ថាប័នអនុវត្តដែលមានសមត្ថកិច្ចគឺតុលាការអនុវត្ត ឬអាជ្ញាសាលា។ នៅក្នុងពាក្យសុំអនុវត្តត្រូវមានបញ្ជាក់អំពីចំណុចសំខាន់ៗដូចខាងក្រោម ហើយ ត្រូវភ្ជាប់ជាមួយនឹងលិខិតចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត៖

• ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្តហើយនឹងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់

• សញ្ញាណនៃលិខិតអនុវត្ត

• សេចក្តីសុំឲ្យអនុវត្តតាមការបង្ខំដោយផ្ទាល់ ឬការអនុវត្តជំនួស ឬវិធានបង្ខំដោយប្រយោល

• សញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ និងវិធីអនុវត្តដោយបង្ខំដែលម្ចាស់បំណុលនៃការអនុវត្តសុំក្នុងករណីដែលសុំឲ្យអនុវត្តតាមការបង្ខំដោយផ្ទាល់

• ខ្លឹមសារដែលម្ចាស់បំណុលសុំ ក្នុងករណីដែលសុំឲ្យអនុវត្តដោយបង្ខំតាមការអនុវត្តជំនួស ឬវិធានបង្ខំដោយប្រយោល

ជាងនេះទៅទៀត ករណីខ្លះទាមទារឲ្យម្ចាស់បំណុលនៃការអនុវត្តត្រូវសរសេរបញ្ជាក់អំពីសេចក្តីសុំ និងទំហំនៃសេចក្តីសុំនោះក្នុងពាក្យសុំអនុវត្តដោយបង្ខំ[២៧]។

ដើម្បីធ្វើការអនុវត្តដោយបង្ខំបាន ជាការចាំបាច់ត្រូវភ្ជាប់មកនូវឯកសារសំខាន់ៗមកជាមួយដើម្បីជាសក្ខីភាពដើម្បីបង្ហាញទៅបុគ្គល ឬភាគីដែលពាក់ព័ន្ធអំពីសិទ្ធិរបស់ខ្លួន។ ឯកសារចាំបាច់ក្នុងការដាក់ពាក្យសុំអនុវត្តដោយបង្ខំ គឺមានដូចជា៖

### ១. លិខិតអនុវត្ត

ដោយសារតែការបំបែកស្ថាប័នវិនិច្ឆ័យ និងស្ថាប័នអនុវត្តដាច់ពីគ្នា ដូចនេះស្ថាប័នអនុវត្តមិនធ្វើការវិនិច្ឆ័យទេអំពីអត្ថិភាពនៃសិទ្ធិទាមទារ។ ក្នុងករណីដែលមានឯកសារបញ្ជាក់ពីអត្ថិភាពនៃសិទ្ធិដែលធ្វើឡើងដោយស្ថាប័នវិនិច្ឆ័យត្រូវបានដាក់មក នោះការអនុវត្តដោយបង្ខំនឹងចាប់ផ្តើមឡើងដោយលក្ខណៈទម្រង់បែបបទ។ ការអនុវត្តដោយបង្ខំត្រូវធ្វើឡើងដោយផ្អែកលើលិខិតអនុវត្តដែល

[២៧] មាត្រា៣៤៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦

លិខិតអនុវត្ត គឺជាប្រភេទលិខិតដែលបានកំណត់អំពីៈ

• សាលក្រម ឬសាលដីកាបង្គាប់ឲ្យផ្តល់តាវកាលិកដែលបានចូលជាស្ថាពរ។

• សាលក្រម ឬសាលដីកាបង្គាប់ឲ្យផ្តល់តាវកាលិកដែលភ្ជាប់ជាមួយនឹងការប្រកាសឲ្យអនុវត្តបណ្តោះអាសន្ន។

• ដីកាសម្រេចបង្គាប់ឲ្យផ្តល់តាវកាលិក។ ប៉ុន្តែចំពោះដីកាសម្រេចដែលមិនត្រូវមានអានុភាពបើមិនទាន់ចូលជាស្ថាពរវិញ មានកម្រិតតែដីកាសម្រេចនោះបានចូលជាស្ថាពរហើយ។

• ដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន។

• ការចាត់ចែងរបស់ក្រឡាបញ្ជីដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ នៃមាត្រា៦៦ (នីតិវិធីដើម្បីកំណត់ជាស្ថាពរនូវចំនួនប្រាក់ប្រដាប់ក្តី) នៃក្រមនេះ។

• លិខិតយថាភូតដែលធ្វើដោយសារការី ចំពោះការទាមទារដែលមានគោលបំណងឲ្យសងជាប្រាក់មានកំណត់។ ប៉ុន្តែមានកម្រិតតែលិខិតដែលបញ្ជាក់សេចក្តីថ្លែងការណ៍ថាៈ កូនបំណុលនឹងទទួលការអនុវត្តដោយបង្ខំភ្លាមៗ។

• សាលក្រម ឬសាលដីការបស់តុលាការបរទេសដែលមានសាលក្រមអនុវត្ត ដែលបានចូលជាស្ថាពរ តាមបញ្ញត្តិនៃមាត្រា ៣៥២ (សាលក្រមអនុវត្តសាលក្រម ឬសាលដីការបស់តុលាការបរទេស) នៃក្រមនេះ។

• សេចក្តីសម្រេចមជ្ឈត្តករ ដែលមានដីកាសម្រេចអនុវត្តដែលបានចូលជាស្ថាពរតាមបញ្ញត្តិនៃមាត្រា ៣៥៣ (ដីកាសម្រេចអនុវត្តសេចក្តីសម្រេចមជ្ឈត្តករ) នៃក្រមនេះ។

• កំណត់ហេតុដែលបានកំណត់នៅក្នុងមាត្រា ២២២ (អានុភាពនៃកំណត់ហេតុស្តីពីការសះជា ជាអាទិ៍) នៃក្រមនេះ និង កំណត់ហេតុផ្សេងទៀតដែលមានអានុភាពដូចសាលក្រម ឬសាលដីកាដែលបានចូលជាស្ថាពរ[២៨]។

## ២. លិខិតដែលបានបញ្ជាក់ពីការបានបញ្ជូនលិខិតអនុវត្ត

លិខិតបញ្ជាក់ពីការបានបញ្ជូន គឺបញ្ជាក់ពីការដែលបានបញ្ជូនលិខិតរួចហើយ។ លិខិតអនុវត្តត្រូវបានបញ្ជូនទៅកូនបំណុលនៃការអនុវត្តជាមុន[២៩] ។ កត្តាចាំបាច់ដែលត្រូវធ្វើការបញ្ជូនលិខិតអនុវត្តទៅកូនបំណុលនៃការអនុវត្តជាមុន គឺដើម្បីជូនដំណឹងទៅកូនបំណុលនៃការអនុវត្តថា នីតិវិធីនៃការអនុវត្តនឹងចាប់ផ្តើមចំពោះសិទ្ធិលើបំណុលណាមួយក្នុងគោលបំណងផ្តល់ឱកាសការពារខ្លួនដល់កូនបំណុលនៃការអនុវត្ត។

[២៨] មាត្រា៣៥០ នៃក្រមនីតិវិធីក្រមរដ្ឋប្បវេណី ចុះថ្ងៃទីចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦

[២៩] មាត្រា៣៦០ នៃក្រមនីតិវិធីក្រមរដ្ឋប្បវេណី ចុះថ្ងៃទីចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦

### ៣. រូបមន្តអនុវត្ត

ការអនុវត្តដោយបង្ខំត្រូវបានធ្វើឡើងដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិត ដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្ត។ ប៉ុន្តែក្នុងករណីដែលយកឯកសារដែលបានកំណត់ដូចខាងក្រោមនេះជាលិខិតអនុវត្ត ការអនុវត្តដោយបង្ខំដោយយកភាគីដែលបានកំណត់ក្នុងលិខិតអនុវត្តនោះធ្វើជាម្ចាស់បំណុលនៃការអនុវត្ត ឬកូនបំណុលនៃការអនុវត្តត្រូវធ្វើឡើងដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តនោះ៖

• សាលក្រមនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិចដែលចូលជាស្ថាពរ។

• សាលក្រមនៃបណ្តឹងរឿងក្តីដែលចំនួនទឹកប្រាក់តិចដែលភ្ជាប់ការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន។

• ដីកាសម្រេចដាស់តឿនដែលភ្ជាក់ការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន។

• ជាគោលការណ៍ រូបមន្តអនុវត្តត្រូវផ្តល់ដោយក្រឡាបញ្ជីនៃតុលាការដែលមានសំណុំរឿងនោះតាមពាក្យសុំ[៣០]។

ភាគីត្រូវសរសេរ ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត ហើយនឹងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។ សរសេរអំពីសញ្ញាណនៃលិខិតអនុវត្តព្រមទាំងហេតុការណ៍ និងមូលហេតុ បើការទាមទារឲ្យផ្តល់រូបមន្តអនុវត្តត្រូវធ្វើឡើងតាមបញ្ញត្តិនៃមាត្រា ៣៥៦ និងកថាខណ្ឌទី១ នៃមាត្រា ៣៥៨នៃក្រមនីតិវិធីរដ្ឋប្បវេណី។

៤. ពាក្យសុំលក់ដោយបង្ខំចំពោះអចលនវត្ថុ

ពាក្យសុំលក់ដោយបង្ខំគឺជាទម្រង់មួយប្រភេទដែលត្រូវបានរៀបចំឡើងក្នុងគោលបំណងដាក់ ពាក្យស្នើរសុំអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ។ ពាក្យសុំអនុវត្តដោយបង្ខំត្រូវបញ្ជាក់ពី[៣១]៖

• ឈ្មោះ ឬនាមករណ៍ និង អាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត ហើយនឹងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។

• សញ្ញាណនៃលិខិតអនុវត្ត។

• សេចក្តីសុំអោយអនុវត្តដោយបង្ខំដោយផ្ទាល់ ឬការអនុវត្តជំនួស ឬវិធានបង្ខំដោយប្រយោល។

• សញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ និងវិធីអនុវត្តដោយបង្ខំដែលម្ចាស់បំណុលនៃការអនុវត្តសុំ ក្នុងករណីដែលសុំឲ្យអនុវត្តតាមការបង្ខំដោយផ្ទាល់។

[៣០] មាត្រា៣៥៤ នៃក្រមនីតិវិធីក្រមរដ្ឋប្បវេណី ចុះថ្ងៃទីចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦

[៣១] មាត្រា៣៤៩ កថាខណ្ឌទី២ នៃក្រមនីតិវិធីក្រមរដ្ឋប្បវេណី ចុះថ្ងៃទីចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦

• ខ្លឹមសារនៃសេចក្តីសម្រេចដែលម្ចាស់បំណុលសុំ ក្នុងករណីដែលសុំឲ្យអនុវត្តដោយបង្ខំតាមការអនុវត្តជំនួស ឬវិធានបង្ខំដោយប្រយោល។

ពាក្យសុំលក់ដោយបង្ខំចំពោះអចលនវត្ថុ ចាំបាច់ត្រូវភ្ជាប់ជាមួយលិខិតដូចខាងក្រោម៖

• លិខិតចម្លងដោយយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត (មាត្រា៣៤៩ កថាខណ្ឌទី២)។

• លិខិតបញ្ជាក់ពីការបញ្ជូនដើម្បីបញ្ជាក់អំពីការបញ្ជូនលិខិតអនុវត្ត (មាត្រា៣៦០)។

• ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុជាអាទិ៍ (មាត្រា៥១៧ នៃ កថាខណ្ឌទី៣ ចំណុច ក និង ខ)។ គឺក្នុងគោលដៅបញ្ជាក់ថាអចលនវត្ថុ គឺជាកម្មសិទ្ធិរបស់កូនបំណុល។

## ផ្នែកទី២៖ ស្ថាប័នអនុវត្ត

### ១. ការបំបែកស្ថាប័នវិនិច្ឆ័យ និងស្ថាប័នអនុវត្ត

ស្ថាប័នវិនិច្ឆ័យ និងស្ថាប័នអនុវត្តជាស្ថាប័នដែលទទួលបន្ទុកដោះស្រាយបណ្តឹង និងជាស្ថាប័នអនុវត្តដែលទទួលបន្ទុកក្នុងការអនុវត្តដោយបង្ខំ។ ស្ថាប័នទាំងពីរនេះគឺជាតុលាការដូចគ្នា តើកត្តាអ្វីបានជាត្រូវបំបែកស្ថាប័នទាំងពីរនេះចេញពីគ្នា?

មូលហេតុមកពីមានការខុសគ្នានៃការវិនិច្ឆ័យអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ទំហំ(បណ្តឹង) និងការសម្រេចនូវសិទ្ធិដែលមានអត្ថិភាព (អនុវត្តដោយបង្ខំ)[៣២]។

#### ១.១. ស្ថាប័នវិនិច្ឆ័យ

ស្ថាប័នវិនិច្ឆ័យគឺធ្វើការតែរឿងទាំងឡាយណាដែលពាក់ព័ន្ធលើការវិនិច្ឆ័យតែប៉ុណ្ណោះ។ ក្នុងករណីវិនិច្ឆ័យអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ និងទំហំតម្រូវអោយធ្វើការវិនិច្ឆ័យដោយហ្មត់ចត់ និងដោយនីតិវិធីប្រិតប្រៀង ដើម្បីជៀសវៀងក្នុងការខ្វះចន្លោះនៅចំណុចណាមួយ។ ដោយឡែកចំពោះករណីដែលធ្វើការសម្រេចនូវសិទ្ធិដែលមានអត្ថិភាព តម្រូវឲ្យមានការចាត់ចែងឆាប់រហ័សសាមញ្ញ។ ដោយមើលឃើញ ពីភាពខុសគ្នាដូចនេះ ទើបគេបំបែកស្ថាប័នទាំងពីរនេះអោយដាច់ពីគ្នា ដែលស្ថាប័នវិនិច្ឆ័យធ្វើការពាក់ព័ន្ធ ការទទួលបន្ទុកបណ្តឹង និងការទទួលបន្ទុកអនុវត្តដោយបង្ខំ។

ក្នុងករណីដែលមានបណ្តឹងតវ៉ាពាក់ព័ន្ធទៅនឹងការទាមទារ ពាក្យបណ្តឹងតវ៉ាពាក់ព័ន្ធទៅនឹងការផ្តល់រូបមន្តអនុវត្ត ឬពាក្យបណ្តឹងតវ៉ារបស់តតិយជន បើសិនជាមានសេចក្តីបញ្ជាក់អំពីមូលហេតុនៃការតវ៉ាដែលត្រូវបានអះអាងនោះ តុលាការដែលទទួលពាក្យបណ្តឹង អាចបង្គាប់អោយផ្អាកការ

---

[៣២]យោងតាមសិក្ខាសាលាស្តីពី ការអនុវត្ត និង នីតិវិធីនៃបណ្តឹងទាក់ទងនឹងរឿងក្តីរដ្ឋប្បវេណី នីតិវិធីអនុវត្តដោយបង្ខំ នាថ្ងៃទី ២០ និង ២១ ខែកុម្ភៈ ឆ្នាំ២០១៧

អនុវត្តដោយបង្ខំមួយរយៈតាមពាក្យសុំ ដោយអោយដាក់ប្រាតិភោគ ឬមិនឲ្យដាក់ប្រាតិភោគបាន រហូតដល់ធ្វើការសម្រេចសេចក្តីដែលបានកំណត់ក្នុងកថាខណ្ឌទី១ នៃមាត្រា ៣៦៨ ក្រមនីតិវិធីរដ្ឋប្បវេណី។ ម្យ៉ាងវិញទៀត ប្រសិនបើតុលាការដែលបានទទួលពាក្យបណ្តឹងអាចបង្គាប់ឲ្យលុបចោលការចាត់ចែងការអនុវត្តដែលបានធ្វើរួចហើយនោះតាមពាក្យសុំ ដោយឲ្យដាក់ប្រាតិភោគ ជាមួយនឹងការបង្គាប់ឲ្យផ្អាកការអនុវត្ត ដោយបង្ខំមួយរយៈបាន។ បើគ្មានពេលគ្រប់គ្រាន់ដើម្បីទទួលការចាត់ចែងផ្អាកការអនុវត្តដោយតុលាការអនុវត្តដែលទទួលពាក្យបណ្តឹងទេ តុលាការអនុវត្ត ឬសាលាដំបូងដែលមានអាជ្ញាសាលាស្ថិតនៅក្រោម អាចបង្គាប់ឲ្យផ្អាកការអនុវត្តជាបណ្តោះអាសន្នបាន។ ដោយហេតុថាមានករណីច្រើនដែលគ្មានពេលគ្រប់ គ្រាន់ដើម្បីឲ្យតុលាការអនុវត្ត ឬសាលាដំបូងអាចផ្អាកការអនុវត្តដោយទទួលការចាត់ចែងផ្អាកការអនុវត្តរបស់តុលា ការទទួលពាក្យបណ្តឹងទេ[៣៣]។

### ១.២. ស្ថាប័នអនុវត្ត

ស្ថាប័នអនុវត្តគឺជាស្ថាប័ន ដែលត្រូវបានផ្តល់សិទ្ធិអំណាចដែលមានបំណងសម្រេចនូវសិទ្ធិដោយប្រើអំណាចបង្ខំនៅក្នុងការអនុវត្តដោយបង្ខំ។

ស្ថាប័ន២ដែលត្រូវបានកំណត់ថាជាស្ថាប័នអនុវត្តគឺៈ តុលាការអនុវត្ត និង អាជ្ញាសាលា[៣៤]។

- តុលាការអនុវត្ត អនុវត្តដោយបង្ខំដោយផ្អែកទៅលើការវិនិច្ឆ័យដោយច្បាប់។

**ឧទាហរណ៍:** ការអនុវត្តចំពោះអចលនវត្ថុ។

- អាជ្ញាសាលា អនុវត្តដោយការធ្វើសកម្មភាពជាក់ស្តែងនៅទីតាំង។

**ឧទាហរណ៍:** ការអនុវត្តចំពោះចលនវត្ថុ[៣៥]។ ការអនុវត្តដោយបង្ខំឲ្យប្រគល់អចលនវត្ថុ /ចលនវត្ថុ[៣៦]។

ស្ថាប័នអនុវត្តត្រូវធ្វើការអនុវត្តដោយបង្ខំត្រូវធ្វើឡើងដោយស្ថាប័នអនុប័នអនុវត្ត តាមពាក្យសុំរបស់ភាគីដែលស្ថាប័ននេះ គឺមានតុលាការអនុវត្ត ឬអាជ្ញាសាលា។ អាជ្ញាសាលា គឺជាស្ថាប័នតុលាការដាច់ដោយឡែកមួយដែលទទួលបន្ទុកការងារអនុវត្តដោយបង្ខំ និងការងារពាក់ព័ន្ធ ហើយដែលមានមន្ត្រីរាជការដែលមានឈ្មោះថាៈ អាជ្ញាសាលា។ អាជ្ញាសាលា គឺជាស្ថាប័នអនុវត្តមួយឯករាជ្យមិនមែនជាស្ថាប័នជំនួយនៃតុលាការអនុវត្តទេ។ ដើម្បីឲ្យមានមូលដ្ឋាននៃមាត្រានេះដែលចែងថាៈ អាជ្ញាសលាជាស្ថាប័នអនុវត្ត យើងត្រូវតាក់តែងច្បាប់ដោយឡែកមួយស្តីពីអាជ្ញាសាលាដែលកំណត់អំពីវិធីជ្រើសរើសអាជ្ញាសាលា ដែលមន្ត្រីរាជការ ប្រព័ន្ធប្រាក់បៀវត្ស សិទ្ធិអំណាចវិន័យ

---

[៣៣] មាត្រា ៣៦៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦

[៣៤] មាត្រា៣៣៦ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦

[៣៥] មាត្រា៣៨៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

[៣៦] មាត្រា៥២៤ កថាខណ្ឌទី១ និងមាត្រា៥២៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

ការងារ និងលក្ខណៈផ្សេងៗដែលត្រូវការ ជាចាំបាច់ថែមទៀត[៣៧]។ អាជ្ញាសាលាត្រូវបានបង្កើតឡើង ដើម្បីអនុវត្តដោយបង្ខំនូវសាលក្រមរដ្ឋប្បវេណីជំនួសឲ្យតុលាការ។ អាជ្ញាសាលា គឺជាតុលាការដាច់ដោយឡែកមួយ ដែលទទួលបន្ទុកការងារអនុវត្តបង្ខំ និងការងារពាក់ព័ន្ធ ហើយដែលមានមន្ត្រីរាជការដែលមានឈ្មោះថា: អាជ្ញាសាលា។ អាជ្ញាសាលា គឺជាស្ថាប័នអនុវត្តមួយឯករាជ្យ មិនមែនជាស្ថាប័នជំនួយនៃតុលាការអនុវត្តទេ។

សាលាដំបូងដែលត្រូវអនុវត្តដោយបង្ខំ តាមបញ្ញត្តិនៃគន្ថីនេះ គឺជាតុលាការអនុវត្ត។ ការសម្រេចសេចក្តីអំពីបណ្តឹងឧបាស្រ័យ ចំពោះការចាត់ចែងការអនុវត្តដែលធ្វើឡើងអាជ្ញាសាលា ត្រូវធ្វើឡើងដោយសាលាដំបូងដែលអាជ្ញាសាលានោះស្ថិតនៅ។

### ១.២.១. អាជ្ញាសាលា

អាជ្ញាសាលាត្រូវបានបង្កើតឡើង ដើម្បីអនុវត្តដោយបង្ខំនូវសាលក្រមរដ្ឋប្បវេណីជំនួសឲ្យតុលាការ។ អាជ្ញាសាលា គឺជាស្ថាប័នតុលាការដាច់ដោយឡែកមួយដែលទទួលបន្ទុកការងារអនុវត្តដោយបង្ខំ និងការងារពាក់ព័ន្ធ ហើយដែលមានមន្ត្រីរាជការដែលមានឈ្មោះថា: អាជ្ញាសាលា។ អាជ្ញាសាលា គឺជាស្ថាប័នមួយឯករាជ្យ មិនមែនស្ថាប័នជំនួយនៃតុលាការអនុវត្តទេ។

ដើម្បីធានាក្នុងការបំពេញមុខងាររបស់អាជ្ញាសាលា នៅពេលជួបប្រទះនឹងការប្រឆាំងពេលបំពេញមុខងាររបស់ខ្លួន អាជ្ញាសាលាអាចប្រើកម្លាំង ឬស្នើសុំជំនួយពីនគរបាល ឬកងកម្លាំងផ្សេងទៀតដែលមានសមត្ថកិច្ចដើម្បីបង្ក្រាបនូវការប្រឆាំង។ ក្នុងករណីដែលបុគ្គលផ្សេងទៀតដែលត្រូវបានអាជ្ញាសាលាបញ្ជូនទៅអនុវត្ត ជួបប្រទះនឹងការប្រឆាំងនៅពេលបំពេញមុខងារនោះ អ្នកដែលត្រូវបានអាជ្ញាសាលាបញ្ជូនអាច ស្នើសុំជំនួយពីអាជ្ញាសាលាដើម្បីអន្តរាគមន៍បាន។

អាជ្ញាសាលាមានសិទ្ធិចូលទៅក្នុងកន្លែងរស់នៅរបស់កូនបំណុលនៃការអនុវត្តបាន ឬកន្លែងផ្សេងទៀតដែលកូនបំណុលនោះកាន់កាប់ ដើម្បីធ្វើការឆែកឆេររកចលនវត្ថុដែលត្រូវរឹបអូសនៅក្នុងទំហំ ចាំបាច់ ដើម្បីធ្វើការអនុវត្តដោយបង្ខំ។ ក៏ប៉ុន្តែចំពោះការបំពេញការងារជាក់ស្តែងវិញ ពេលខ្លះមានការពិបាកខ្លាំងនឹងធ្វើដោយខ្លួនឯងផ្ទាល់។ ឧទាហរណ៍: ករណីនៃការអនុវត្តដោយបង្ខំ ឲ្យប្រគល់អាគារដែលមានអ្នកកាន់កាប់ច្រើននាក់ ឬករណីអនុវត្តចំពោះជនខិលខូចដែលមានឆន្ទៈទុច្ចរិត គឺពិតជាមានការលំបាកយ៉ាងខ្លាំងចំពោះអាជ្ញាសាលាក្នុងការចុះអនុវត្ត។ ចំពោះករណីនេះ គឺអាជ្ញាសាលាមានសិទ្ធិសុំជំនួយពីអាជ្ញាសាលាផ្សេងអោយជួយ ឬសុំជំនួយពីសមត្ថកិច្ចដើម្បីសហការណ៍។ ករណី ដែលចុះអនុវត្តតែឯងត្រូវមាន ការអនុញ្ញាតពីប្រធានសាលាដំបូងរាជធានី/ខេត្ត។ ជាគោលការណ៍ត្រូវធ្វើមុនពេលសុំជំនួយ ប៉ុន្តែយល់ថាករណីបន្ទាន់អាចសុំការអនុញ្ញាតនៅពេលក្រោយបាន។

[៣៧] មាត្រា៣៣៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

ទន្ទឹមនឹងនេះអាជ្ញាសាលាក៏ត្រូវទប់ស្កាត់នូវការក្លែងបន្លំផ្សេងៗដែលបុគ្គលមួយចំនួនបានតាំងខ្លួនជាអាជ្ញាសាលាផងដែរ ហេតុដូច្នេះនៅពេលចុះទៅបំពេញមុខងាររបស់ខ្លួនអាជ្ញា ឬបុគ្គលដែលត្រូវបានអាជ្ញាសាលាចាត់តាំង ក្នុងការបំពេញមុខងារ ត្រូវភ្ជាប់នូវលិខិតបញ្ជាក់អត្តសញ្ញាណ ឬលក្ខណៈសម្បត្តិរបស់ខ្លួន ហើយត្រូវបង្ហាញលិខិតនេះទៅជនដែលមានការពាក់ព័ន្ធនឹងផលប្រយោជន៍ ប្រសិនបើជននោះទាមទារ។

### ១.២.២. ក្រឡាបញ្ជី

នៅពេលដែលដីកាសម្រេចចាប់ផ្តើមពីការលក់ដោយបង្ខំត្រូវបានចេញ ក្រឡាបញ្ជីត្រូវរៀបចំចាត់ចែងអោយស្ថាប័នមានសមត្ថកិច្ចចុះបញ្ជី អំពីការរឹបអូសដែលពាក់ព័ន្ធនឹងដីកាសម្រេចចាប់ផ្តើមនោះជាបន្ទាន់។ ក្នុងករណីដែលមានការចាំបាច់ពិសេសណាមួយក្នុងការចាត់ចែងការងាររបស់អាជ្ញាសាលា នោះប្រធានសាលាដំបូងអាចធ្វើការកំណត់ជាមុននូវក្រឡាបញ្ជីដែលត្រូវបំពេញកិច្ចការរបស់អាជ្ញាសាលាដោយកម្រិត ឬមិនកម្រិតនៅកិច្ចការនោះ ឲ្យបុគ្គលនោះបំពេញមួយផ្នែក ឬទាំងស្រុងបាន។ ម្យ៉ាងវិញទៀតប្រសិនបើក្នុងករណីបន្ទាន់ដោយអាជ្ញាសាលាមានគ្រោះថ្នាក់ដោយចៃដន្យ ឬដោយមូលហេតុផ្សេងទៀត ប្រធានសាលាដំបូងក៏អាចអោយក្រឡាបញ្ជីដែលពុំបានកំណត់ដោយចំណុចខាងលើទទួលកាតព្វកិច្ចនេះមួយផ្នែក ឬទាំងស្រុងបានដែរ។

ចំពោះការវាយតម្លៃ ជាទូទៅគឺជាតួនាទីរបស់អាជ្ញាសាលា។ ប៉ុន្តែប្រសិនបើការរឹបអូសចលនវត្ថុនោះមានតម្លៃខ្ពស់ អាជ្ញាសាលាត្រូវជ្រើសតាំងអ្នកវាយតម្លៃ[៣៨]។

នៅពេលចុះអនុវត្ត ក្រៅពីអាជ្ញាសាលា នគរបាល ឬកងកម្លាំងផ្សេងទៀតក៏ត្រូវបានចុះអនុវត្តជាមួយអាជ្ញាសាលាដូចគ្នា ប្រសិនបើអាជ្ញាសាលាយល់ឃើញថា ស្ថានការពិបាកក្នុងការគ្រប់គ្រង។ ដោយយោងតាមមាត្រា៣៣៩ និងសេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលាបានកំណត់ថា នៅពេលដែលចុះបំពេញមុខងារតួនាទីរបស់ខ្លួន អាជ្ញាសាលាអាចស្នើសុំជំនួយពីនគរបាល ឬកងកម្លាំងផ្សេងទៀតដែលមានសមត្ថកិច្ច ដើម្បីបំបាត់នូវការប្រឆាំងទាំងឡាយដែលខ្លួនជួបប្រទះនៅពេលបំពេញមុខងារនោះ[៣៩]។ នៅពេលចុះទៅបំពេញមុខងារ ប្រសិនបើមិនបានជួបជាមួយបុគ្គលចម្បងនៃទីកន្លែងរស់នៅ ឬអ្នកតំណាងរបស់បុគ្គលនោះ ឬញាតិនៅជាមួយ ឬអ្នកបម្រើ ឬបុគ្គលផ្សេងដែលធ្វើការងារនៅទីនោះ ដែលមានសមត្ថភាពក្នុងការយល់ដឹងទេ ក្រឡាបញ្ជី ឬ អាជ្ញាសាលា ឬបុគ្គលផ្សេងដែលត្រូវបានផ្ទេរសិទ្ធិក្នុងការចុះអនុវត្តដោយបង្ខំ ដែលត្រូវបានបង្គាប់ដោយតុលាការអនុវត្ត ចាំបាច់ត្រូវមានមន្ត្រីឃុំ /សង្កាត់ មន្ត្រីនគរបាល ឬអ្នកដទៃទៀតដែលអាចធ្វើជាសាក្សីសមរម្យបាន។

---

[៣៨] មាត្រា៣៩៥ ចំណុចទី៧នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

[៣៩] មាត្រា៣៣៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

### ២. តុលាការអនុវត្ត

សាលាដំបូងនឹងក្លាយជាតុលាការអនុវត្ត ដោយយោងតាមមាត្រា៣៣៦ កថាខណ្ឌទី៣ ដែលបានចែងថា សាលាដំបូងដែលត្រូវអនុវត្តដោយបង្ខំ តាមបញ្ញត្តិនៃគន្ថីនេះ គឺជាតុលាការអនុវត្ត។

ជាគោលការណ៍ ការចែកចំណែកពីការលក់អចលនវត្ថុ ត្រូវធ្វើឡើងដោយតុលាការអនុវត្ត[៤០]។ សមត្ថកិច្ចចែកចំណែករបស់តុលាការមានចំពោះ៖

• ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ក្នុងករណីដែលកូនបំណុលទី៣ បានផ្ញើរប្រាក់ស្មើរនឹងចំនួនទឹកប្រាក់ទាំងអស់នៃសិទ្ធិលើបំណុលដែលត្រូវបានរឹបអូសមកតុលាការ។

• ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ក្នុងករណីដែលសិទ្ធិលើបំណុលត្រូវបានលក់ ហើយប្រាក់ដែលបានមកពីការលក់នោះត្រូវបានប្រគល់ជូនតុលាការអនុវត្ត[៤១]។

• ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀតដែលមានគោលបំណងឲ្យប្រគល់ត្រូវបានរឹបអូស ហើយអាជ្ញាសាលាលក់ចលនវត្ថុនោះរួចប្រគល់ប្រាក់ពីការលក់មកតុលាការ[៤២]។

• ករណីការអនុវត្តដោយបង្ខំចំពោះអចលវត្ថុ ដែលអ្នកទិញជាម្ចាស់បំណុលនៃការអនុវត្តដែលត្រូវបានទទួលការចែកចំណែក ហើយអ្នកទិញនេះបានបង់ថ្លៃលក់ដោយដកចេញនៅចំណែកដែលខ្លួនត្រូវទទួលបាន នៅកាលបរិច្ឆេទនៃការចែកចំណែក[៤៣]។

• ការអនុវត្តដោយបង្ខំចំពោះនាវា[៤៤]។ លើសពីនេះតុលាការអនុវត្តក៏មានសមត្ថកិច្ចផងដែរលើការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ក្នុងករណីដែលប្រាក់ដែលបានពីការលក់អចលនវត្ថុនោះមិនគ្រប់សម្រាប់សងម្ចាស់បំណុលច្រើននាក់ ហើយម្ចាស់បំណុលទាំងអស់មិនព្រមព្រៀងគ្នាលើការចែកចំណែក[៤៥]។

#### ២.១. ទីកន្លែងដែលត្រូវដាក់ពាក្យ

ក្នុងការអនុវត្តចំពោះអចលនវត្ថុ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងនៃអចលន

[៤០] មាត្រា៤៨៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

[៤១] មាត្រា៤១១ កថាខណ្ឌទី១ និងទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

[៤២] មាត្រា៤១៤ កថាខណ្ឌទី២ និងមាត្រា៤៨៨ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

[៤៣] មាត្រា៤៤៧ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

[៤៤] មាត្រា៤៧៩ កថាខណ្ឌទី១ និងមាត្រា៤៨៨ កថាខណ្ឌទី១ ចំណុច ឃ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

[៤៥] មាត្រា៥០១ និងមាត្រា៤៨៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

វត្ថុ គឺតុលាការអនុវត្ត។ ក្នុងករណីដែលយកដី ឬអាគារដែលបានចុះបញ្ជីជាកម្មវត្ថុ គឺសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងនោះ[៦]។

### ២.២. ឯកសារចំបាច់ក្នុងការដាក់ពាក្យ

មុននឹងឈានទៅដល់ការអនុវត្ត កត្តាចាំបាច់ត្រូវរៀបចំនូវសំណុំឯកសារក្នុងការដាក់ពាក្យសុំជាមុនសិន។ ឯកសារដែលចាំបាច់ក្នុងការដាក់ពាក្យ រួមមានដូចជា៖

- លិខិតអនុវត្ត
- លិខិតដែលបានបញ្ជាក់ពីការបានបញ្ជូនលិខិតអនុវត្ត
- រូបមន្តអនុវត្ត
- ពាក្យសុំលក់ដោយបង្ខំចំពោះអចលនវត្ថុ

### ២.៣. លិខិតអនុវត្ត

លិខិតអនុវត្ត គឺជាឯកសារដែលបញ្ជាក់អំពីសិទ្ធិទាមទារឲ្យផ្តល់តាវកាលិកណាមួយជាក់លាក់ ដែលកំណត់នៅក្រោមនីតិឯកជន ហើយផ្អែកលើឯកសារនោះ ច្បាប់ផ្តល់ឲ្យនូវអំណាចបង្ខំឲ្យអនុវត្ត ដើម្បីសម្រេចនូវអត្ថន័យនៃសិទ្ធិតាមរយៈការអនុវត្តដោយបង្ខំ[៧]។ ខាងក្រោមនេះគឺជាប្រភេទផ្សេងៗនៃលិខិតអនុវត្ត៖

- សាលក្រម ឬសាលដីកាបង្គាប់ឲ្យផ្តល់តាវកាលិកដែលបានចូលជាស្ថាពរ។
- សាលក្រម ឬសាលដីកាបង្គាប់ឲ្យផ្តល់តាវកាលិកដែលភ្ជាប់ជាមួយនឹងការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន។
- ដីកាសម្រេចបង្គាប់ឲ្យផ្តល់តាវកាលិក។ ប៉ុន្តែចំពោះដីកាសម្រេចដែលមិនត្រូវមានអានុភាពបើមិនទាន់ចូលជាស្ថាពរវិញ មានកម្រិតតែដីកាសម្រេចនោះបានចូលជាស្ថាពរហើយ។
- ដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន។
- ការចាត់ចែងរបស់ក្រឡាបញ្ជីដែលកំណត់អំពីប្រាក់ប្រដាប់ក្តី។
- លិខិតយថាភូតដែលធ្វើដោយសារការី ចំពោះការទាមទារដែលមានគោលបំណងឲ្យសងជាប្រាក់មានកំណត់។ ប៉ុន្តែមានកម្រិតតែលិខិតដែលបញ្ជាក់សេចក្តីថ្លែងការណ៍ថាកូនបំណុល នឹងទទួលការអនុវត្តដោយបង្ខំភ្លាមៗ។
- សាលក្រម ឬសាលដីការបស់តុលាការបរទេសដែលមានសាលក្រមអនុវត្តដែលបានចូលជាស្ថាពរ។

[៦] មាត្រា៨១៨ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

[៧] មាត្រា៣៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

- សេចក្តីសម្រេចមជ្ឈត្តករដែលមានដីកាសម្រេចអនុវត្ត ហើយបានចូលជាស្ថាពរ។
- កំណត់ហេតុដែលមានអានុភាពដូចសាលក្រម ឬសាលដីកា ដែលបានចូលជាស្ថាពរ។

**ឧទាហរណ៍:** កំណត់ហេតុសះជា។

លិខិតអនុវត្ត គឺសំដៅដល់ឯកសារដែលបញ្ជាក់ជាផ្លូវការតាមទម្រង់យថាភូតអំពីអត្ថិភាពនៃសិទ្ធិ ទាមទារអោយផ្តល់នូវតារកាលិកដែលកំណត់នៅក្រោមនីតិឯកជន។ តាមរយៈការបង្កើតលិខិតអនុវត្តទំនាក់ទំនងដែលថាម្ចាស់សិទ្ធិមានសិទ្ធិក្នុងការទាមទារឲ្យអាជ្ញាធររដ្ឋ គឺស្ថាប័នអនុវត្ត ធ្វើការអនុវត្តដោយ បង្ខំ និងកូនបំណុលយល់ព្រមទទួលយកសកម្មភាពរបស់អាជ្ញាធរ រដ្ឋ ដែលទាំងនេះកើតចេញពីទំនាន់ទំនងនៃសិទ្ធិ និងកាតព្វកិច្ចរបស់ភាគីនៅក្រោយនីតិឯកជន។

## ២.៤. លិខិតបញ្ជាក់ពីការបញ្ជូនលិខិតអនុវត្ត

លិខិតបញ្ជាក់ពីការបានបញ្ជូន គឺដើម្បីធ្វើការបញ្ជាក់ពីការដែលបានបញ្ជូនលិខិតរួចហើយទៅភាគីដែលពាក់ព័ន្ធអោយបានជ្រាបជាព័ត៌មានតាម។ ជាងនេះទៅទៀតចាំបាច់ត្រូវបញ្ជូនលិខិតអនុវត្ត ដើម្បីធ្វើការងារទុកជាមុនចំពោះកូនបំណុលនៃការអនុវត្តថា តើខ្លឹមសារ ណាខ្លះដែលនឹងត្រូវយកធ្វើការអនុវតត្ត។ ដោយឡែកក្នុងចំណោមលិខិតអនុវត្តគឺលិខិតសាលក្រមត្រូវបានបញ្ជូនទៅឲ្យភាគីក្នុងអំឡុងពេល ២(ពីរ) សប្តាហ៍ដោយគិតចាប់ពីថ្ងៃដែលបានប្រកាសសាលក្រមនេះ[៤៨]។

## ៣. រូបមន្តអនុវត្ត

រូបមន្តអនុវត្ត គឺជាប្រយោគដែលក្រឡាបញ្ជី ឬសារការី សរសេរភ្ជាប់បន្ថែមនៅលើផ្នែកក្រោមនៃឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត និងដែលបញ្ជាក់ជាផ្លូវការនូវអត្ថិភាព និងអត្ថន័យនៃអំណាច បង្ខំឲ្យអនុវត្តនៃលិខិតអនុវត្តនេះ។ ជាគោលការណ៍ ស្ថាប័នអនុវត្តត្រូវធ្វើការអនុវត្តដោយបង្ខំដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់ជាមួយរូបមន្តអនុវត្ត[៤៩]។ តើមូលហេតុអ្វីបានជាតម្រូវឲ្យភ្ជាប់បន្ថែមនូវរូបមន្តអនុវត្តទៅនឹងលិខិតអនុវត្ត?

**ទីមួយ៖** ស្ថាប័នអនុវត្តមិនមែនជាតុលាការនៃបណ្តឹងទេ ដូច្នេះវាមិនមែនជាការសមស្របនោះឡើយដែលឲ្យស្ថាប័នអនុវត្តធ្វើការវិនិច្ឆ័យទៅលើការអនុភាពអនុវត្តនៃលិខិតអនុវត្តនៅក្នុងករណីមានពាក្យសុំឲ្យអនុវត្តដោយបង្ខំម្តងៗ ដែលជាហេតុផលនាំឲ្យមានការយឺតយ៉ាវនៅក្នុងការអនុវត្តដោយបង្ខំ។

**ទីពីរ៖** នៅក្នុងករណីមានការអនុវត្តដោយបង្ខំត្រូវធ្វើឡើងពីអ្នកដែលបានបញ្ជាក់នៅក្នុងលិខិតអនុវត្តថា: ជាម្ចាស់បំណុល ឬជាកូនបំណុលនៃការអនុវត្តនោះចាំបាច់ត្រូវធ្វើការពិនិត្យស្រាវ

[៤៨] មាត្រា១៩០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

[៤៩] មាត្រា៣៥៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

ជ្រាវថាតើបុគ្គលនោះជាបុគ្គលដែលត្រូវទទួលឥទ្ធិពលនៃអានុភាពអនុវត្តនៃលិខិតអនុវត្តដែរឬទេ? ប៉ុន្តែបើបុគ្គលនោះជាបុគ្គលដែលត្រូវទទួលឥទ្ធិពលនៃអានុភាពអនុវត្តនៃលិខិតអនុវត្តមែននោះ ត្រូវសរសេរបន្ថែមនៅក្នុងលិខិតអនុវត្តដោយរៀបរាប់អំពីចំណុចនោះក្រោមទម្រង់ជារូបមន្តអនុវត្ត។

ជាគោលការណ៍ ទោះបីជាមានលិខិតអនុវត្តប្រភេទណាមួយក៏ដោយ ដើម្បីអាចដាក់ពាក្យសុំឲ្យអនុវត្តដោយបង្ខំនូវសិទ្ធិទាមទារ ឬសិទ្ធិប្រាតិភោគបាន ម្ចាស់បំណុលនៃការអនុវត្តត្រូវទទួលបាននូវការផ្តល់រូបមន្តសិនជានិច្ច។ ទោះបីជាលិខិតអនុវត្តដែលម្ចាស់បំណុលមានសេចក្តីប្រកាសថាៈ ការអនុវត្តដោយបង្ខំអាចធ្វើទៅបានដោយផ្អែកលើលិខិតនោះ (ដូចជា សាលក្រម ឬសាលដីកា) ក៏ចាំបាច់ត្រូវតែបានទទួលការផ្តល់រូបមន្តអនុវត្តសិនដែរ។

ជាករណីលើកលែង បើលិខិតអនុវត្ត គឺជាសាលក្រមនៃបណ្តឹងរឿងក្តីដែលមានចំនួនទឹកប្រាក់តិចដែលបានចូលជាស្ថាពរ សាលក្រមនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិចដែលភ្ជាប់ជាមួយនឹងការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន ឬក៏ជាដីការសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឲ្យអនុវត្តជាបណ្តោះអាសន្ន ពុំចាំបាច់មានរូបមន្តអនុវត្តទេ។

អត្ថិភាពនៃឯកសារចម្លងយថាភូត នៃលិខិតអនុវត្តដែលភ្ជាប់ជាមួយរូបមន្តអនុវត្ត គឺជាលក្ខខណ្ឌទាមទារសម្រាប់ការអនុវត្តដោយបង្ខំ។ម្យ៉ាងទៀតប្រសិនបើមានឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់មកជាមួយនឹងរូបមន្តហើយនោះ ស្ថាប័នអនុវត្តត្រូវធ្វើការអនុវត្តដោយបង្ខំដោយមិនចាំបាច់ ពិនិត្យពិចារណាលើខ្លឹមសារនៃលិខិតអនុវត្តនោះទេ។ ហេតុនេះហើយទោះបីជាឯកសារ ចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់មកជាមួយរូបមន្តអនុវត្ត ខុសគ្នាពីលិខិតអនុវត្តច្បាប់ដើម ឬប្រសិនបើរូបមន្តនោះត្រូវបានផ្តល់ដើម្បីប្រយោជន៍ ឬទៅឲ្យបុគ្គលណាម្នាក់ដែលពុំមានលក្ខណៈជាភាគីនៃការអនុវត្តដោយ បង្ខំក៏ដោយ ឬទោះបីជាលិខិតអនុវត្តនោះបានបាត់បង់អានុភាពក៏ដោយ ក៏ការអនុវត្តដោយបង្ខំដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់មកជាមួយនឹងរូបមន្តនោះ នៅតែជាការអនុវត្តស្របតាមច្បាប់ស្តីពីការអនុវត្តដោយបង្ខំដែរ។

ឯកសារយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់មកជាមួយនឹងរូបមន្តអនុវត្ត មានអានុភាពនៅគ្រប់ទីកន្លែងទាំងអស់ដែលស្ថិតនៅក្រោមសិទ្ធិជម្រះក្តីនៃព្រះរាជាណាចក្រកម្ពុជា ហើយម្ចាស់បំណុលអាចធ្វើការអនុវត្តដោយបង្ខំនៅទីកន្លែងណាមួយក៏បានដោយផ្អែកលើឯកសារចម្លងយថាភូតនោះ។ ជាងនេះទៅទៀតអានុភាពនៃឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលភ្ជាប់មកជាមួយនឹងរូបមន្តអនុវត្តនោះ ពុំមានការកម្រិតអំឡុងពេលដែលមានអានុភាពនោះទេ។ ក៏ប៉ុន្តែជាគោលការណ៍ទោះបីជាមានលិខិតអនុវត្តប្រភេទណាក៏ដោយដើម្បីអាចដាក់ពាក្យសុំឲ្យអនុវត្តដោយបង្ខំនូវសិទ្ធិទាមទារ ឬសិទ្ធិប្រាតិភោគ បានម្ចាស់បំណុលនៃការអនុវត្តត្រូវទទួលបាននូវការផ្តល់រូបមន្តអនុវត្តជាមុន

សិន[50]។ ចំពោះករណីលើកលែងប្រសិនបើលិខិតអនុវត្តជាសាលក្រមនៃបណ្ដឹងរឿងក្ដីមានចំនួនទឹកប្រាក់តិចដែលបានចូលជាស្ថាពរ សាលក្រមនៃបណ្ដឹងរឿងក្ដីចំនួនទឹកប្រាក់តិចភ្ជាប់ជាមួយ និងការប្រកាសឲ្យអនុវត្តជាបណ្ដោះអាសន្ន ឬដីកាសម្រេចដាស់តឿនដែលភ្ជាប់មកជាមួយនឹងប្រកាសឲ្យអនុវត្តជាបណ្ដោះអាសន្ននោះ ពុំចាំបាច់មានរូបមន្តទេ[51]។

### ៣.១. នីតិវិធីនៃការផ្ដល់រូបមន្តអនុវត្ត

ជាគោលការណ៍រូបមន្តអនុវត្តត្រូវផ្ដល់ដោយក្រឡាបញ្ជីដែលមានសំណុំរឿងនោះ[52]។ ក្នុងករណីចាំបាច់ដើម្បីធ្វើការវិនិច្ឆ័យថាតើអាច ឬមិនអាចផ្ដល់រូបមន្តអនុវត្ត ចាំបាច់មានការមើលបញ្ជាក់រឿងក្ដីនោះ។ ដោយឡែកក៏មានករណីខ្លះគឺរូបមន្តអនុវត្តក៏ត្រូវបានផ្ដល់ដោយសារការីដែលរក្សាទុកនូវលិខិតដើមនោះ[53]។ អ្វីដែលឃើញថាមានភាពដូចគ្នានោះគឺ មិនថារូបមន្តអនុវត្តដែលផ្ដល់ដោយក្រឡាបញ្ជី ឬរូបមន្តដែលផ្ដល់ដោយសារការីនោះទេ ចាំបាច់ត្រូវមានសំណុំរឿងក្ដីដើម្បីធ្វើការវិនិច្ឆ័យលើលក្ខខណ្ឌដែលត្រូវផ្ដល់រូបមន្តអនុវត្ត។

ពាក្យសុំរូបមន្តអនុវត្តគឺត្រូវធ្វើឡើងដោយភាគីដែលចង់បានរូបមន្តអនុវត្តដែលត្រូវរៀបចំដាក់ពាក្យសុំរូបមន្តអនុវត្តទៅស្ថាប័នបង្កើតរូបមន្តអនុវត្ត។ នៅក្នុងពាក្យសុំរូបមន្តអនុវត្តត្រូវសរសេរដូចរៀបរាប់ខាងក្រោម[54]៖

• ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត ហើយនិងឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។

• សញ្ញាណនៃលិខិតអនុវត្ត។

• ហេតុការណ៍ និងមូលហេតុ បើការទាមទារផ្ដល់រូបមន្តអនុវត្តត្រូវធ្វើឡើងតាមបញ្ញត្តិនៃមាត្រា ៣៥៦ ឬមាត្រា ៣៥៨ កថាខណ្ឌទី១។

ក្នុងករណីដែលលិខិតអនុវត្តជាសេចក្ដីសម្រេចដែលមិនបង្កើតអានុភាព បើមិនទាន់ចូលជាស្ថាពរទេ ប្រសិនបើម្ចាស់បំណុលនៃការអនុវត្តដាក់ពាក្យសុំឲ្យផ្ដល់រូបមន្តអនុវត្តចំពោះលិខិតអនុវត្តនោះ ម្ចាស់បំណុលនៃការអនុវត្តត្រូវភ្ជាប់មកជាមួយនូវពាក្យសុំ នូវលិខិតបញ្ជាក់ពីការចូលជាស្ថាពរនៃសេចក្ដីសម្រេចនោះ[55]។ សេចក្ដីសម្រេចចូលជាស្ថាពរ គឺជាសាលក្រម ឬសាលដីកាបង្គាប់អោយ

---

[50] មាត្រា ៣៥០ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

[51] មាត្រា ៣៥៤ កថាខណ្ឌទី១ វាក្យខណ្ឌទី២ ចំណុច ក ដល់ គ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

[52] មាត្រា ៣៥៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

[53] មាត្រា ៣៥៤ កថាខណ្ឌទី២ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

[54] មាត្រា ៣៥៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

[55] មាត្រា ៣៥៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

ផ្តល់តាវកាលិកដែលបានចូលជាស្ថាពរ (មាត្រា៣៥០ កថាខណ្ឌទី២ ចំណុច ក) ដីកាសម្រេចបង្គាប់ឲ្យផ្តល់តាវកាលិក ដីកាសម្រេចដែលតម្រូវឲ្យចូលជាស្ថាពរ (កថាខណ្ឌដដែលចំណុច គ) ឬ សាលក្រម ឬសាលដីកាអនុវត្ត និងដីកាសម្រេចអនុវត្តដែលបានចូលជាស្ថាពរ (កថាខណ្ឌដដែលចំណុច ឆ និង ជ)។

ស្ថាប័នបង្កើតរូបមន្តអនុវត្តដែលទទួលពាក្យសុំ នឹងធ្វើការបញ្ជាក់អំពីអត្ថិភាព ឬនត្ថិភាព និងទំហំនៃអនុវត្តលិខិតអនុវត្តនោះ។ ប្រសិនបើអានុភាពអនុវត្តលិខិតអនុវត្តត្រូវបានទទួលស្គាល់ដូចដែលបានកំណត់នៅក្នុងនោះ រូបមន្តអនុវត្តនឹងផ្តល់ឲ្យដោយសរសេរភ្ជាប់បន្ថែមនៅផ្នែកខាងក្រោមនៃឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត[៥៦]។ ក្រៅពីនេះស្ថាប័នបង្កើតរូបមន្តអនុវត្តត្រូវសរសេរនៅក្នុងច្បាប់ដើមនៃលិខិតអនុវត្ត នូវការដែលបានផ្តល់រូបមន្តអនុវត្ត ដូចដែលមានចែងក្នុងមាត្រា៣៥៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី[៥៧]។

**ចំណុចសំខាន់ៗដែលត្រូវសរសេរនៅក្នុងរូបមន្តអនុវត្ត[៥៨]**

-.កថាខណ្ឌទី១ ចំណុច ក បុគ្គលដែលអាចទាមទារឲ្យធ្វើការអនុវត្តដោយបង្ខំបានដោយលិខិតអនុវត្តនោះ និងភាគីម្ខាងទៀត។

-.កថាខណ្ឌទី១ ចំណុច ខ ហេតុការណ៍ ក្នុងករណីដែលបានផ្តល់រូបមន្តអនុវត្តតាមបញ្ញត្តិនៃមាត្រា ៣៥៦ (រូបមន្តអនុវត្តពិសេស) នៃក្រមនេះ។

-.កថាខណ្ឌទី១ ចំណុច គ ទំហំដែលអាចអនុវត្តដោយបង្ខំបាន បើបានផ្តល់រូបមន្តអនុវត្តតែមួយផ្នែកនៃសិទ្ធិទាមទារដែលត្រូវបានកំណត់នៅក្នុងលិខិតអនុវត្ត។

-.កថាខណ្ឌទី២ ក្រឡាបញ្ជី ឬសារការីត្រូវចុះហត្ថលេខាលើរូបមន្តអនុវត្តដោយសរសេរនៅថ្ងៃ ខែ ឆ្នាំ នៃការផ្តល់។

### ៣.២. ពាក្យសុំផ្តល់រូបមន្តអនុវត្ត

រូបមន្តអនុវត្តត្រូវផ្តល់ដោយក្រឡាបញ្ជីនៃតុលាការអនុវត្តដែលមាសំណុំរឿងនោះតាមពាក្យសុំ។ ប៉ុន្តែចំពោះលិខិតអនុវត្តដែលធ្វើឡើងដោយសារការីចំពោះការទាមទារដែលមានគោលបំណងឲ្យសងជាប្រាក់មានកំណត់ត្រូវផ្តល់ដោយសារការីដែលរក្សាទុកនូវលិខិតដើម។

---

[៥៦] មាត្រា ៣៥២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

[៥៧] មាត្រា៥៥៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

[៥៨] មាត្រា ៣៥៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

**ពាក្យសុំផ្តល់រូបមន្តអនុវត្តត្រូវធ្វើឡើងក្រោមទម្រង់ដូចខាងក្រោមៈ**

**ពាក្យសុំផ្តល់រូបមន្តអនុវត្ត**

**(ភាគី)**

**ម្ចាស់បំណុលនៃការអនុវត្ត** : អាសយដ្ឋាន
ឈ្មោះ

**កូនបំណុលនៃការអនុវត្ត** : អាសយដ្ឋាន
ឈ្មោះ

**(សញ្ញាណនៃលិខិតអនុវត្ត)**

ចំពោះរឿងក្តីរវាងម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្តនៅសាលាដំបូងក្រុងភ្នំពេញនាឆ្នាំ២០១៧ (លេខរឿងក្តី លេខសាលក្រម) សាលាដំបូងដែលខាងលើបានប្រកាសសាលក្រមនៅថ្ងៃទី.....ខែ........ឆ្នាំ២០១៧ (បានចូលជាស្ថានពរនៅថ្ងៃទី.......ខែ........ឆ្នាំដែល)

### ៤. ពាក្យសុំលក់ដោយបង្ខំចំពោះអចលនវត្ថុ

ជាទូទៅ វិវាទផ្នែករដ្ឋប្បវេណីច្រើនតែកើតឡើងដោយសារភាគីកូនបំណុលមិនព្រមបំពេញកាតព្វកិច្ចចំពោះម្ចាស់បំណុល ដូច្នេះហើយទើបទាមទារឲ្យមានការចូលរួមអន្តរាគមន៍ពីរដ្ឋអំណាចចំពោះការរំលោភបំពានយ៉ាងដូចនេះ។ សាលក្រមរដ្ឋក្រមរដ្ឋប្បវេណី បង្គាប់បញ្ជាឲ្យកូនបំណុលនៃការអនុវត្ត បំពេញតាវកាលិកឲ្យម្ចាស់បំណុលដោយស្ម័គ្រចិត្ត ករណីដែលកូនបំណុលនោះមិនបំពេញដោយស្ម័គ្រចិត្ត រដ្ឋត្រូវប្រើប្រាស់អំណាចរបស់ខ្លួនជាថ្មីម្តងទៀតដើម្បីសម្រេចសិទ្ធិជាស្ថាពររបស់ម្ចាស់បំណុលតាមរយៈនៃការអនុវត្តដោយបង្ខំ។ ចំពោះម្ចាស់បំណុលនៃការអនុវត្តសិទ្ធិលើបំណុលរបស់ខ្លួនត្រូវបានសម្រេច ជាស្ថាពរតាមរយៈទទួលចំណែក។ ដោយឡែកម្ចាស់បំណុលដែលបានទិញអចលនវត្ថុពីការលក់ដោយបង្ខំ ហើយក្លាយជាម្ចាស់តាមរយៈការចុះបញ្ជីផ្ទេរកម្មសិទ្ធិនឹងអាចសម្រេចសិទ្ធិរបស់ខ្លួនជាម្ចាស់ទ្រព្យបានតាមរយៈការផ្ទេរការកាន់កាប់ជាក់ស្តែង។ ករណីនេះម្ចាស់អចលនវត្ថុដែលទិញទ្រព្យលក់ដោយបង្ខំ ត្រូវដាក់ពាក្យសុំតុលាការចេញដីកាបង្គាប់ដើម្បីឲ្យប្រគល់អចលនវត្ថុ។ ទោះជាយ៉ាងនេះក្តី រដ្ឋនៅតែមិនអាចសម្រេចការចាត់ចែងការប្រគល់វត្ថុទាំងនោះដោយឯកឯងបានឡើយ គឺតម្រូវឲ្យម្ចាស់កម្មសិទ្ធិថ្មីនោះដាក់ពាក្យសុំមកកាន់តុលាការដោយផ្ទាល់។ ក្រមនីតិវិធីរដ្ឋប្បវេណីមិនបានកំណត់ពីលក្ខខណ្ឌអប្បរមា នៃទម្រង់នៃពាក្យសុំឲ្យប្រគល់អចលនវត្ថុឡើយ ហេតុដូចនេះគម្បីអ្នកទិញដាក់ពាក្យសុំដែលមានទម្រង់ធម្មតាមកតុលាការអនុវត្តដោយភ្ជាប់មកជាមួយឯកសារនានាដែលជាភស្តុតាងបញ្ជាក់ថាខ្លួនពិតជាម្ចាស់កម្មសិទ្ធិលើ

អចលនវត្ថុដែលអនុវត្តដោយបង្ខំនោះពិតប្រាកដមែន មានជាអាទ៍៖ លិខិតបញ្ជាក់អត្តសញ្ញាណនៃអ្នកទិញ ដីកាសម្រេចអនុញ្ញាតឲ្យលក់ ដីកាកំណត់ពីពេលបង់ប្រាក់ វិក័យបត្របង់ប្រាក់ និងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុជាដើម[៥៩]។ ហើយការដាក់ពាក្យសុំនេះត្រូវធ្វើឡើយមិនឲ្យហួសអំឡុងពេល ០៦ (ប្រាំមួយ) ខែ គិតចាប់ពីកាលបរិច្ឆេទបង់ប្រាក់ថ្លៃលក់ឡើយ ពុំនោះទេអ្នកទិញរូបនោះត្រូវថ្លោះសិទ្ធិទាមទារឲ្យប្រគល់។

ចំណុចដែលត្រូវបញ្ជាក់នៅក្នុងពាក្យសុំលក់ដោយបង្ខំចំពោះអចលនវត្ថុ[៦០]៖

• ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត ហើយនឹងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។

• សញ្ញាណនៃលិខិតអនុវត្ត។

• សេចក្តីសុំអនុវត្តតាមការបង្ខំដោយផ្ទាល់ ឬការអនុវត្តជំនួស ឬវិធានបង្ខំដោយប្រយោល។

• សញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ និងវិធីអនុវត្តដោយបង្ខំដែលម្ចាស់បំណុលនៃការអនុវត្តសុំ ក្នុងករណីដែលសុំឲ្យអនុវត្តតាមការបង្ខំដោយផ្ទាល់។

• ខ្លឹមសារនៃសេចក្តីសម្រេចដែលម្ចាស់បំណុលសុំ ក្នុងករណីដែលសុំឲ្យអនុវត្តដោយបង្ខំតាមការអនុវត្តជំនួស ឬវិធានបង្ខំដោយប្រយោល។

ក្រៅពីពាក្យសុំលក់ដោយបង្ខំចំពោះអចលនវត្ថុ ក៏ចាំបាច់ត្រូវភ្ជាប់មកនូវលិខិតមួយចំនួនមកជាមួយផងដែរដូចជាលិខិតចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត (មាត្រា ៣៤៩ កថាខណ្ឌទី២) លិខិតដែលបានបញ្ជាក់ពីការបានបញ្ជូនលិខិតអនុវត្ត (មាត្រា ៣៦០) ព្រមទាំងឯកសារចម្លងដែលមានសេចក្តីបញ្ជាក់នៃសៀវភៅចុះបញ្ជីអចលនវត្ថុជាអាទិ៍ (មាត្រា៤១៧ កថាខណ្ឌទី៣ ចំណុច ក និង ខ) ដើម្បីបញ្ជាក់ថា: អចលនវត្ថុគឺជាកម្មសិទ្ធិរបស់កូនបំណុល។

### ៥. ដីការសម្រេចចាប់ផ្តើមការលក់ដោយបង្ខំចំពោះអចលនវត្ថុ

ក្រោយធ្វើការពិនិត្យលើពាក្យសុំឲ្យប្រគល់ផ្ទៀងផ្ទាត់អត្តសញ្ញាណអ្នកទិញ និងអត្តសញ្ញាណនៃអចលនវត្ថុរួច តុលាការត្រូវចេញដីកាសម្រេចបង្គាប់ឲ្យប្រគល់អចលនវត្ថុ។ ដីកានេះតុលាការកំណត់ពេលសមរម្យសម្រាប់កូនបំណុលប្តឹងជំទាស់បាន បើផុតរយ:ពេលតវ៉ា ដីការនេះត្រូវមានអានុភាពអនុវត្ត។ ដីកាបង្គាប់ឲ្យប្រគល់មានអានុភាពបញ្ជាឲ្យកូនបំណុលនៃការអនុវត្ត ឬអ្នកកាន់កាប់អចលនវត្ថុ ដែលកំពុងកាន់កាប់អចលនវត្ថុនោះប្រគល់ទៅម្ចាស់អចលនវត្ថុថ្មីដែលត្រូវបានផ្ទេរកម្មសិទ្ធិដោយអធន្ទ:របស់កូនបំណុល គឺផ្ទេរកម្មសិទ្ធិដោយតុលាការ។ ប្រសិនបើតុលាការចេញដីកា

---

[៥៩] សៀវភៅស្តីពីការពន្យល់នីតិវិធីរដ្ឋប្បវេណី ភាគទី២ ទំព័រទី ៦២

[៦០] មាត្រា ៣៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

សម្រេចឲ្យប្រគល់ចំពោះអ្នកកាន់កាប់ផ្សេងពីកូនបំណុលតុលាការត្រូវសួរអ្នកកាន់កាប់នោះ[៦១]។

ផ្អែកតាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត តុលាការចាប់ផ្តើមការលក់ដោយបង្ខំនូវអចលនវត្ថុរបស់កូនបំណុលនៃការអនុវត្តដែលមានកំណត់នៅក្នុងឯកសារភ្ជាប់ស្តីពីបញ្ជីវត្ថុ ព្រមទាំងរឹបអូសអចលនវត្ថុនោះដើម្បីម្ចាស់បំណុលនៃការអនុវត្តក្នុងការបំពេញ ការសងសិទ្ធិលើបំណុលដែលទាមទារដែលមានកំណត់នៅក្នុងឯកសារភ្ជាប់ស្តីពីលិខិតអនុវត្ត និងបញ្ជីវាយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពលើបញ្ជីកំណត់ដដែលនោះ[៦២]។

១. រឹបអូស

**១.១ ពាក្យសុំ**
**១.២ ដីកាសម្រេចចាប់ផ្តើម**
**១.៣ រឹបអូស**
**១.៤ ទាមទារឲ្យចែកចំណែក**

↓

២. ចែកចំណែក

**២.១ ស្រាវជ្រាវ**
**២.២ លក់**
**២.៣ អានុភាព**

↓

៣. ចែកចំណែក

**៣.១ រៀបចំ**
**៣.២ ចែកចំណែក**

## ផ្នែកទី៣៖ លិខិតគតិយុត្តក្នុងការអនុវត្ត

ការអនុវត្តដោយបង្ខំ គឺជារបបបង្កើតឡើងដើម្បីសម្រេចនូវសិទ្ធិទាមទារឲ្យផ្តល់តាវកាលិករបស់ម្ចាស់បំណុលនៃការអនុវត្តចំពោះកូនបំណុលនៃការអនុវត្ត។ ស្ថាប័នអនុវត្តនឹងធ្វើការវិនិច្ឆ័យ

[៦១] មាត្រា៤៥០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

[៦២] យោងតាមគេហទំព័រ jica.go.jp នៃសិក្ខាសាលាដែលរៀបរៀងដោយលោកសាស្ត្រាចារ្យ HIGASHIO Kazuyuki និងលោកសាស្ត្រាចារ្យ YUKAWA Ryo

អំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិទាមទារឲ្យផ្តល់តាវកាលិក តាមលក្ខណៈទម្រង់បែបបទដោយផ្អែកលើលិខិតអនុវត្ត។ ហេតុនេះហើយនៅក្នុងលិខិតអនុវត្តត្រូវបង្ហាញឲ្យបានច្បាស់លាស់អំពីការ ដែលជាសិទ្ធិទាមទារឲ្យផ្តល់តាវកាលិក និងទំហំនៃសិទ្ធិទាមទារឲ្យផ្តល់តាវកាលិកនោះ។

## ១. លិខិតអនុវត្តដែលអាចអនុវត្តបានដោយគ្មានបញ្ហា

នៅលិខិតអនុវត្តមួយដែលអាចធ្វើការអនុវត្តទៅបានដោយគ្មានបញ្ហានោះគឺ ជាប្រភេទនៃសាលក្រមដែលបានសរសេរអំពីការបង្ហាញឲ្យឃើញច្បាស់ថា: នេះគឺជាសិទ្ធិទាមទារឲ្យផ្តល់តាវកាលិក និងការកំណត់អំពីចំនួនទឹកប្រាក់ក៏ត្រូវបានកំណត់បានច្បាស់លាស់ផងដែរ។ ហេតុនេះហើយចំពោះការអនុវត្តចំពោះអចលនវត្ថុអាចចាប់ផ្តើមបានដោយពុំមានបញ្ហានោះទេ។

**សាលក្រម**

**បង្គាប់អោយចុងចម្លើយបង់ប្រាក់ចំនួនសែសិបលានរៀល ចំពោះដើមចោទ**

ដែលនៅក្នុងសាលក្រមបានបង្ហាញឲ្យឃើញពីសិទ្ធិទាមទារតាវកាលិក និង បញ្ជាក់ពីចំនួនទឹកប្រាក់ច្បាស់លាស់។ ដូចនេះហើយលិខិតអនុវត្តនេះអាចអនុវត្តបានដោយគ្មានបញ្ហានោះទេ។

## ២. លិខិតអនុវត្តដែលមានបញ្ហា

ភាពខុសគ្នានៃលិខិតអនុវត្តដែលពុំមានបញ្ហា និងលិខិតអនុវត្តដែលមានបញ្ហាត្រង់ថា: សាលក្រមនៃលិខិតអនុវត្តដែលពុំមានបញ្ហាបង្គាប់ឲ្យភាគីចុងចម្លើយបង់ប្រាក់នៅដើមចោទ រីឯសាលក្រមដែលអនុវត្តទៅមានបញ្ហានៅ គឺការប្រើប្រាស់ពាក្យនៅក្នុងសាលក្រមមានបញ្ហាសរសេរថា: ចុងចម្លើយមានកាតព្វកិច្ចបង់ប្រាក់ទៅដើមចោទ។

ការសរសេរថា: មានកាតព្វកិច្ចបង់ប្រាក់នេះ គឺជាការបង្គាប់ឲ្យផ្តល់តាវកាលិក ឬគ្រាន់តែជាការបញ្ជាក់អំពីអត្ថិភាពនៃកាតព្វកិច្ច? គឺត្រង់ចំណុចនេះហើយដែលបង្ហាញពីភាពមិនច្បាស់លាស់នៃសាលក្រមនោះ។ ហេតុដូច្នេះហើយលិខិតអនុវត្តបែបនេះមិនអាចធ្វើការអនុវត្តដោយបង្ខំបាទេ តុលាការត្រូវលើកចោលពាក្យសុំនោះ។ ចំពោះដីកាសម្រេចលើកចោលពាក្យសុំឲ្យអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ម្ចាស់បំណុលនៃការអនុវត្តជាអ្នកប្តឹងជំទាស់បាន[៦៣]។

**សាលក្រម**

**ចុងចម្លើយមានកាតព្វកិច្ចបង់ប្រាក់ចំនួនសែសិបលានរៀលចំពោះដើមចោទ**

[៦៣] មាត្រា៥១៩ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

# ជំពូកទី ៣

## ទំនាក់ទំនងគតិយុត្តរវាងការអនុវត្ត

## ដោយបង្ខំ និងការក្សាការពារ

# ជំពូកទី៣

# ទំនាក់ទំនងគតិយុត្តរវាងការអនុវត្តដោយបង្ខំ និងការរក្សាការពារ

## ផ្នែកទី១៖ គោលការណ៍នៃការរឹបអូស

ជាគោលការណ៍ ការរឹបអូសអាចធ្វើបានចំពោះអចលនវត្ថុ និងចលនវត្ថុដែលធ្លាក់ទៅលើកូនបំណុលនៃការអនុវត្តនោះ ដែលសំដៅទៅលើទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិ ឬស្ថិតក្រោមការកាន់កាប់របស់កូនបំណុលនៃការអនុវត្តនោះ គឺសុទ្ធតែក្លាយជាកម្មវត្ថុនៃការរឹបអូសដើម្បីសម្រេចនូវសិទ្ធិទាមទាររបស់ម្ចាស់បំណុលនៃការអនុវត្ត។

ដូចគ្នាផងដែរចំពោះការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ជាគោលការណ៍គ្រប់អចលនវត្ថុដែលជាកម្មសិទ្ធិ ឬស្ថិតក្រោមការកាន់កាប់របស់កូនបំណុលសុទ្ធតែជាកម្មវត្ថុនៃការរឹបអូសទាំងអស់ដោយពុំចាំបាច់ធ្វើការស្រាវជ្រាវអំពីកម្មសិទ្ធិនៅមុនការធ្វើការរឹបអូសទេ លើកលែងតែមានការកំណត់ជាពិសេសនៅក្នុងច្បាប់។

ការអនុវត្តដោយបង្ខំលើអចលនវត្ថុ គឺមានគោលដៅក្នុងការបង្ហាញពីសិទ្ធិរបស់ភាគីក្នុងនាមជាដើមបណ្ដឹងទៅលើចលនវត្ថុ ឬអចលនវត្ថុ ដែលជាកម្មវត្ថុក្នុងការអនុវត្តដោយបង្ខំក្នុងការប្រគល់ទៅភាគី ដើមចោទ។ នៅពេលដែលមានការអនុវត្តដោយបង្ខំលើអចលនវត្ថុណាមួយបានចាប់ផ្ដើមអចលនវត្ថុនោះ នឹងត្រូវបានរឹបអូស។

**ឧទាហរណ៍:** សាលាដំបូងរាជធានីភ្នំពេញបានចេញសាលក្រមស្ដាពរឹបអូសដីមួយកន្លែងពីលោក A។

### ១. ការរឹបអូសជាបណ្ដោះអាសន្ន និង ការអនុវត្តដោយបង្ខំ

ការរឹបអូសជាបណ្ដោះអាសន្ន គឺជារបបរក្សារការពារជាបណ្ដោះអាសន្ននូវទ្រព្យសម្បត្តិរបស់កូនបំណុលដើម្បីជៀសវាងស្ថានភាពមួយដែលជាផលប៉ះពាល់ទៅដល់ភាគីនៃបណ្ដឹង។

**ករណីសិក្សា៖** នៅពេលដែលតុលាការកំពុងចាត់ការរឿងក្ដីរបស់ **កញ្ញា ក** និង **លោក ខ** ស្រាប់តែ **លោក ខ** បានធ្វើអនុប្បទានដី **ឯ** ទៅអោយតតិយជនបាត់។ ក្នុងករណីបែបនេះទោះបីជា **កញ្ញា ក** បានឈ្នះក្ដីក៏ដោយ ក៏មិនអាចសម្រេចនូវសិទ្ធិលើបំណុលឲ្យ **លោក ក** បានដែរព្រោះ **លោក ខ** មិនមានទ្រព្យសម្បត្តិអ្វីអាចអនុវត្តដោយបង្ខំបានទេ។

ហេតុដូចនេះហើយទើបមានការរឹបអូសជាបណ្ដោះអាសន្នដើម្បីជៀងវាងការបំពានរបស់ភាគីទៅលើភាគីម្ខាងទៀត។ ភាពចាំបាច់នៃដីការសម្រេចរឹបអូសជាបណ្ដោះអាសន្ន គឺដីកាសម្រេចរឹបអូសបណ្ដោះអាសន្នអាចចេញបានចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ក្នុងករណីដែលមានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬនឹងមានការលំបាកក្នុងការ

អនុវត្តដោយបង្ខំ។ ដីការសម្រេចរឹបអូសជាបណ្ដោះអាសន្នអាចចេញបានទោះបីជាសិទ្ធិលើបំណុល ដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណីមាត្រា ៥៤៥ បានថែងក៏ដោយ។

- ការរឹបអូសជាបណ្ដោះអាសន្ន គឺជាការរក្សាការពារទ្រព្យសម្បត្តិរបស់កូនបំណុលជាបណ្ដោះអាសន្ន។ វិធានការនេះធ្វើនៅមុនពេលកំណត់បញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិទាមទារ។
- ការអនុវត្តដោយបង្ខំ (ការអនុវត្តដោយបង្ខំដែលមានគោលបំណងឲ្យសងជាប្រាក់) គឺជាការ សងសិទ្ធិលើបំណុលដោយការលក់ដោយបង្ខំនូវទ្រព្យសម្បត្តិរបស់កូនបំណុល។ វិធានការនេះជាគោល ការណ៍ធ្វើនៅក្រោយពេលបានកំណត់បញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិទាមទារ[៦៤]។

**ការរឹបអូសជាបណ្ដោះអាសន្ន និងការអនុវត្តដោយបង្ខំ**

ការរក្សាការពារនៃបណ្ដឹងរដ្ឋប្បវេណី (រឹបអូសជាបណ្ដោះអាសន្ន)

↓

បណ្ដឹងរដ្ឋប្បវេណី (ការទាមទារឲ្យសងជាប្រាក់)

↓

អនុវត្តដោយបង្ខំ (ការអនុវត្តដោយបង្ខំដែលមានគោលបំណងឲ្យសងជាប្រាក់)

ការរឹបអូសជាបណ្ដោះអាសន្ន និងការអនុវត្តដោយបង្ខំ គឺជានីតិវិធីផ្សេងគ្នា តែទំនាក់ទំនងមាននៅត្រង់ថា ដើម្បីអាចអនុវត្តដោយបង្ខំបានត្រូវរឹបអូសជាបណ្ដោះអាសន្នទុកជាមុន។ នីតិវិធីទាំងនេះគឺធ្វើបន្តបន្ទាប់គ្នា។ ហេតុនេះហើយការប្ដូរពីការរឹបអូសជាបណ្ដោះអាសន្នទៅការអនុវត្តដោយបង្ខំនោះ ត្រូវបានទទួលស្គាល់។ នៅក្នុងការអនុវត្តជាក់ស្ដែងហៅថា ការប្ដូរទៅការអនុវត្តពិតប្រាកដ។

[៦៤] យោងតាមគេហទំព័រ jica.go.jp នៃសិក្ខាសាលាដែលរៀបរៀងដោយលោកសាស្ត្រាចារ្យ HIGASHIO Kazuyuki និងលោកសាស្ត្រាចារ្យYUKAWA Ryo



**ដី ខ**





**កញ្ញា ក បានទិញដីខទាមទារដី ខ ពីលោក ខ**

**កញ្ញា ក** **លោក ខ**

នៅពេលដែលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុត្រូវបានចេញការរក្សាការពារ និងត្រូវបានអនុវត្ត។ ការអនុវត្តរក្សាការពារគឺជាការអនុវត្តដើម្បីសម្រេចនូវគោលដៅនៃដីការសម្រេចរក្សាការពារ។

៦ **ការអនុវត្តដោយបង្ខំ គឺជាការអនុវត្តដើម្បីសម្រេចនូវគោលដៅនៃសាលក្រមសាលដីកាជាអាទិ៍។**

ដាក់ស្តែងត្រូវធ្វើការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុដែលបានកំណត់នៅក្នុងកថាខណ្ឌទី១ នៃមាត្រា៥១៧ (កម្មវត្ថុ និងវិធីនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ) នៃក្រមនេះត្រូវធ្វើតាមរបៀបចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ន[៦៥]។ នីតិវិធីនៃការចុះបញ្ជីរឹបអូសជាបណ្តោះអាសន្ន និងអានុភាពមានដូចគ្នានឹងករណីលក់ដោយបង្ខំដែរ[៦៦]។ ប្រសិនបើទាមទារឲ្យប្តូរទៅការអនុវត្តពិតប្រាកដត្រូវបញ្ជាក់ឲ្យច្បាស់លាស់អំពីការណ៍នោះនៅពេលដាក់ពាក្យសុំអនុវត្តដោយបង្ខំ។ នៅក្នុងពាក្យសុំលក់ដោយបង្ខំចំពោះអចលនវត្ថុត្រូវសរសេរពីការទាមទារសុំប្តូរពីការរឹបអូសជាបណ្តោះអាសន្នទៅការអនុវត្តពិតប្រាកដ។

**ឧទាហរណ៍៖** រឿងក្តីនេះ គឺជាពាក្យសុំអនុវត្តពិតប្រាកដដែលប្តូរពីការរឹបអូសជាបណ្តោះអាសន្ន ដោយដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន (**លេខដីកាសម្រេច**) សាលាដំបូងរាជធានីភ្នំពេញ ចុះថ្ងៃទី០ ខែ០ ឆ្នាំ ២០១៦។ ម្យ៉ាងទៀតចាំបាច់ត្រូវដាក់ឯកសារចម្លងយថាភូតនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន។ ផ្អែកតាមការទាំងនេះការរឹបអូសជាបណ្តោះអាសន្ននឹងប្តូរទៅ

[៦៥] មាត្រា៥៦៧ កថាខណ្ឌទី១ នៃក្រមនិតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

[៦៦] មាត្រា៥៦៧ កថាខណ្ឌទី៤ នៃក្រមនិតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

ការអនុវត្តពិតប្រាកដ[៦៧]។ ផ្អែកតាមការប្តូរទៅការអនុវត្តពិតប្រាកដ ការចាត់ចែងដែលត្រូវបានធ្វើក្រោយពេលចុះបញ្ជីរឹបអូសជាបណ្តោះអាសន្នមិនអាចតតាំងនិងម្ចាស់បំណុលនៃការអនុវត្តបានឡើយ។ សិទ្ធិនោះនឹងត្រូវរលត់ដោយ ការលក់។ ក្នុងចំណោមសិទ្ធិប្រាតិភោគប្រត្យក្ស សិទ្ធិប្រត្យក្សប្រើប្រាស់ និងអាស្រ័យផល និងសិទ្ធិជួលដែលមានលើអចលនវត្ថុចំពោះសិទ្ធិដែលអាចតតាំងនឹងការរឹបអូសដោយម្ចាស់បំណុលនៃការអនុវត្តបានត្រូវបន្តអត្ថិភាពនៅក្រោយការលក់[៦៨]។

### ២. ការប្តូរពីការរឹបអូសជាបណ្តោះអាសន្ន ទៅការអនុវត្តពិតប្រាកដ

កញ្ញា X ៖ ជាម្ចាស់បំណុលនៃការអនុវត្ត

លោក Y ៖ ជាបំណុលនៃការអនុវត្ត

លោក Z ៖ ជាតតិយជន

លោក W ៖ ជាតតិយជន

**១**. ចុះបញ្ជីរឹបអូសជាបណ្តោះអាសន្ន **៤**. ប្តូរទៅការអនុវត្តពិតប្រាកដ

**២**. Y ចុះបញ្ជីបង្កើតហ៊ីប៉ូតែកដើម្បី W **៣**. Y ចុះបញ្ជីផ្ទេរកម្មសិទ្ធិឲ្យទៅ Z

ដោយការប្តូរពីការអនុវត្តជាបណ្តោះអាសន្នទៅការអនុវត្តពិតប្រាកដទាក់ទងនឹងនីតិវិធីអនុវត្ត ការចាត់ចែង ២ និង ៣ ត្រូវក្លាយជាមោឃៈ។

## ផ្នែកទី២ ៖ ការលក់

មុននឹងឈានទៅដល់ការលក់នូវអចលនវត្ថុណាមួយ តុលាការតែងតែធ្វើការសិក្សាស្រាវជ្រាវ អចលនវត្ថុដែលបានរឹបអូសនោះ ហើយកំណត់តម្លៃលក់អប្បបរមាដោយផ្អែកលើស្ថានភាពនិងទំនាក់ទំនងសិទ្ធិនៃអចលនវត្ថុនោះ និងធ្វើការផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មាននៃអចលនវត្ថុដែល បានរឹបអូសដោយកំណត់អ្នកទិញដោយវិធីលក់ឡៃឡុងដោយស្រោមសំបុត្រជាអាទិ៍ ហើយឲ្យអ្នកទិញបង់ថ្លៃលក់។ ក្រោយពេលថ្លៃលក់ត្រូវបានបង់ហើយកម្មសិទ្ធិនៃអចលនវត្ថុនឹងផ្ទេរពីកូនបំណុលនៃការអនុវត្តទៅ អ្នកទិញ។

### ១. ការស្រាវជ្រាវ

ក្នុងករណីលក់អចលនវត្ថុដែលបានរឹបអូស **តើខាងអ្នកទិញមានការចាប់អារម្មណ៍យកចិត្តទុកដាក់ ទៅលើចំណុចអ្វីខ្លះ?**

---

[៦៧] យោងតាមគេហទំព័រ jica.go.jp នៃសិក្ខាសាលាដែលរៀបរៀងដោយលោកសាស្ត្រាចារ្យ HIGASHIO Kazuyuki និងលោកសាស្ត្រាចារ្យYUKAWA Ryo

[៦៨] មាត្រា៤៣១ កថាខណ្ឌទី១ និងទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

ក្នុងនាមជាអ្នកទិញនៃកិច្ចសន្យាលក់ទិញ អ្វីដែលចាប់អារម្មណ៍យកចិត្តទុកដាក់នោះ គឺប្រាកដទៅលើ**កម្មវត្ថុនៃការអនុវត្ត** និង**ថ្លៃលក់** ជាមិនខាន។ តម្លៃនៃការលក់ គឺកំណត់ដោយផ្អែកលើតម្លៃនៃកម្មវត្ថុនៃការអនុវត្ត។ មានន័យថាតុលាការដែលនឹងក្លាយជាអ្នកលក់ត្រូវធ្វើការស្រាវជ្រាវអំពីកម្មវត្ថុនៃការអនុវត្ត និងអំពីតម្លៃនោះ។ នៅពេលដែលតុលាការបានបើកការស្រាវជ្រាវយ៉ាងដូចនេះនោះសំណួរមួយនឹងត្រូវបានចោទឡើងបន្តបន្ទាប់ទៀតថា: តើតម្លៃនៃអចលនវត្ថុដែលជាកម្មវត្ថុនៃការ អនុវត្តកំណត់ដោយផ្អែកលើកត្តាអ្វីខ្លះ? ជាទូទៅពាក់ព័ន្ធទៅនឹងទំហំផ្ទៃដី ទីតាំងជាដីទំនេរ ឬអាគារ? តើមាននរណាកំពុងកាន់កាប់ឬទេ? តើមានភ្ជាប់និងសិទ្ធិប្រាតិភោគឬទេ? ទាំងនេះសុទ្ធសឹងជាសំណួរដែលតែងតែចោទឡើងនៅពេលដែលតុលាការចាប់ផ្តើមការស្រាវជ្រាវនៅក្នុងការលក់ទៅលើអចលនវត្ថុ ហេតុដូច្នេះហើយទើបចាំបាច់ឲ្យតុលាការធ្វើការវាយតម្លៃដោយផ្អែកលើលទ្ធផលនោះ។

ដើម្បីធ្វើការស្រាវជ្រាវនិងវាយតម្លៃនូវបញ្ហាដែលបានចោទឡើង តុលាការអនុវត្តត្រូវជ្រើសតាំងអ្នកវាយតម្លៃ និងបង្គាប់ឲ្យវាយតម្លៃអចលនវត្ថុនោះ[៦៩]។ អ្នកវាយតម្លៃដែលត្រូវបានជ្រើសតាំងត្រូវបានដាក់ជូនទៅតុលាការអនុវត្តជាលាយលក្ខណ៍អក្សរនូវលទ្ធផលនៃការស្រាវជ្រាវអំពីស្ថានភាព បច្ចុប្បន្ននៃអចលនវត្ថុ និងការវាយតម្លៃអចលនវត្ថុនោះ[៧០]។

ដើម្បីកាន់តែមានភាពច្បាស់លាស់ទៅលើសិទ្ធិរបស់អ្នកវាយតម្លៃនោះ គឺចាំបាច់ត្រូវភ្ជាប់មកជាមួយនូវលិខិតបង្គាប់ឲ្យធ្វើការវាយតម្លៃ និង ឯកសារភ្ជាប់ស្តីពីបញ្ជីវត្ថុជាដើម។

**ខាងក្រោមនេះជាឯកសារភ្ជាប់ស្តីពីបញ្ជីវត្ថុ**

**លិខិតបង្គាប់ឲ្យធ្វើការវាយតម្លៃ**

អ្នកវាយតម្លៃ………………………

ជ្រើសតាំងជនដែលបានកំណត់ខាងលើនេះជាអ្នកវាយតម្លៃ។

បង្គាប់ឲ្យអ្នកវាយតម្លៃធ្វើការវាយតម្លៃចំពោះអចលនវត្ថុដែលមានកំណត់នៅក្នុងឯសារភ្ជាប់ពីបញ្ជីវត្ថុ។

កំណត់ថ្ងៃទី…..ខែ….ឆ្នាំ….ជាកាលកំណត់ត្រូវប្រគល់លិខិតវាយតម្លៃ។

ថ្ងៃទី………ខែ…..ឆ្នាំ…

សាលាដំបូងរាជធានីភ្នំពេញចៅក្រមឈ្មោះ……………

[៦៩] មាត្រា៤៣០ កថាខណ្ឌទី១ នៃក្រមនិតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

[៧០] មាត្រា៤៣០ កថាខណ្ឌទី៥ នៃក្រមនិតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

**ឯកសារភ្ជាប់ស្តីពីបញ្ជីវត្ថុ**

- ឈ្មោះខេត្ត/ក្រុង
- ឈ្មោះស្រុក/ខណ្ឌ
- ឈ្មោះឃុំ/សង្កាត់
- ឈ្មោះភូមិ
- លេខក្បាលដី/លេខប័ណ្ណកម្មសិទ្ធិ
- ឈ្មោះកម្មសិទ្ធិករនិងអាសយដ្ឋាន

## ➤ សិទ្ធិអំណាចរបស់អ្នកវាយតម្លៃ

ដើម្បីសុំជំនួយពីអាជ្ញាសាលា អ្នកវាយតម្លៃត្រូវទទួលការអនុញ្ញាតពីតុលាការអនុវត្ត[៧១]។ នៅពេលស្រាវជ្រាវដើម្បីធ្វើការវាយតម្លៃ អ្នកវាយតម្លៃអាចចូលទៅកាន់អចលនវត្ថុ ឬអាចសួរសំណួរ ឬទាមទារឲ្យបង្ហាញឯកសារចំពោះកូនបំណុលនៃការអនុវត្ត ឬតតិយជនដែលកាន់កាប់អចលនវត្ថុនោះ បាន[៧២]។ ស្តីពីទំនាក់ទំនងសិទ្ធិនៃអចលនវត្ថុដែលត្រូវបានរឹបអូសក្នុងនាមជាអ្នកទិញប្រាកដជាមានការចាប់អារម្មណ៍ និងយកចិត្តទុកដាក់ចំពោះសិទ្ធិជាអាទិ៍ដែលនៅបន្តមានអត្ថិភាពក្រោយពេលលក់ជាមិនខាន។

**ឧទាហរណ៍៖** ប្រសិនបើអចលនវត្ថុដែលបានទិញនោះ ជាអចលនវត្ថុដែលត្រូវបានបន្សល់ទុកនូវហ៊ីប៉ូតែក ទោះបីជាបានទិញហើយក៏ដោយ ជាចុងបញ្ចប់អ្នកទិញអាចនឹងបាត់បង់កម្មសិទ្ធិនោះដោយ សារក្រោយមកហ៊ីប៉ូតែកត្រូវបានអនុវត្ត។ ហេតុដូចនេះហើយនៅពេលធ្វើការវាយតម្លៃត្រូវវិនិច្ឆ័យអំពីសិទ្ធិដែលនៅបន្តមានអត្ថិភាពក្រោយការកត់ឲ្យអ្នកទិញ និងសិទ្ធិដែលត្រូវរលត់ដោយការលក់ ហើយត្រូវកំណត់តម្លៃអចលនវត្ថុដោយផ្អែកលើលទ្ធផលនៃការវិនិច្ឆ័យនោះ។ ស្តីពីសិទ្ធិលើអចលនវត្ថុដែលបានរឹបអូស តើសិទ្ធិនេះនឹងបន្តមានអត្ថិភាព ឬត្រូវរលត់ក្រោយការលក់ នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី នោះនឹងក្លាយជាមូលដ្ឋានសំរាប់ការវិនិច្ឆ័យថា: តើអាចតតាំងនិងការរឹបអូស ឬក៏មិនអាច? យោងតាមមាត្រា ៤៣១ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី គឺសិទ្ធិដែលត្រូវបានចុះបញ្ជីនៅមុនពេលអានុភាពនៃការរឹបអូសកើតឡើង នៅបន្តមានអត្ថិភាពក្រោយការលក់។ ដោយឡែកសិទ្ធិដែលត្រូវបានចុះបញ្ជីនៅក្រោយពេលអានុភាពនៃការរឹបអូសកើតឡើងត្រូវរលត់ក្រោយ

[៧១] មាត្រា៤៣០ កថាខណ្ឌទី២ នៃក្រមនិតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

[៧២] មាត្រា៤៣០ កថាខណ្ឌទី៣ នៃក្រមនិតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

ការលក់ដោយយោងតាមមាត្រា ៨៣១ កថាខណ្ឌទី២។

**ឧទាហរណ៍:** ជាក់ស្តែងប្រសិនបើសិទ្ធិនោះត្រូវបានចុះបញ្ជីតាមលំដាប់ដូចខាងក្រោម៖

1. ចុះបញ្ជីបង្កើតហ៊ីប៉ូតែកទី១ (A ->Y)
2. ចុះបញ្ជីបង្កើតហ៊ីប៉ូតែកទី២ (B ->Y)
3. ចុះបញ្ជីរឹបអូស (X ->Y)
4. ចុះបញ្ជីបង្កើតហ៊ីប៉ូតែកទី៣ (C ->Y)

សិទ្ធិដែលនៅបន្តមានអត្ថិភាពក្រោយការលក់គឺ ហ៊ីប៉ូតែកទី១ និង ទី២ (ទី៣ ត្រូវរលត់)ដោយសារទំនាក់ទំនងសិទ្ធិអាចនឹងមានការផ្លាស់ប្តូរ ដូច្នេះហើយទើបអ្នកវាយតម្លៃធ្វើការវាយតម្លៃដោយផ្អែកលើទំនាក់ទំនងសិទ្ធិដែលនៅបន្តមានអត្ថិភាពក្រោយការលក់។ ហើយយោងលើការវាយតម្លៃរបស់អ្នកវាយតម្លៃដែលបានធ្វើឡើយដោយផ្អែកតាមកត្តាទាំងអស់នេះ តុលាការត្រូវកំណត់តម្លៃលក់អប្បបរមានៃអចលនវត្ថុដែលរឹបអូសនោះ[៧៣]។ តម្លៃអប្បបរមា គឺជាការដែលមិនអាចលក់ដោយតម្លៃតិចជាងនេះ។ នៅពេលត្រូវអនុវត្តការលក់ ក្រឡាបញ្ជីត្រូវផ្សាយជាសាធារណៈនូវសញ្ញាណនៃអចលនវត្ថុដែលត្រូវលក់តម្លៃអប្បបរមាព្រមទាំងកាលបរិច្ឆេទ និងទីកន្លែងលក់[៧៤]។ ដោយឡែកប្រសិនបើការលក់អប្បបរមាដែលតុលាការបានកំណត់នឹងពុំសេសសល់ប្រាក់សំរាប់ចែកចំណែកចំពោះម្ចាស់បំណុលទេ ការលក់នោះពុំមានផលប្រយោជន៍សំរាប់ម្ចាស់បំណុលឡើយ ដូច្នេះតុលាការអនុវត្តត្រូវជូនដំណឹងអំពីការនោះទៅឲ្យម្ចាស់បំណុលនៃការអនុវត្ត ជាគោលការណ៍ត្រូវលុបចោលនូវនីតិវិធីនៃការលក់ដោយបង្ខំ[៧៥]។ ករណីលើកលែងប្រសិនបើម្ចាស់បំណុលនៃការអនុវត្តធ្វើសំណើរថាខ្លួននឹងទិញអចលនវត្ថុក្នុងតម្លៃស្នើសុំដែលលើសពីតម្លៃសោហ៊ុយសម្រាប់នីតិវិធី និងដាក់ប្រាក់ធានាដែលស្មើនឹងតម្លៃស្នើសុំ[៧៦]។

**ឧទារហណ៍:**

តម្លៃនៃអចនវត្ថុ គឺ ១០១

ហ៊ីប៉ូតែកទី១ (ក) បាន ៦០

ហ៊ីប៉ូតែកទី២ (ខ) បាន ៤០

ចំណែកឯសោយហ៊ុយសម្រាប់នីតិវិធី (២)

---

[៧៣] មាត្រា៨៣២ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

[៧៤] មាត្រា៨៣៦ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

[៧៥] មាត្រា៨៣៥ កថាខណ្ឌទី២ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

[៧៦] មាត្រា៨៣៥ កថាខណ្ឌទី២ ចំណុច ក និង ចំណុច ខ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

ដោយសារតម្លៃជាក់ស្តែងនៃអចលនវត្ថុ [១០១-(៦០+៤០)=១] គឺតិចជាងសោហ៊ុយសំរាប់នីតិវិធី (២) ដូច្នេះជាគោលការណ៍នីតិវិធីនៃការលក់ត្រូវលុបចោល។ ដើម្បីផ្សព្វផ្សាយប្រមូលអ្នកមានបំណងចង់ទិញ ចាំបាច់ត្រូវបង្ហាញឲ្យបានច្បាស់អំពីព័ត៌មានស្តីពីកម្មវត្ថុនៃការអនុវត្ត និងថ្លៃលក់ដែលតុលាការអនុវត្តត្រូវធ្វើឯកសារលំអិតអំពីវត្ថុហើយត្រូវទុកឯកសារចម្លងនៃឯកសារនោះនៅតុលាការអនុវត្តជាមួយ នឹងឯកសារចម្លងនៃរបាយការណ៍វាយតម្លៃដើម្បីផ្តល់ជូនសាធារណៈជនបានមើល[៧៧]។

## ២. ការលក់

នីតិវិធីនៃការលក់ គឺជានីតិវិធីដែលត្រូវបានយកមកអនុវត្តនៅក្នុងដំណាក់កាលនៃការលក់មួយនៅក្នុងបណ្តឹងទាក់ទងទៅនឹងការអនុវត្តដោយបង្ខំ ដែលនីតិវិធីនេះមានកំណត់អំពីលក្ខខណ្ឌពិសេស ដូចខាងក្រោម៖

១. កំណត់វិធីលក់ បើកកាលបរិច្ឆេទលក់ ហើយប្រគល់ឲ្យអាជ្ញាសាលាអនុវត្តការលក់

២. កំណត់អ្នកស្នើទិញក្នុងតម្លៃជាអតិបរមា ហើយបើកកាលបរិច្ឆេទដើម្បីចេញដីកាសម្រេចអនុញ្ញាតឲ្យលក់

៣. នៅពេលដែលកំណត់ដីកាសម្រេចអនុញ្ញាតឲ្យលក់ចូលជាស្ថាពរ ត្រូវកំណត់នូវពេលកំណត់ ដែលត្រូវបង់ថ្លៃលក់ ហើយឲ្យអ្នកទិញបង់ថ្លៃលក់។

ការលក់អចលនវត្ថុត្រូវអនុវត្តតាមនីតិវិធី **ឡៃឡុងដោយស្រោមសំបុត្រ** ឬដោយផ្ទាល់មាត់[៧៨]។ ប្រសិនបើការលក់តាមវិធីឡៃឡុងដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់តុលាការអនុញ្ញាតត្រូវកំណត់កាលបរិច្ឆេទ និងទីកន្លែងលក់ ហើយត្រូវឲ្យអាជ្ញាសាលាអនុវត្តការលក់នោះ[៧៩]។

- **ចំណាំ៖ កូនបំណុលនៃការអនុវត្តមិនអាចទិញបានឡើយដោយយោងតាមមាត្រា ៨៣៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី។**

ការលក់ឡៃឡុងដោយស្រោមសំបុត្រ គឺជានីតិវិធីដែលអ្នកមានបំណងចង់ទិញដាក់សំណើរទិញ (ជាលាយល័ក្ខអនក្សរ) ដោយសរសេរតម្លៃដែលចង់ទិញទៅក្នុងពាក្យសុំទិញការលក់ឡាយឡុង បន្ទាប់មកអនុវត្តការប្រើស្រោមសំបុត្រ ហើយកំណត់អ្នកស្នើសុំទិញក្នុងតម្លៃអតិបរមា។ នីតិវិធីនេះខុសគ្នា និងការលក់ឡៃឡុងដោយផ្ទាល់មាត់ដែលតម្រូវអោយអ្នកបច្ចេកទេស ឬបទពិសោធន៍ក្នុងការវាយតម្លៃ វិធីលក់ខាងលើនេះត្រូវបានយល់ឃើញថា: ជាគោលការណ៍នៃវិធីលក់ដោយហេតុ

[៧៧] មាត្រា៨៣៤ កថាខណ្ឌទី២ នៃក្រមនិតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

[៧៨] មាត្រា៨៣៦ កថាខណ្ឌទី១ នៃក្រមនិតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

[៧៩] មាត្រា៨៣៦ កថាខណ្ឌទី៣ នៃក្រមនិតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

ថា: អាចធ្វើឲ្យសាធារណជនទូទៅមកចូលរួមយ៉ាងទូលំទូលាយ។ ដើម្បីបង្ការការមិនបង់ថ្លៃលក់របស់អ្នកទិញ ជនដែលបម្រុងនិង ធ្វើសំណើទិញអចលនវត្ថុត្រូវដាក់ប្រាក់ទៅតុលាការ ជាប្រាក់ធានាដែលមាន ចំនួនស្មើនឹង១ភាគ១០ នៃតម្លៃលក់អប្បបរមា[៨០]។ ក្នុងករណីដែលបានក្លាយជាអ្នកទិញក្នុងតម្លៃអតិបរមា ប្រាក់ធានានេះនឹងត្រូវគិតបញ្ចូលក្នុងថ្លៃលក់។ ដោយឡែកប្រសិនបើមិនបានក្លាយជាអ្នកទិញ ក្នុងតម្លៃអតិបរមាទេ ក្រោយពេលបញ្ចប់ការលក់ ប្រាក់ធានានឹងត្រូវបានសងមកវិញ។ ការងារជាក់ស្តែងនៃការលក់ ប្រគល់ឲ្យអាជ្ញាសាលាជាអ្នកអនុវត្ត ប៉ុន្តែបន្ទាប់ពីនោះមកគឺតុលាការត្រូវបើកកាលបរិច្ឆេទដើម្បីចេញដីកាសម្រេចអនុញ្ញាត ឬមិនអនុញ្ញាតឲ្យលក់ចំពោះអ្នកទិញក្នុងតម្លៃអតិបរមាដែលកំណត់ដោយអាជ្ញាសាលា។ ដីកាសម្រេចនេះប្រសិនបើពុំមានចំណុចពិសេសដែលត្រូវបានកំណត់ដោយច្បាប់ទេ តុលាការអនុវត្តត្រូវចេញដីកាសម្រេចអនុញ្ញាតឲ្យលក់។ ក្នុងករណីដែលមានបណ្តឹងឧបាស្រ័យចំពោះដីកាសម្រេចអនុញ្ញាត ឬមិនអនុញ្ញាតឲ្យលក់ជនដែលពាក់ព័ន្ធនឹងផលប្រយោជន៍ អាចប្តឹងជំទាស់បានលុះត្រាតែក្នុងករណីដែលដីកាសម្រេច នោះបណ្តាលឲ្យមានការខូចខាតដល់សិទ្ធិ របស់ខ្លួន។

- ការតវ៉ាចំពោះការអនុវត្ត[៨១] ៖
    - ចំពោះការចាត់ចែងការអនុវត្តរបស់តុលាការអនុវត្តដែលមិនអាចប្តឹងជំទាស់បាន អាចតវ៉ាទៅតុលាការអនុវត្តបានដោយអះអាងអំពីការបំពានលើនីតិវិធីនោះ។
    - ការសម្រេចសេចក្តីបានធ្វើឡើងដោយដីកាសម្រេចដោយគ្មានការកម្រិតអំឡុងពេល។
    - ពុំមែនជាបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ទេ គឺជាការទាមទារសុំឲ្យតុលាការជម្រះក្តីដដែលនោះធ្វើការពិចារណាឡើងវិញ។
    - ជាគោការណ៍មិនអាចធ្វើឧបាស្រ័យចំពោះការតវ៉ា ចំពោះការអនុវត្តបានឡើយ ប្រសិន បើយល់ឃើញថាចាំបាច់ តុលាការអនុវត្តអាចផ្លាស់ប្តូរតម្លៃលក់អប្បបរមាបាន[៨២]។

## ៣. អានុភាព

ដើម្បីឲ្យដីកាសម្រេចអនុញ្ញាតចូលជាស្ថាពរ អ្នកទិញត្រូវបង់ថ្លៃលក់ទៅតុលាការអនុវត្ត នៅមុនពេលដែលតុលាការអនុវត្តបានកំណត់។ ពេលកំណត់នេះត្រូវស្ថិតនៅក្នុងអំឡុងពេល១ខែ ដោយគិតចាប់ពីថ្ងៃដែលដីកាសម្រេចអនុញ្ញាតឲ្យលក់បានចូលជាស្ថាពរ[៨៣]។ ក្នុងករណីដែលអ្នកទិញមិនបង់ ថ្លៃលក់ទេ ដីកាសម្រេចអនុញ្ញាតឲ្យលក់នោះនឹងបាត់បង់អានុភាព។ ក្នុងករណីដូចខាងលើនេះ

---

[៨០] មាត្រា៥៣៧ កថាខណ្ឌទី១ នៃក្រមនិតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

[៨១] មាត្រា៣៨៤ នៃក្រមនិតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

[៨២] មាត្រា៥៣២ កថាខណ្ឌទី២ នៃក្រមនិតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

[៨៣] មាត្រា៥៤៧ កថាខណ្ឌទី១ នៃក្រមនិតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

អ្នកទិញ មិនអាចទាម ទារឲ្យសងទឹកប្រាក់ដែលខ្លួនបានដាក់ជាការធានាលើសំណើទិញបានទេ។ តុលាការអនុវត្តត្រូវអនុវត្តការលក់ដោយបង្ខំសារជាថ្មី។ ដោយយោងតាមមាត្រា៤៤៧ កថាខណ្ឌទី៤ នៃក្រមដដែល ដែលកំណត់ក្នុងករណីថ្លៃលក់ត្រូវបានបង់ ហើយអ្នកទិញធ្វើលទ្ធកម្មនៃអចលនវត្ថុនៅពេលដែលខ្លួនបានបង់ថ្លៃលក់ហើយ។ ប្រសិនបើថ្លៃលក់បានបង់ហើយ ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជី និងលុយការចុះបញ្ជីនូវចំណុចដូចកំណត់ខាងក្រោមនេះ៖

៱ ការចុះបញ្ជីអំពីការផ្ទេរសិទ្ធិដែលអ្នកទិញបានធ្វើលទ្ធកម្ម។

៱ ការលុបការចុះបញ្ជីអំពីលទ្ធកម្មនូវសិទ្ធិដែលបានរលត់ ឬសិទ្ធិដែលបានបាត់បង់អានុភាពដោយការលក់។

តុលាការអនុវត្តអាចចេញដីកាសម្រេចបង្គាប់ឲ្យកូនបំណុលនៃការអនុវត្ត ឬអ្នកកាន់កាប់អចលន វត្ថុប្រគល់អចលនវត្ថុនោះទៅឲ្យអ្នកទិញតាមពាក្យសុំរបស់អ្នកទិញដែលបានបង់ថ្លៃលក់ហើយ[៩៤]។

## ផ្នែកទី៣៖ ចែកចំណែក

ចំណែកដែលត្រូវយកមកចែកគឺ បានមកពីថ្លៃលក់អចលនវត្ថុដែលបានរឹបអូសមកបែងចែកឲ្យម្ចាស់បំណុល។ ករណីដែលម្ចាស់បំណុលមានតែម្នាក់ ក្រោយពេលបានបង់សិទ្ធិលើបំណុលឲ្យម្ចាស់បំណុលហើយ ផ្តល់ប្រាក់ដែលនៅសេសសល់ឲ្យទៅកូនបំណុលនៃការអនុវត្ត។ ដោយឡែកប្រសិនបើម្ចាស់បំណុលមានច្រើននាក់ ហើយប្រាក់ដែលបានមកពីការលក់មិនគ្រប់ចំនួនទឹកប្រាក់សិទ្ធិលើបំណុលទេត្រូវបែងចែកតាមការព្រមព្រៀង ឬតាមការកំណត់នៃច្បាប់។ ការរៀបចំចែកចំណែកនេះ គឺតុលាការអនុវត្តត្រូវអនុវត្តការចែកចំណែកម្ចាស់បំណុលដែលត្រូវទទួលចំណែក[៩៥]។

### ១. ការរៀបចំការចែកចំណែក

**ម្ចាស់បំណុលដែលត្រូវទទួលចំណែក៖**

១. ម្ចាស់បំណុលដែលបានដាក់ពាក្យសុំការលក់ដោយបង្ខំ ឬការលក់ដោយបង្ខំដែលជាការអនុវត្តឯកសិទ្ធិទូទៅរហូតដល់កំណត់ពេលចុងក្រោយសម្រាប់ការទាមទារឲ្យចែកចំណែក។ ជាទូទៅ៖ គឺមានចំណុចសំខាន់ៗដូចជា៖ **ការដាក់ពាក្យសុំដោយផ្អែកលើលិខិតអនុវត្ត និងដាក់ពាក្យសុំជាការអនុវត្តសិទ្ធិប្រាតិភោគ។**

២. ម្ចាស់បំណុលដែលទាមទារឲ្យចែកចំណែក រហូតដល់ពេលកំណត់ចុងក្រោយសម្រាប់ការទាមទារឲ្យចែកចំណែក។

---

[៩៤] មាត្រា៤៥០ កថាខណ្ឌទី១ នៃក្រមនិតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

[៩៥] មាត្រា៤៥៣ នៃក្រមនិតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

**ជនដែលអាចទាមទារឲ្យចែកចំណែក[៨៦]៖**

• ជនដែលមានលិខិតអនុវត្ត (មាត្រា៣៥៤ និង មាត្រា ៣៥០ កថាខណ្ឌទី២ នៃក្រមដដែល)

• ម្ចាស់បំណុលដែលបានចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន នៅក្រោយពេលចុះបញ្ជីអំពីការរឹបអូស ដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំ។

• ជនដែលមានឯកសិទ្ធិទូទៅ (យោងតាមមាត្រា ៧៨៣ នៃក្រមរដ្ឋប្បវេណី)។

៣. ម្ចាស់បំណុលដែលបានចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ន នៅមុនការចុះបញ្ជីអំពីការរឹបអូសដោយផ្អែកលើដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំដំបូង។

ម្ចាស់បំណុលដែលបានចុះបញ្ជីអំពីការរឹបអូសជាបណ្ដោះអាសន្ននៅក្រោយពេលចុះបញ្ជីអំពីការរឹបអូស ត្រូវធ្វើការទាមទារឲ្យចែកចំណែកសិន ទើបអាចទទួលការចែកចំណែកបាន (យោងតាមមាត្រា ៤២៦ កថាខណ្ឌទី១ ចំណុច ខ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ លើសពីនេះចំណុចដែលត្រូវធ្វើការប្រុងប្រយ័ត្ននោះគឺ ម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគដែលនឹងបន្តមានអត្ថិភាពក្រោយការលក់ (ម្ចាស់បំណុលដែលមានសិទ្ធិប្រាតិភោគដែលត្រូវបានចុះបញ្ជី នៅមុនការចុះបញ្ជីអំពីការរឹបអូស) ទោះបីជាមានលិខិតអនុវត្តក៏ដោយ ក៏មិនអាចទទួលការចែកចំណែកបានឡើយ (ហើយក៏មិនអាច ទាមទារឲ្យចែកចំណែកបានដែរ)។

ដើម្បីអាចទទួលបានការចែកចំណែក ត្រូវដាក់ពាក្យសុំការលក់ដោយបង្ខំដែលជាការអនុវត្តសិទ្ធិប្រាតិភោគដោយឆន្ទៈរបស់ខ្លួននៅមុនពេលកំណត់ចុងក្រោយនៃការទាមទារឲ្យចែកចំណែក[៨៧]។ តុលាការអនុវត្តដែលត្រូវចែកចំណែកត្រូវកំណត់កាលបរិច្ឆេទនៃការចែកចំណែក ហើយផ្ដល់ដំណឹងអំពីពេលវេលា និងទីកន្លែងនោះទៅម្ចាស់បំណុលដែលត្រូវទទួលការចែកចំណែក និងកូនបំណុល[៨៨]។

## ២. ការចែកចំណែក

**វិធីចែកចំណែកមាន២គឺ៖**

១. ការចែកចំណែកដោយមិនចាំបាច់ផ្អែកលើតារាងចែកចំណែក ដោយយោងតាមមាត្រា ៤៨៩ កថាខណ្ឌទី១ វាក្យខណ្ឌទី២ និង កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ក្នុងករណីដែលមានម្ចាស់ បំណុលមានតែម្នាក់ ឬក្នុងករណីដែលម្ចាស់បំណុលមានច្រើននាក់ ហើយទឹកប្រាក់ដែលត្រូវបំពេញការចែកចំណែកនោះ អាចសងសព្វគ្រប់ចំពោះសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនីមួយៗព្រមទាំងសោហ៊ុយសម្រាប់ការអនុវត្ត។

[៨៦] មាត្រា៤២៦ កថាខណ្ឌទី១ នៃក្រមនិតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

[៨៧] មាត្រា៤២២ កថាខណ្ឌទី៣ ចំណុចខ នៃក្រមនិតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

[៨៨] មាត្រា៤៨៨ កថាខណ្ឌទី១ នៃក្រមនិតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

**ឧទាហរណ៍ជាក់ស្តែង១៖**

ម្ចាស់បំណុលដែលអាចទទួលការចែកចំណែក (ចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល)

A (៥លានរៀល)

B (៣លានរៀល)

ចំនួនទឹកប្រាក់សរុបដែលត្រូវអនុវត្តការចែកចំណែកគឺ ៩លានរៀល។

**ដូចនេះម្ចាស់បំណុលដែលអាចទទួលការចែកចំណែក (ចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល)**

A (៥លានរៀល) ⟶ **៥លានរៀល**

B (៣លានរៀល) ⟶ **៣លានរៀល**

ប្រាក់ដែលសល់ពីការចែកចំណែក ២លានរៀល ប្រគល់ទៅកូនបំណុល។

២. ការចែកចំណែកដោយផ្អែកលើតារាងចែកចំណែកដែលបានធ្វើនៅកាលបរិច្ឆេទនៃការចែកចំណែកយោងតាមមាត្រា ៤៨៩ កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមដដែល។ តុលាការត្រូវធ្វើតារាងចែកចំណែកនៅកាលបរិច្ឆេទនៃការចែកចំណែក[៨៩]។ នៅកាលបរិច្ឆេទចែកចំណែកត្រូវកោះ ហៅម្ចាស់បំណុលដែលត្រូវទទួលចំណែក (មាត្រា៥៥៣ នៃក្រមដដែល) និងកូនបំណុលនៃការអនុវត្ត (មាត្រា៤៩០ កថាខណ្ឌទី២ ចំណុច គ)។

តុលាការត្រូវធ្វើសេចក្តីព្រាងនៃតារាងចែកចំណែកដោយផ្អែកលើលិខិតគណនាដែលត្រូវបានដាក់ដោយម្ចាស់បំណុលម្នាក់ៗជាមុន។ នៅកាលបរិច្ឆេទចែកចំណែកពាក់ព័ន្ធនឹងការធ្វើតារាងចែកចំណែកតុលាការអាចសួរម្ចាស់បំណុល និងកូនបំណុលនៃការអនុវត្តដែលបង្ហាញខ្លួន ហើយអាចធ្វើការពិនិត្យភស្តុតាងជាឯកសារដែលអាចធ្វើការពិនិត្យភ្លាមៗបាននៅកាលបរិច្ឆេទនៃការចែកចំណែក យោងតាមមាត្រា៤៩០ កថាខណ្ឌទី៣ នៃក្រមដដែល)។ ចំណុចសំខាន់ដែលត្រូវសរសេរក្នុងតារាងចែកចំណែក យោងតាមមាត្រា៤៩០ កថាខណ្ឌទី៤ ចំណុច គ នៃក្រមដដែលមានដូចខាងក្រោម៖

- ចំនួនទឹកប្រាក់បានមកពីការលក់
- អំពីម្ចាស់សិទ្ធិលើបំណុលម្នាក់ៗ
  - ប្រាក់ដើម ការប្រាក់ ការប្រាក់យឺតយ៉ាវនៃសិទ្ធិលើបំណុលជាអាទិ៍
  - ចំនួនទឹកប្រាក់នៃសោហ៊ុយអនុវត្ត។

លំដាប់ និងចំនួនទឹកប្រាក់នៃការចែកចំណែក យោងតាមមាត្រា៤៩០ កថាខណ្ឌទី៥ នៃក្រមដដែល

[៨៩] មាត្រា៤៩០ នៃក្រមនិតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦

• នៅកាលបរិច្ឆេទចែកចំណែក ក្នុងករណីដែលកិច្ចព្រមព្រៀងបានសម្រេចឡើងរវាងម្ចាស់បំណុលគ្រប់រូប នោះត្រូវសរសេរតាមការព្រមព្រៀង។

• ដោយឡែកក្នុងករណីដែលកិច្ចព្រមព្រៀងមិនអាចសម្រេចបាន ត្រូវសរសេរតាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ច្បាប់ដែលទាក់ទងនឹងពាណិជ្ជកម្ម ឬច្បាប់ផ្សេងទៀត។ ជាក់ស្តែងការសម្រេចដោយការព្រមព្រៀងគ្នា គឺពុំសូវមានទេ ភាគច្រើនគឺចែកចំណែកតាមបញ្ញត្តិនៃច្បាប់។

**ឧទាហរណ៍ជាក់ស្តែង១៖ ប្រសិនបើរវាងម្ចាស់បំណុលមានលក្ខខណ្ឌស្មើគ្នា**

ម្ចាស់បំណុលដែលអាចទទួលការចែកចំណែក (ចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល)

A (៤លានរៀល) សិទ្ធិលើបំណុលទូទៅ

B (៦លានរៀល) សិទ្ធិលើបំណុលទូទៅ

C (៨លានរៀល) សិទ្ធិលើបំណុលទូទៅ

**ចំនួនទឹកប្រាក់សរុបដែលត្រូវចែកចំណែកគឺ៩លានរៀល។**

**ចំនួនប្រាក់ចំណែក**

A (៤លានរៀល) → ២លានរៀល

B (៦លានរៀល) → ៣លានរៀល

C (៨លានរៀល) → ៤លានរៀល

មានន័យថាយកទឹកប្រាក់ ៩លានរៀលបែងចែកស្របតាមសមាមាត្រនៃទឹកប្រាក់សិទ្ធិលើបំណុល របស់ A: B: C: (៤: ៦: ៨: = ២: ៣: ៤:)

ពុំមានប្រាក់ដែលនៅសល់ត្រូវប្រគល់ឲ្យទៅភាគីកូនបំណុលនៃការអនុវត្តទេ។

**ឧទាហរណ៍ជាក់ស្តែង២៖ ប្រសិនបើរវាងម្ចាស់បំណុលមានលក្ខខណ្ឌអាទិភាព**

ម្ចាស់បំណុលដែលអាចទទួលបានការចែកចំណែក (ចំនួនទឹកប្រាក់នៃសិទ្ធិលើបំណុល)

A (៤លានរៀល) សិទ្ធិលើបំណុលទូទៅ

B (៦លានរៀល) ជនដែលមានឯកសិទ្ធិទូទៅ

C (៨លានរៀល) សិទ្ធិលើបំណុលទូទៅ

ចំនួនទឹកប្រាក់សរុបដែលត្រូវអនុវត្តការចែកចំណែកគឺ ៩លានរៀល។

**ចំនួនប្រាក់ចំណែក**

A (៤លានរៀល) → ១លានរៀល

B (៦លានរៀល) → ៦លានរៀល

C (៨លានរៀល) → ២លានរៀល

ក្រោយពេលបានចែកចំណែកសិទ្ធិលើបំណុលទាំងអស់របស់ម្ចាស់បំណុល B ដែលត្រូវផ្តល់អាទិភាពរួចហើយ ទើបយកចំនួនប្រាក់សេសសល់ ៩-៦ =៣ ចែកតាមសមាមាត្រនៃចំនួនប្រាក់សិទ្ធិលើបំណុល (៤: ៨: = ១: ២:) ពុំមានប្រាក់ដែលនៅសល់ត្រូវប្រគល់ឲ្យទៅភាគីកូនបំណុលនៃការអនុវត្តទេ។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវ និងតាមរយ:ការសរសេររៀបរាប់អំពីខ្លឹមសារខាងលើ អាចអោយយើងខ្ញុំធ្វើការសន្និដ្ឋានបានថា: នីតិវិធីអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ពិតជាមានសារ:សំខាន់យ៉ាងខ្លាំងសម្រាប់ អ្នកអនុវត្តច្បាប់ក្នុងការអនុវត្តអោយស្របតាមអ្វីដែលច្បាប់បានអនុម័ត និងជាពិសេសជាជំនួយដល់មន្ត្រីអនុវត្តគ្រប់ជាន់ថ្នាក់ ព្រមទាំងប្រជាពលរដ្ឋអោយយល់ដឹងកាន់តែច្បាស់អំពីគោលបំណងនៃច្បាប់នេះ និងដើម្បីការពារផលប្រយោជន៍របស់ម្ចាស់បំណុលទៀតផង។ ក្រៅពីនេះទៅទៀតយើងសង្កេតឃើញថា ការអនុវត្តដោយបង្ខំជានីតិវិធីដែលមានលក្ខណ:ស្មុគស្មាញ និងស៊ីជម្រៅដោយហេតុថា: បើកូនបំណុលនៃការអនុវត្តត្រូវបានតុលាការបង្គាប់បញ្ជា និងប្រើប្រាស់កំលាំងដោយបង្ខំក្នុងការដកហូតអធន្ទ:នូវអចលនវត្ថុរបស់ពួកគាត់ក្តី ក៏ប៉ុន្តែច្បាប់នូវតែការពារសិទ្ធិ និងផលប្រយោជន៍របស់គាត់ ដោយធ្វើយ៉ាងណាកុំឲ្យប៉ះពាល់ដល់ផលប្រយោជន៍ដទៃទៀត។ នីតិវិធីអនុវត្តដោយបង្ខំពិតជាមានសារ:សំខាន់ក្នុងប្រព័ន្ធដោះស្រាយរឿងក្តីរដ្ឋប្បវេណីដោយហេតុថា: សាលក្រមដែលបង្គាប់ឲ្យកូនបំណុលផ្តល់តាវកាលិកជូនទៅម្ចាស់បំណុល មានអានុភាពត្រឹមតែកំណត់អត្ថិភាពនៃសិទ្ធិតែប៉ុណ្ណោះ ដូច្នេះចង់ ឬមិនចង់កូនបំណុលនៅតែមានចេតនាគេចវេសការបំពេញតាវកាលិកជូនម្ចាស់បំណុលដែលមានអត្ថិភាពនៃសិទ្ធិទាមទារដដែល ប្រសិនបើគ្មានប្រព័ន្ធអនុវត្តដោយបង្ខំមួយដើម្បីបង្ខិតបង្ខំឲ្យកូនបំណុលនោះផ្តល់តាវកាលិកដល់ម្ចាស់បំណុល។ សិទ្ធិរបស់ម្ចាស់ បំណុលនៃការអនុវត្តដោយបង្ខំដែលមានបំណងអោយសងជាសាច់ប្រាក់ និងសម្រេចបានស្ថាពរនៅ ពេលដែលបំណុលជាប្រាក់របស់គាត់ត្រូវបានសងប្រាក់ត្រឡប់មកវិញជាប្រាក់។

ទន្ទឹមនឹងសារសំខាន់យើងកត់សម្គាល់ថា: ការអនុវត្តដោយបង្ខំមិនមែនសុទ្ធតែអាចសម្រេចបានដោយជោគជ័យនោះឡើយ ហើយក៏មានករណីខ្លះការអនុវត្តដោយបង្ខំត្រូវបានរារាំង ឬអាក់ខានទៅវិញដោយឧបសគ្គនានា ជាអាទិ៍ ការរារាំងពីក្រុមប្រជាពលរដ្ឋដែលប្រដាប់អាវុធ និងសកម្មភាពទាស់ទែងពីសំណាក់ប្រជាពលរដ្ឋដែលជាកូនបំណុលអនុវត្ត ដែលទាំងនេះជាបញ្ហាប្រឈមនាពេលបច្ចុប្បន្នសម្រាប់មន្ត្រីអនុវត្ត។

# អនុសាសន៍

## អនុសាសន៍

ដើម្បីជាការរួមចំណែកដល់ការកែលម្អ និងបង្កើនប្រសិទ្ធិភាពនៃការងារអនុវត្តដោយបង្ខំនេះ ឲ្យកាន់តែមានប្រសិទ្ធិភាព ក្នុងនាមក្រុមយើងខ្ញុំជាអ្នកសិក្សាស្រាវជ្រាវអំពីប្រធានបទនេះ យើងខ្ញុំបាន ដាក់ ចេញនូវអានុសាសន៍ ពីរចំណុចធំៗគឺ៖

**១. អានុសាសន៍ដើម្បីបង្ការ និងទប់ស្កាត់ជម្លោះក្នុងសង្គម**

**ក. បង្កើនការងារផ្សព្វផ្សាយអប់រំច្បាប់:** ការយល់ដឹងអំពីច្បាប់ គឺមានសារៈសំខាន់ណាស់សម្រាប់ប្រជាពលរដ្ឋក្នុងសង្គមដើម្បីបញ្ចៀសទំនាស់ផ្សេងៗ ជាក់ស្តែងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ គឺត្រូវបានតាក់តែងឡើងក្នុងគោលបំណងគ្រប់គ្រងទំនាក់ទំនងរបស់ពលរដ្ឋក្នុងសង្គមដែលមានបញ្ញត្តិអំពីសិទ្ធិ កាតព្វកិច្ច កិច្ចសន្យា ការទទួលខុសត្រូវចំពោះកំហុសញាតិភាព និងការបែងចែកទ្រព្យសម្បត្តិជាដើម។ ច្បាប់ដទៃទៀតក៏ត្រូវបានបង្កើតឡើងដើម្បីបង្ការបង្ក្រាបបទល្មើស និងដោះស្រាយទំនាស់កុំឲ្យកើតមាន ឬបន្តកើតមាននៅក្នុងសង្គម និងរៀបចំសង្គមឲ្យមានសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយតាមរយៈការដាក់ទណ្ឌកម្មឲ្យធួនល្មមទៅនឹងអំពើ ដែលជនទាំងនោះ បានប្រព្រឹត្ត ឬបានបំពាន។ កាលណាប្រជាពលរដ្ឋភាគច្រើនបាន យល់ដឹងអំពីច្បាប់ ទំនាស់ក៏ត្រូវបានកាត់បន្ថយដែរ។ ការអប់រំផ្សព្វផ្សាយច្បាប់ត្រូវធ្វើជាទូទៅដល់ពលរដ្ឋទាំងអស់ ជាពិសេសក្នុងចំណោម សិស្ស និស្សិត និងយុវជន ព្រោះយុវជនក្នុងប្រទេសនីមួយៗមានចំនួនច្រើន ស្មារតីល្អ ឆាប់យល់ ងាយចងចាំ និងអាចពង្រីកការយល់ដឹងរបស់ខ្លួនបន្តបានលឿន និងបានយូរអង្វែង។ លើសពីនេះការផ្សព្វផ្សាយច្បាប់គប្បីធ្វើផងដែរចំពោះអ្នកសារព័ត៌មានអំពីនីតិវិធីរបស់តុលាការជាដើម ព្រោះ អង្គភាព ព័ត៌មានទាំងអស់ជាបណ្តាញផ្សព្វផ្សាយយ៉ាងឆាប់រហ័ស និងមានប្រសិទ្ធភាព គម្បីជៀសវាងការផ្សាយខុស នាំឲ្យមានការភ័ន្តច្រឡំ និងបង្កចលាចលនៅក្នុងសង្គម។

**ខ. បន្តជំរុញការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ:** យើងសង្កេតឃើញថា ដើម្បីឲ្យតុលាការដោះស្រាយរឿងក្តីប្រកបដោយយុត្តិធម៌បាន តុលាការត្រូវការ ការពិនិត្យ វិនិច្ឆ័យឲ្យបានហ្មតចត់ និងប្រើរយៈពេលយូរ។ លើសពីនេះ រឿងក្តីរដ្ឋប្បវេណី បន្ទុកនានាត្រូវធ្លាក់មកលើភាគី ជាអាទិ៍ ការបង់ពន្ធពាក្យសុំ ប្រាក់ប្រដាប់ក្តី សោហ៊ុយសម្រាប់អនុវត្ត សោហ៊ុយធ្វើដំណើរ ការស្នាក់នៅការហូបចុកក្នុងអំឡុងពេល ទៅមកតុលាការ...។ល។ ករណីខ្លះបំណុល ដែលម្ចាស់បំណុលទទួលបានមកវិញ ស្ទើរតែមិនអាចទូទាត់ជាមួយការចំណាយពេលវេលា និងថវិការរបស់ខ្លួនក្នុងអំឡុងពេលដោះស្រាយ រឿងក្តីផង។ ផលវិបាកធ្ងន់ទាំងនេះ គឺកើតមានចំពោះសង្គមទាំងមូលតែម្តង គឺកាលណាទំនាស់កើតឡើងមិនមែនត្រឹមតែបុគ្គល ពីរ ឬបីនាក់ដែលជាភាគីនៃទំនាស់នោះទេ ដែលបែកបាក់មិត្តភាពនឹងគ្នា ប៉ុន្តែគឺគ្រួសារទាំងពីរតែម្តង ចុះប្រសិនបើក្នុងសង្គមទាំងមូលពោរពេញ

ដោយទំនាស់នោះ ប្រាកដណាស់ថា: សង្គមជាតិនឹងមិនមានសាមគ្គីភាពគ្នានោះឡើយ។ ការដោះស្រាយក្រៅប្រព័ន្ធតុលាការ ទោះបីមិនមានយុត្តិធម៌មួយរយភាគរយ យ៉ាងហោចណាស់ភាគីទាំងពីរព្រមទទួលយក ដំណោះស្រាយ ដ៏សមស្របមួយ នឹងអាចឈានទៅរកមិត្តភាពឡើងវិញ។ លើកលែងតែក្នុងករណីខ្លះដែលការដោះស្រាយក្រៅប្រព័ន្ធតុលាការនេះ គ្មានដំណោះស្រាយល្អ ទើបគប្បីទៅពឹងពាក់តុលាការជាជម្រើសចុងក្រោយ។

**គ. ជំរុញការចុះបញ្ជីដីធ្លី:** ក្រៅពីទំនាស់ជំពាក់ប្រាក់ដែលត្រូវសងជាប្រាក់ មានទំនាស់ជាច្រើនដែលកើតឡើងដោយសារការកំណត់ព្រំប្រទល់ដីមិនបានច្បាស់លាស់។ ដូច្នេះការចុះបញ្ជីដីធ្លីពិតជាមានសារៈសំខាន់ដើម្បីបង្ការទំនាស់កើតឡើង។ សារៈសំខាន់ពីការចុះបញ្ជីដីនេះដែរចំពោះការអនុវត្តដោយ បង្ខំ គឺមានភាពងាយស្រួល ដើម្បីតុលាការបង្គាប់ឲ្យចុះបញ្ជីផ្ទុកផ្តាក់អំពីការរឹបអូសអចលនទ្រព្យរបស់កូនបំណុល ជៀសវាងកូនបំណុលគេចវេសមិនអនុវត្តកាតព្វកិច្ចតាមរយៈការផ្ទេរកម្មសិទ្ធិលើអចលនវត្ថុ មុនការអនុវត្តដោយបង្ខំ ជាហេតុធ្វើឲ្យការអនុវត្តដោយបង្ខំមិនអាចសម្រេចបាន។

២. អានុសាសន៍ដើម្បីបង្កើនសមត្ថភាពរបស់ស្ថាប័នអនុវត្ត

**ក. ការបង្កើតច្បាប់:** ថ្វីបើបញ្ញត្តិជាច្រើនមានជាអាទិ៍ ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណីត្រូវបានយកមកអនុវត្តទាក់ទងនឹងការអនុវត្តដោយបង្ខំក្តី ក៏ប៉ុន្តែបញ្ញត្តិមួយចំនួនមិនត្រូវបានយកមកអនុវត្តនៅឡើយជាក់ស្តែង បញ្ញត្តិស្តីពីស្ថាប័នអាជ្ញាសាលាដែលមានតួនាទីយ៉ាងសំខាន់ក្នុងនីតិវិធីអនុវត្តដោយបង្ខំចំពោះចលនវត្ថុជាអាទិ៍។ បច្ចុប្បន្ន តួនាទីរបស់អាជ្ញាសាលានេះត្រូវបានជំនួសដោយព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងនៅតាមសាលាដំបូង រាជធានី ខេត្តនានា។ ដើម្បីសម្រាលការងាររបស់ព្រះរាជអាជ្ញាដែលមានច្រើន និងដើម្បីផ្តល់សិទ្ធិអំណាចដល់សាលាដែលត្រូវបានជ្រើសរើស និងបណ្តុះបណ្តាលប្រកបដោយគុណវុឌ្ឍិគ្រប់គ្រាន់ គម្បីពន្លឿនការអនុម័តច្បាប់ស្តីពីលក្ខន្តិកៈអាជ្ញាសាលានេះ ហើយចាត់តាំងទៅបំពេញមុខងាររបស់ខ្លួនឲ្យមានប្រសិទ្ធភាព ស្របតាមក្រមនីតិវិធីរដ្ឋប្បវេណី និងច្បាប់ផ្សេងទៀតជាធរមាន។

**ខ. ការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់:** មន្ត្រីអនុវត្តនៅទីនេះ យើងខ្ញុំរាប់បញ្ចូលទាំងមន្ត្រីតុលាការ ដែលដឹកនាំសម្រមសម្រួលអនុវត្តនីតិវិធីមាន ចៅក្រម ក្រឡាបញ្ជី និងអាជ្ញាសាលា និងមន្ត្រីដែលចូលរួមក្នុងការប្រតិបត្តិ ការអនុវត្តតាមគ្រប់ដំណាក់កាលមាន មន្ត្រីសុរិយោដី អាជ្ញាធរមូលដ្ឋាន និងកងកម្លាំងសាធារណៈ ជាដើម។ ការពង្រឹងសមត្ថភាពគឺពិតជាមានសារៈសំខាន់ណាស់ ដើម្បីធានាថា មន្ត្រីនីមួយៗយល់ដឹងអំពីនីតិវិធីតុលាការ និងតួនាទីរបស់ខ្លួន ផ្តល់កិច្ចសហការហើយចូលរួមអនុវត្តច្បាប់ និងសេចក្តីសម្រេចរបស់តុលាការឲ្យមានប្រសិទ្ធភាពខ្ពស់។

**គ. ការបណ្តុះសីលធម៌មន្រ្តីអនុវត្តច្បាប់:** ការអប់រំមួយដែលមនុស្សគ្រប់គ្នាតែងតែមើលរំលង គឺសីលធម៌របស់មន្រ្តីអនុវត្តច្បាប់ ដែលកន្លងមកគេឃើញមានសារព័ត៌មានមួយចំនួនបានចុះផ្សាយពីមន្រ្តីខិលខូចមួយចំនួនតូច ប្រើប្រាស់អំណាចរបស់ខ្លួនទៅគៀបសង្កត់ពលរដ្ឋស្លូតត្រង់ គ្មានកំហុស ឆ្លៀតឱកាសពេលបំពេញមុខងាររបស់ខ្លួន ធ្វើឲ្យខូចខាតទ្រព្យសម្បត្តិកូនបំណុល និងបន្លំកិបកេងទ្រព្យសម្បត្តិកូនបំណុលក្នុងប្រតិបត្តិការរឹបអូស ឆែកឆេរ ឬអនុវត្តការគ្រប់គ្រងជាដើម។ កាលណាមន្រ្តីទាំងអស់បំពេញការងាររបស់ខ្លួនប្រកបដោយសមត្ថភាព និងសីលធម៌ខ្ពស់ វាស្តែងឲ្យឃើញពីប្រសិទ្ធភាពការងារ និងជំនឿទុកចិត្តពីប្រជាពលរដ្ឋចំពោះស្ថាប័នតុលាការ ដែលនាំមកនូវកិត្យានុភាពនៃស្ថាប័នរដ្ឋ និង សុខដុមរមនានៃពលរដ្ឋក្នុងសង្គមទាំងមូលផងដែរ។

ហេតុដូចនេះហើយក្នុងនាមយើងខ្ញុំជានិស្សិតច្បាប់ ក៏ដូចជាប្រជាពលរដ្ឋផ្សេងៗទៀត តែងតែមានក្តីរំពឹងមួយចង់អោយមន្រ្តីគ្រប់រូបចូលរួមអនុវត្តតួនាទីរបស់ខ្លួនទៅតាមមុខងារនីមួយ ដើម្បីចូលរួមលើកស្ទួយវិស័យយុត្តិធម៌របស់កម្ពុជាកាន់តែល្អប្រសើរថែមទៀត។

# ឯកសារពិគ្រោះ

# ឯកសារពិគ្រោះ


១. រដ្ឋធម្មនុញ្ញ ប្រកាសឲ្យប្រើនៅថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣

២. ក្រមនីតិវិធីរដ្ឋប្បវេណី ប្រកាសឲ្យប្រើនៅថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០០៦

៣. ក្រមរដ្ឋប្បវេណី ប្រកាសឲ្យប្រើនៅថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧

៤. ច្បាប់ស្តីពីនីតិវិធីនៃការពិន័យស៊ីវិល ឆ្នាំ ២០១១

៥. ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល និងច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹង ឆ្នាំ ២០១១

៦. សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ១ ដល់ភាគ៦

៧. សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគី១៖ នីតិវិធីបណ្តឹង បោះពុម្ពឆ្នាំ២០០៩

៨. សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគី២៖ ការអនុវត្តដោយបង្ខំ និង ការចាត់ចែងរក្សាការពារ បោះពុម្ពឆ្នាំ២០០៨ របស់ក្រសួងយុត្តិធម៌

៩. Jica មេរៀនក្រមរដ្ឋប្បវេណី ភាគ១ ដល់ភាគ៦

១០. សេចក្តីផ្តើមនីតិរដ្ឋប្បវេណី (និពន្ធដោយសាស្ត្រាចារ្យ ណូមូរ៉ា តូយ៉ូហ៊ីរ៉ូ) (បោះពុម្ពលើកទី៥ ភ្នំពេញ ២០១១)

១១. សៀវភៅសិក្សារបស់ក្រសួងយុត្តិធម៌ នៃវិទ្យាស្ថានចម្រុះស្រាវជ្រាវ និង បណ្តុះបណ្តាលកិច្ចការច្បាប់ (ICD) ដោយសាស្ត្រាចារ្យ HIGASHIO Kazuyuki និង សាស្ត្រាចារ្យ YUKAWA Ryo

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

| | |
|---|---|
| ១ | ពាក្យបណ្តឹង របស់សាលាដំបូងរាជធានីភ្នំពេញ ចូលថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០១៦ |
| ២ | ដីកាសម្រេចបង្គាប់ឲ្យបង់ប្រាក់ប្រដាប់ក្តីតុលាការក្រៅពីពន្ធ |
| ៣ | ដីកាកោះ |
| ៤ | កំណត់ហេតុស្តីពីនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលផ្ទាល់មាត់ |
| ៥ | ដីកាអញ្ជើញ |
| ៦ | សំណើសុំស្រាវជ្រាវអំពីសណ្ឋានអចលនវត្ថុ |
| ៧ | ដីកាអម សំណើសុំស្រាវជ្រាវអំពីសណ្ឋានអចលនវត្ថុ អំពីទំនាក់ទំនង និងការកាន់កាប់ ឬការជាប់បន្ទុក ព្រមទាំងស្ថានភាពផ្សេងនៃ អចលនវត្ថុ |
| ៨ | កំណត់ហេតុស្តីពីការចុះពិនិត្យស្រាវជ្រាវអំពីសណ្ឋានអចលនវត្ថុ អំពីទំនាក់ទំនង និងការកាន់កាប់ ឬការជាប់បន្ទុក ព្រមទាំងស្ថានភាពផ្សេងនៃ អចលនវត្ថុ |
| ៩ | របាយការណ៍ស្តីពីការស្រាវជ្រាវអំពីសណ្ឋានអចលនវត្ថុ របស់រដ្ឋបាលខណ្ឌដូនពេញ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ២០១៨ |
| ១០ | ដីកាបញ្ជូន |
| ១១ | ដីកាសម្រេច |
| ១២ | រូបមន្តអនុវត្តសាលក្រម |
| ១៣ | ដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ |
| ១៤ | ពាក្យសុំរូបមន្តអនុវត្តសាលក្រមបណ្តោះអាសន្ន |
| ១៥ | ពាក្យសុំរូបមន្តអនុវត្តសាលក្រមស្ថាពរ |
| ១៦ | ដីកាបង្គាប់ឲ្យវាយតម្លៃ |
| ១៧ | លិខិតផ្ទុកផ្តាក់អោយចុះបញ្ជីអំពីការរឹបអូសអចលនវត្ថុ |